# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៧៨

បាលីប្រែ ៩៧ - ៩៨

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# អភិធម្មបិដក

## និង

# បរមត្ថទីបនី អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## បដ្ឋាន

## ចតុត្ថភាគ និង បញ្ចមភាគ

## ៧៨

## បាលីប្រែ ៩៧-៩៨



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៤៣*

# ក្បាលទី ៧៨
# អភិធម្មបិដក ចតុត្ថភាគ
# អនុលោមត្តិកប្បដ្ឋានខាងចុង

*សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## វិតក្កត្តិកៈ
## បដិច្ចវារៈ

[ ១ ] *ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ វិតក្ក អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ វិតក្កអាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ*

ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ។

[ ២ ] ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺវិតក្កក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ វិតក្កក្តី កដត្តារូបក្តី អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី វិតក្កក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក

ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ។

[ ៣ ] ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌មិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌មិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ២ ក្តី វិតក្កក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី វិតក្កក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វិតក្កក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ ។

[ ៤ ] ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្ក ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្ក ក្នុងខណៈនៃបដិសន្ធិ ។

ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារ អាស្រ័យធម៌ដែលមិនមានវិតក្កៈ មាន ត្រឹមតែវិចារ ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺវិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ ចិត្តសមុដ្ឋានរូប អាស្រ័យវិតក្កៈ វិចារក្តី កដត្តារូបក្តី អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យវិតក្កៈ ក្នុងខណៈនៃបដិសន្ធិ ។

[ ៥ ] ធម៌ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី ធម៌ដែល មិនមានវិតក្កៈ មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្កៈ មានត្រឹម តែវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកប ដោយវិតក្កៈ ប្រកបដោយវិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិតក្កៈ ខន្ធ ទាំងឡាយ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី កដត្តារូបក្តី អាស្រ័យវិតក្កៈ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមិនមានវិតក្កៈ មានត្រឹម តែវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី អាស្រ័យធម៌ ដែល មិនមានវិតក្កៈ មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី វិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ ខន្ធ ២ ក្តី វិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី វិចារក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វិចារក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ ។

[ ៦ ] ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ចិត្តសមុដ្ឋានរូប អាស្រ័យវិចារ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ កដត្តារូប អាស្រ័យវិចារ ក្នុងខណៈនៃបដិសន្ធិ វត្ថុ អាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយអាស្រ័យវត្ថុ វត្ថុ អាស្រ័យវិចារ វិចារ អាស្រ័យវត្ថុ មហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប ឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។ ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវិចារ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ វិតក្ក អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ៧ ] ធម៌ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី ធម៌មិនមានវិតក្កៈ មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្កៈ មិនមានវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។ ធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្កៈ មិនមានវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិចារ ខន្ធទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី កដត្តារូបក្តី អាស្រ័យវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ វិតក្កៈ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ខន្ធទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី វិចារក្តី អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្កៈ មិនមានវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី វិតក្កៈក្តី អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ៨ ] ធម៌ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី ធម៌ដែលមិន

មានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៩ ] ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺវិតក្ក អាស្រ័យខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង ក្នុង

ខណៈនៃបដិសន្ធិ ។

[ ១០ ] ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្កប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្កប្រកបដោយវិចារផង មហាភូតទាំងឡាយផង ។ ធម៌ដែលមិនមានវិតក្កមានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺវិតក្ក អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្កប្រកបដោយវិចារផង មហាភូតទាំងឡាយផង ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ផង

វត្ថុផង ។

[ ១១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង ។

[ ១២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិចារផង ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង

វិចារផង ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង មហាភូតទាំងឡាយផង ចិត្តសមុដ្ឋានរូប អាស្រ័យវិតក្កផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យវិតក្កផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ វិចារ អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ។

[ ១៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យ

វិតក្កផង មហាភូតទាំងឡាយផង ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ផង វិចារផង ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ ផង វិចារផង ខន្ធ ៣ ក្តី វិចារក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វិចារក្តី អាស្រ័យខន្ធ ២ ផង វត្ថុផង ។

[ ១៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិតក្កផង ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិតក្កផង ។ ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិន

មានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ។

[ ១៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ផង វិតក្កផង ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ២ ផង វិតក្កផង ។

[ ១៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិតក្កផង វត្ថុផង ។ ធម៌ ដែលមិនមានវិតក្ក មិន

មានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង មហាភូតទាំងឡាយផង កដត្តារូបអាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។

[ ១៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ អាស្រ័យខន្ធ ៣ ផង វិតក្កផង វត្ថុផង ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិតក្កផង វត្ថុផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង មហាភូតទាំងឡាយផង ។

[ ១៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក

ប្រកបដោយវិចារ ខន្ធ ២ អាស្រ័យខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្កប្រកបដោយវិចារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺវិតក្ក អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ១៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្កប្រកបដោយវិចារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តីវិតក្កក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២០ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ខន្ធ ២ អាស្រ័យខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ ដែលប្រកបដោយវិតក្កប្រកបដោយវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្ក ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺវិចារ អាស្រ័យខន្ធ

ទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី វិចារក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ខន្ធ ២ ក្តី វិចារក្តី អាស្រ័យខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២២ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ វិចារ អាស្រ័យវត្ថុ ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវិចារ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយ ដែលមិន

មានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ វិតក្កអាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ២៣ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមិនមានវិតក្កមានត្រឹមតែវិចារក្តី វិចារក្តី អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែ វិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ២៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្កមិនមានវិចារផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺវិតក្ក អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ។

[ ២៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្កប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ផង វត្ថុផង ។

[ ២៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្កផង វត្ថុផងក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិចារផង ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិចារផង ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យ

ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺវិចារ អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ។

[ ២៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី វិចារក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វិចារក្តី អាស្រ័យខន្ធ ២ ផង វត្ថុផង ។

[ ២៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកប

ដោយវិចារផង វិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិតក្កផង វត្ថុផង ។

បច្ច័យទាំងពីរ លោកចែកហើយ ដោយផ្លូវនៃការស្វាធ្យាយ បច្ច័យ ២០ ដ៏សេស បណ្ឌិតគប្បីចែកយ៉ាងនេះដែរ ។

[ ២៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ( ខន្ធទាំងឡាយអាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ( ខន្ធទាំងឡាយអាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺវិតក្ក អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ( វិតក្កអាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ( ចិត្ត-សមុដ្ឋានរូប អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្ប-

យុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺវិតក្កក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ វិតក្ក ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ( ខន្ធទាំងឡាយ អាស្រ័យ ) វត្ថុ ( ទើបកើតឡើង )

ព្រោះវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ២ ក្តី វិតក្កក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធទាំងឡាយក្តី វិតក្កក្តី ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣២ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ។បេ។ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ( អាស្រ័យ ) ខន្ធ ២ ... ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្ក ( ខន្ធទាំងឡាយ អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មិន

មានវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺវិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ វិចារ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប អាស្រ័យវិតក្ក ( ចិត្តសមុដ្ឋានរូប អាស្រ័យ ) វិតក្ក ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិតក្កខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) វិតក្ក ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្តី វិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ខន្ធ ២ ក្តី វិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធទាំងឡាយក្តី វិចារក្តី ( អាស្រ័យ ) វត្ថុ ( ទើបកើត

ឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៤ ] ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធ ២ ... ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធទាំងឡាយ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប អាស្រ័យវិចារ ( ចិត្តសមុដ្ឋានរូប អាស្រ័យ ) វិចារ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប អាស្រ័យវិចារ ក្នុងខណៈនៃបដិសន្ធិ ( កដត្តារូប អាស្រ័យ ) វិចារ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ វត្ថុអាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយ អាស្រ័យវត្ថុ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ វត្ថុ ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ វត្ថុ អាស្រ័យវិចារ វិចារ អាស្រ័យវត្ថុ វិចារ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ វត្ថុ ( អាស្រ័យ ) វិចារ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ មហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ( ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង )

ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ( ខន្ធទាំងឡាយអាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវិចារ ( ខន្ធទាំងឡាយ អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវិចារ ក្នុងខណៈនៃបដិសន្ធិ ( ខន្ធទាំងឡាយ អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ( ខន្ធទាំងឡាយ អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ វិតក្ក អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ( វិតក្ក អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៣៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប

អាស្រ័យមហាភូតទាំងឡាយ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិចារ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) វិចារ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី កដត្តារូបក្តី អាស្រ័យវិចារ ក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) វិចារ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ វិតក្កអាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ វិតក្កអាស្រ័យវត្ថុទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយ

ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី វិចារក្តី អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ( ខន្ធទាំងឡាយ អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្កៈ មិនមានវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី វិតក្កក្តី អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ( ខន្ធទាំងឡាយក្តី វិតក្កក្តី អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៣៦ ] ធម៌ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្កៈ មិនមានវិចារ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី វិតក្កក្តី អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ខន្ធទាំងឡាយក្តី វិតក្កក្តី ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៣៧ ] ធម៌ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារផង ទើបកើតឡើងព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យ

ខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ( ខន្ធទាំងឡាយ អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្កមិនមានវិចារផង ... វិតក្ក អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្កប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ( វិតក្ក អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលមិនមានវិតក្កមិនមានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង ( ចិត្តសមុដ្ឋានរូប អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ។បេ។ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើត

ឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... វិតក្ក អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង វិតក្ក ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារៈផង ... ខន្ធ ៣ ក្តី វិតក្កក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ផង វត្ថុផង ( ខន្ធទាំងឡាយ អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៣៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិន

មានវិតក្ក មិនមានវិចារផង ... ខន្ធ ៣ ក្តី វិតក្កក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង ខន្ធទាំងឡាយក្តី វិតក្កក្តី ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៤០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ( ខន្ធទាំងឡាយ អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ( ខន្ធទាំងឡាយ អាស្រ័យ ) ខន្ធ ២ ផង វត្ថុផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ( ខន្ធទាំងឡាយ អាស្រ័យ ) ខន្ធ ២ ផង វត្ថុផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធ ៣

អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ( ខន្ធទាំងឡាយ អាស្រ័យ ) ខន្ធ ២ ផង វត្ថុផង ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ( ចិត្តសមុដ្ឋានរូប អាស្រ័យ ) ខន្ធទាំងឡាយផង វិចារផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង មហាភូតទាំងឡាយផង ( ចិត្តសមុដ្ឋានរូប អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប អាស្រ័យវិតក្កផង មហាភូតទាំងឡាយផង ( ចិត្តសមុដ្ឋានរូប អាស្រ័យ ) វិតក្ក ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ( កដត្តារូប អាស្រ័យ ) ខន្ធទាំងឡាយផង វិចារផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ( កដត្តារូប អាស្រ័យ ) ខន្ធទាំងឡាយ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប អាស្រ័យវិតក្កផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ( កដត្តារូប អាស្រ័យ ) វិតក្ក ( ទើប

កើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ វិចារ អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ( វិចារ អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៤១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យវិតក្កផង មហាភូតទាំងឡាយផង ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) វិតក្ក ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធទាំងឡាយផង វិចារផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ

( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយផង វិចារផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យខន្ធ ២ ផង ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង មហាភូតទាំងឡាយផង ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយ ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធ ៣ ក្តី វិចារក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ( អាស្រ័យ ) ខន្ធ ២ ផង ... ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៤២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ... ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ( ខន្ធទាំងឡាយ អាស្រ័យ ) ខន្ធ ២ ផង វត្ថុផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ( ខន្ធទាំងឡាយ អាស្រ័យ ) វត្ថុ ក្នុងខណៈនៃបដិសន្ធិ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ... ចិត្តសមុដ្ឋានរូប

អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ( ចិត្តសមុដ្ឋានរូប អាស្រ័យ ) ខន្ធទាំងឡាយផង វិតក្កផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ( ចិត្តសមុដ្ឋានរូបអាស្រ័យ ) ខន្ធទាំងឡាយផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៤៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ... ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ( ខន្ធទាំងឡាយអាស្រ័យ ) ខន្ធ ២ ... ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ចិត្តសមុដ្ឋានរូប ( អាស្រ័យ ) ខន្ធទាំងឡាយផង វិតក្កផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ក្នុងខណៈនៃបដិសន្ធិ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយផង វិតក្កផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៤៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើត

ឡើង ... ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ( ខន្ធទាំងឡាយ អាស្រ័យ ) ខន្ធ ២ ... ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ... ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង មហាភូតទាំងឡាយផង ( ចិត្ត-សមុដ្ឋានរូប អាស្រ័យ ) ខន្ធទាំងឡាយផង វិតក្កផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ( ចិត្តសមុដ្ឋានរូប អាស្រ័យ ) ខន្ធទាំងឡាយផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៤៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យខន្ធ ២ ផង ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង មហាភូតទាំងឡាយផង ខន្ធទាំងឡាយ ( អាស្រ័យ ) វត្ថុ ( ទើបកើត

ឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ កដត្តារូប ( អាស្រ័យ ) ខន្ធទាំងឡាយផង វិតក្កផង ( ទើបកើតឡើង ) ព្រោះវិប្បយុត្តប្បច្ច័យ ។

[ ៤៦ ] ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះអត្ថិប្បច្ច័យ ។ សេចក្តីបង្រួញ ។ ព្រោះនត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

[ ៤៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២១ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២៨ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២១ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១១ ក្នុងកម្មប្បច្ច័យ មានវារៈ ៣៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣៧ ក្នុងអាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ មានវារៈ ៣៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣៧ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ២១ ក្នុងវិគតប្បច្ច័យ មានវារៈ ២១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣៧ ។

ក្នុងអារម្មណប្បច្ច័យ មានវារៈ ២១ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ការរាប់ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីរាប់យ៉ាងនេះ

ដែរ ។

## អនុលោម ចប់

[ ៤៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ជាអហេតុកៈ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ២ អាស្រ័យខន្ធ ២ មោហៈដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ អាស្រ័យខន្ធទាំងឡាយ ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺវិតក្ក អាស្រ័យខន្ធទាំងឡាយ ជាអហេតុកៈ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយជាអហេតុកៈ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។

[ ៤៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី

ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ជាអហេតុកៈ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺវិតក្កក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធទាំងឡាយ ជាអហេតុកៈដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី អាស្រ័យខន្ធ ១ ជាអហេតុកៈ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។

[ ៥០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ជាអហេតុកៈ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។

[ ៥១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌

ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្ក ដែលជាអហេតុកៈ ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្ក ក្នុងខណៈនៃអហេតុកប្បដិសន្ធិ មោហៈដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ អាស្រ័យវិតក្ក ដែលច្រឡំដោយវិចិកិច្ឆា ច្រឡំដោយឧទ្ធច្ចៈ ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យវិតក្ក ដែលជាអហេតុកៈ កដត្តារូប អាស្រ័យវិតក្ក ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។

[ ៥២ ] ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិតក្កដែលជាអហេតុកៈ ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារៈក្តី កដត្តារូបក្តី អាស្រ័យវិតក្ក ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។

[ ៥៣ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ជាអហេតុកៈ ដែលមិនមានវិតក្ក មិនមានវិចារ ខន្ធ ១ អាស្រ័យខន្ធ ៣ ខន្ធ ២ អាស្រ័យខន្ធ ២ មហាភូត ៣ អាស្រ័យមហាភូត

១ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ពាហិរូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ ... កដត្តារូប និងឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺវិតក្ក អាស្រ័យវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។

[ ៥៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៥៥ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺវិតក្ក អាស្រ័យវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹម

តែវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី អាស្រ័យវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។

[ ៥៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី អាស្រ័យវត្ថុ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៥៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺវិតក្ក អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក

ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ជាអហេតុកៈ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។

[ ៥៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺវិតក្ក អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូប អាស្រ័យខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមាន

វិតក្ក មានត្រឹមតែវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ផង វត្ថុផង ។

[ ៥៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ផង វត្ថុផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង ។

[ ៦០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្កផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមាន

វិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យវិតក្ក ជាអហេតុកៈផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យវិតក្កផង មហាភូតទាំងឡាយផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ។

[ ៦១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្កផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ កដត្តារូប អាស្រ័យវិតក្កផង មហាភូតទាំងឡាយផង ។

[ ៦២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើងព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ជាអហេតុកៈដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិតក្កផង ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិតក្កផង មោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ អាស្រ័យខន្ធទាំងឡាយ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈផង វិតក្កផង ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ

ផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយជាអហេតុកៈដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។

[ ៦៣ ] ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្កប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ជាអហេតុកៈដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ផង វិតក្កផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។

[ ៦៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្កមានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិតក្កផង វត្ថុផង ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែល

មិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ជាអហេតុកៈ ដែលប្រកបដោយ វិតក្ក ប្រកបដោយវិចារផង វិតក្កផង មហាភូតទាំងឡាយផង ក្នុងខណៈ នៃអហេតុកប្បដិសន្ធិ ... ។

[ ៦៥ ] ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែល មិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង វត្ថុផង ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិតក្កផង វត្ថុផង កដត្តារូប អាស្រ័យខន្ធទាំងឡាយដែលប្រកបដោយ វិតក្ក ប្រកបដោយវិចារផង វិតក្កផង មហាភូតទាំងឡាយផង ។

[ ៦៦ ] ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែល ប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើងព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកប ដោយវិចារ កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ។

[ ៦៧ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលមិន មានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺ

ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែ វិចារ ចិត្តសមុដ្ឋានរូប អាស្រ័យវិតក្ក កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យវិតក្ក ក្នុងខណៈនៃបដិសន្ធិ ។

[ ៦៨ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្ត-សមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ចិត្តសមុដ្ឋានរូប អាស្រ័យវិចារ កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យ វិចារ វត្ថុ អាស្រ័យខន្ធទាំងឡាយ ពាហិររូប អាស្រ័យមហាភូត ១ ... អាហារ-សមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ ។

[ ៦៩ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។

[ ៧០ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលមិន

មានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ចិត្តសមុដ្ឋាន-រូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង មហាភូតទាំងឡាយផង ចិត្តសមុដ្ឋានរូប អាស្រ័យវិតក្កផង មហាភូតទាំងឡាយផង ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ។បេ។ កដត្តារូប ។

[ ៧១ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៧២ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង មហាភូតទាំងឡាយផង កដត្តារូប ( កើតឡើង ) ក្នុងខណៈនៃបដិសន្ធិ ។

[ ៧៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌

ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនអធិប-តិប្បច្ច័យ ។បេ។ វារៈ ៧ ។

[ ៧៤ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺ អធិបតិធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ខន្ធ ៣ អាស្រ័យខន្ធ ១ ជាវិបាក ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែល ប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្ក ក្នុងខណៈនៃ បដិសន្ធិ ... ។ ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលមិន មានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ វិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធទាំងឡាយ ជាវិបាកដែលមិនមានវិតក្ក មាន ត្រឹមតែវិចារ ។ ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មាន ត្រឹមតែវិចារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធទាំងឡាយដែល ប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យវិតក្ក ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិន មានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើប

កើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី វិចារក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ជាវិបាកដែលមិនមានវិតក្ក មានត្រឹមតែវិចារ ។

[ ៧៥ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ខន្ធ ៣ អាស្រ័យខន្ធ ១ ជាវិបាកដែលមិនមានវិតក្ក មិនមានវិចារ ។ ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវិចារ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវិចារ ដែលជាវិបាក ។ ( ធម៌ ) ៧ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ។

[ ៧៦ ] អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ។ សេចក្តីបង្រួញ ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើត

ឡើង ... ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារៈផង អាស្រ័យខន្ធ ១ ជាវិបាក ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ។ សេចក្តីបង្រួញ ។

[ ៧៧ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ និងនឧបនិស្សយប្បច្ច័យ ... ( សេចក្តីអធិប្បាយ ) ប្រហែលគ្នានឹងនអារម្មណប្បច្ច័យដែរ ។

[ ៧៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនបុរេ-ជាតប្បច្ច័យ មានវារៈ ៧ ។

[ ៧៩ ] ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺអាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងអរូបភព ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្កក្នុងអរូបភព ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មិនមាន

វិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺវិចារ អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងអរូបកព ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ចិត្តសមុដ្ឋានរូប អាស្រ័យវិតក្ក ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី កដត្តារូបក្តី អាស្រ័យវិតក្ក ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ ក្តី វិចារក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងអរូបកព ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៨០ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងអរូបកព ។បេ។ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ចិត្តសមុដ្ឋានរូប អាស្រ័យវិចារ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលមិនមាន

វិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវិចារ ក្នុងអរូបភព ក្នុងខណៈនៃបដិសន្ធិ ... ។ សេចក្តីបង្រួញ ។

[ ៨១ ] ( ធម៌ ) ៧ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងអរូបភព ក្នុងខណៈនៃបដិសន្ធិ ... ។ សេចក្តីបង្រួញ ។ ធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារៈក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារៈក្តី អាស្រ័យធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារៈផង ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារៈផង ទើបកើតឡើង ។ សេចក្តីបង្រួញ ។ អរូបសុទ្ធយ៉ាងណា ឯអរូបធម៌ទាំងឡាយ បណ្ឌិតគប្បីធ្វើយ៉ាងនោះ ក្នុងនបុរេជាតមូលកៈ ក្នុងខណៈនៃបដិសន្ធិដែរ ។ ព្រោះនបច្ឆាជាតប្បច្ច័យ និងនអាសេវនប្បច្ច័យ ។

[ ៨២ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែល

មិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺអាស្រ័យខន្ធ ១ ជាវិបាកដែលមិនមានវិតក្ក មានត្រឹមតែវិចារ ។ សេចក្តីបង្រួញ ។

[ ៨៣ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺអាស្រ័យខន្ធ ១ ជាវិបាកដែលមិនមានវិតក្ក មិនមានវិចារ ។ សេចក្តីបង្រួញ ។

[ ៨៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ។

[ ៨៥ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ។ ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារ អាស្រ័យវិតក្ក ។

[ ៨៦ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលមិន

មានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនា ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ពាហិររូប ... អាហារសមុដ្ឋានរូប ... អាស្រ័យមហាភូត ១ ដែលមានរដូវជាសមុដ្ឋាន ។ ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវិចារ ។

[ ៨៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យខន្ធទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ។

[ ៨៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ។

[ ៨៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះ

នវិបាកប្បច្ច័យ ។ សេចក្តីបង្រួញ ។ ព្រោះនអាហារប្បច្ច័យ ពាហិររូប ... ឧតុសមុដ្ឋានរូប ។បេ។ ព្រោះនឥន្ទ្រិយប្បច្ច័យ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... រូបជីវិតិន្ទ្រិយ អាស្រ័យមហាភូតទាំងឡាយរបស់ពួកអសញ្ញសត្វ ។ ខន្ធ ១ ដែលប្រទូំដោយបញ្ចវិញ្ញាណ ព្រោះនឈានប្បច្ច័យ ។បេ។ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... របស់ពួកអសញ្ញសត្វ ... ។ ( ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារមួយអន្ទើដោយវិបាក ក្នុងនអាសេវនមូលកៈ បណ្ឌិតកាលដឹង គប្បីធ្វើឲ្យប្រហែលគ្មានទីងនបុរេជាតប្បច្ច័យដែរ ។ ម្យ៉ាងទៀត វិបាក បណ្ឌិតកាលដឹងនូវធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ថាជាធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ គប្បីសម្តែងផងចុះ ) ... ព្រោះនមគ្គប្បច្ច័យ និងនសម្បយុត្តប្បច្ច័យ ... ។

[ ៩០ ] ... ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងអរូប ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺវិតក្កអាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងអរូប ។ ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្តី វិតក្កក្តី

អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងអរូប ខន្ធ ២ ក្តី វិតក្កក្តី អាស្រ័យខន្ធ ២ ។

[ ៩១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងអរូប ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យវិតក្ក ក្នុងអរូប ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺវិចារ អាស្រ័យខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងអរូប ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ ក្តី វិចារក្តី អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងអរូប ខន្ធ ២ ក្តី វិចារក្តី អាស្រ័យខន្ធ ២ ។

[ ៩២ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងអរូប ខន្ធ

២ អាស្រ័យខន្ធ ២ ពាហិររូប ... អាហារសមុដ្ឋានរូប ... ឧតុសមុដ្ឋានរូប ... អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យវិចារ ក្នុងអរូប ។

[ ៩៣ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អាស្រ័យធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងអរូប ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិចារផង ។

[ ៩៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អាស្រ័យធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ក្នុងអរូប ខន្ធ ២ អាស្រ័យខន្ធ ២ ផង វិតក្កផង ។

[ ៩៥ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ អាស្រ័យធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះនោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ ។

[ ៩៦ ] វារៈ ៣៣ ក្នុងនហេតុប្បច្ច័យ វារៈ ៧ ក្នុងនអារម្មណប្បច្ច័យ

វារៈ ៣៧ ក្នុងនអធិបតិប្បច្ច័យ វារៈ ៧ ក្នុងនអនន្តរប្បច្ច័យ វារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ វារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ វារៈ ៧ ក្នុងនឧបនិស្សយប្បច្ច័យ វារៈ ៣៧ ក្នុងនបុរេជាតប្បច្ច័យ វារៈ ៣៧ ក្នុងនបច្ឆាជាតប្បច្ច័យ វារៈ ៣៧ ក្នុងនអាសេវនប្បច្ច័យ វារៈ ៧ ក្នុងនកម្មប្បច្ច័យ វារៈ ២០ ក្នុងនវិបាកប្បច្ច័យ វារៈ ១ ក្នុងនអាហារប្បច្ច័យ វារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ វារៈ ១ ក្នុងនឈានប្បច្ច័យ វារៈ ៣៣ ក្នុងនមគ្គប្បច្ច័យ វារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ វារៈ ១១ ក្នុងនវិប្បយុត្តប្បច្ច័យ វារៈ ៧ ក្នុងនោនត្ថិប្បច្ច័យ វារៈ ៧ ក្នុងនោវិគតប្បច្ច័យ ។ ការរាប់នូវបច្ចនីយៈ ក្នុងកុសលត្តិកៈយ៉ាងណា បណ្ឌិតគប្បីរាប់យ៉ាងនេះដែរ ។

## បច្ចនីយ ចប់

[ ៩៧ ] វារៈ ៧ ក្នុងនអារម្មណប្បច្ច័យ ព្រោះហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ការរាប់នូវអនុលោមបច្ចនីយៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

[ ៩៨ ] វារៈ ១៤ ក្នុងអារម្មណប្បច្ច័យ ព្រោះនហេតុប្បច្ច័យ ។ សេចក្តីបង្រួញ ។ ការរាប់នូវបច្ចនីយានុលោម ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ ចប់

ឯសហជាតវារៈ បណ្ឌិតគប្បីធ្វើឲ្យប្រហែលគ្នានឹងបដិច្ចវារៈផងចុះ ។

## បច្ចយវារៈ

[ ៩៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ នឹងខន្ធ ២ ... មានបញ្ហា ៧ ។ ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ មានបញ្ហា ៥ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ១០០ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ( ចិត្តសមុដ្ឋានរូប ) ពឹងផ្អែកនឹងខន្ធ ២ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងវិចារ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ វិចារ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ... ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ... ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងវិចារ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងវត្ថុ វិតក្ក ពឹងផ្អែកនឹង

វត្ថុ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ១០១ ] ធម៌ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្កៈ មិនមានវិចារ ទើបកើតឡើង ... ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្កៈ មិនមានវិចារ ... ខន្ធទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងវិចារ ខន្ធទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ វិតក្កៈ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ខន្ធទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី វិចារក្តី ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្កៈ មិនមានវិចារ ... ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី វិតក្កក្តី ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្កៈ មិនមានវិចារ ... ខន្ធទាំងឡាយ ដែលប្រកបដោយ

វិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ១០២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ។បេ។ បញ្ហា ៧ បណ្ឌិតគប្បីធ្វើក្នុងខណៈនៃបដិសន្ធិដែលប្រព្រឹត្តទៅក្នុងបឋមឧទាហរណ៍ចុះ ។

[ ១០៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងវិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ

ផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង មហាភូតទាំងឡាយផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងវិតក្កផង មហាភូតទាំងឡាយផង វិចារ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង វារៈខន្ធ ៤ ក្នុងខណៈនៃបដិសន្ធិ យ៉ាងនេះឯង ។

[ ១០៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ... ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងវិតក្កផង វត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងវិតក្កផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ... ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១

ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ខន្ធ ៣ ពឹងផ្អែកនឹង ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង មហាភូត ទាំងឡាយផង ខន្ធ ៣ ក្តី វិចារក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ។

បវត្តិប្បដិសន្ធិ ក្នុងតំណដ៏សេសទាំងពីរ បណ្ឌិតគប្បីឲ្យពិស្តារចុះ ។

## ហេតុប្បច្ច័យ ចប់

បច្ចយវារៈ បណ្ឌិតកាលរំពឹងនូវហេតុប្បច្ច័យរួចហើយ គប្បីសម្តែងឲ្យ ពិស្តារផងចុះ ។

ការរាប់នូវបដិច្ចវារៈ យ៉ាងណា ( ឯបច្ចយវារៈ ) បណ្ឌិត គប្បីរាប់ យ៉ាងនោះដែរ ។

វារៈ ៣៧ ក្នុងអធិបតិប្បច្ច័យ វារៈ ២១ ក្នុងបុរេជាតប្បច្ច័យ និង អាសេវនប្បច្ច័យនេះ ជាសេចក្តីប្លែកគ្នា ក្នុងបច្ចយវារៈ នេះ ។

[ ១០៥ ] បញ្ហា ៣៣ ក្នុងនហេតុប្បច្ច័យ ក្នុងបច្ចនីយៈ មោហៈ ៧ ក្នុងឋាន ៧ បណ្ឌិត គប្បីសើរើឡើងចុះ ។ ចិត្តសមុដ្ឋាន ៧ បណ្ឌិតគប្បី សើរើឡើង ក្នុងនអារម្មណប្បច្ច័យ ក្នុងមូលប្បទេសទាំងឡាយតែម្យ៉ាងចុះ ។ បញ្ហា ៧ មានធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារជាមូល បណ្ឌិត គប្បីធ្វើក្នុងនអធិបតិប្បច្ច័យផងចុះ ។

[ ១០៦ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាវិបាក ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ... ។ នឹងធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... ។ បញ្ហា ៥ បណ្ឌិតគប្បីធ្វើឲ្យដូចជាក្នុងបដិច្ចន័យដែរ ។

[ ១០៧ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ... គឺអធិបតិធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ជាវិបាកដែលមិនមានវិតក្ក មិនមានវិចារ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងវិចារ ដែលជាវិបាក គឺអធិបតិធម៌ដែលមិនមានវិតក្ក មិនមានវិចារ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយ ជាវិបាកដែលមិនមានវិតក្ក មិនមានវិចារ ក្តី វិចារក្តី ពឹងផ្អែកនឹងវត្ថុ ។បេ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្ក មិនមានវិចារ ... អធិបតិ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្ក មិនមានវិចារ ... គឺអធិបតិធម៌ ដែលមិន

មានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងវិចារ គឺអធិបតិធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងវត្ថុ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងវិចារ ដែលជាវិបាក ខន្ធទាំងឡាយជាវិបាក ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ... ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ... ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងវិចារ ដែលជាវិបាក ខន្ធទាំងឡាយជាវិបាកដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ វិតក្ក ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ខន្ធទាំងឡាយ ជាវិបាកដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្ក មិនមានវិចារ ... ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ពឹងផ្អែក

នឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ... ។ នេះជាតំណាទី ១ ចប់សព្វគ្រប់ប៉ុណ្ណោះឯង ។

[ ១០៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្កមិនមានវិចារផង ទើបកើតឡើង ... ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្កប្រកបដោយវិចារ ពឹងផ្អែកនឹងវិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ... គឺអធិបតិធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង អធិបតិធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងខន្ធទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ជាវិបាក ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ពឹងផ្អែកនឹងខន្ធ ១ ជាវិបាកដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ... ។ បញ្ហា ៥ បណ្ឌិតគប្បីធ្វើផងចុះ ។ វត្ថុដែលមិនមានវិតក្ក មានត្រឹមតែវិចារ មកក្នុងទីណា វិបាក បណ្ឌិតគប្បីធ្វើក្នុងទីនោះចុះ ។ បញ្ហា ៣៧ បណ្ឌិតគប្បីធ្វើ ក្នុងនអធិបតិមូលកៈចុះ ។ នអនន្តរប្បច្ច័យក្តី នសមនន្តរប្បច្ច័យក្តី នអញ្ញមញ្ញប្បច្ច័យក្តី នឧបនិស្សយប្បច្ច័យក្តី សុទ្ធតែមានបញ្ហារូប ៧ ដូចគ្នា បញ្ហា ៣៧ ក្នុងនបុរេជា-

តប្បច្ច័យ ប្រហែលគ្នានឹងបដិច្ចវារៈ និងបច្ចនីយៈដែរ ។ បញ្ហា ៣៧ ក្នុងនបច្ឆាជាតប្បច្ច័យ ។ ក្នុងនអាសេវនប្បច្ច័យសោត ក៏ប្រហែលគ្នាដែរ ។ ឯធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ មកក្នុងបច្ច័យណា វិបាកទាំងឡាយ បណ្ឌិតគប្បីធ្វើក្នុងបច្ច័យនោះចុះ ។

[ ១០៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... ព្រោះនកម្មប្បច្ច័យ គឺចេតនា ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ។ ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... ចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ។ ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្ក មិនមានវិចារ ... ចេតនាដែលមិនមានវិតក្ក មិនមានវិចារ ។ បណ្ឌិតគប្បីធ្វើឲ្យពេញគ្រប់គ្រាន់ផងចុះ ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... ចេតនា ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... ចេតនា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងវិចារ ចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងវត្ថុ ។

[ ១១០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ចេតនាប្រកបដោយវិតក្ក ប្រកបដោយវិចារ

ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិត្តផង ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងវិតក្កផង វិត្តផង ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ចេតនា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិត្តផង ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ... ចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ។

[ ១១១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ ចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកប

ដោយវិចារផង វិតក្កផង វត្ថុផង ។

[ ១១២ ] បញ្ហា ៣៧ បណ្ឌិតគប្បីធ្វើ ក្នុងនវិបាកប្បច្ច័យ ។ នអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ នសម្បយុត្តប្បច្ច័យ នវិប្បយុត្តប្បច្ច័យ នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ១១៣ ] វារៈ ៣៣ ក្នុងនហេតុប្បច្ច័យ វារៈ ៧ ក្នុងនអារម្មណប្បច្ច័យ វារៈ ៣៧ ក្នុងនអធិបតិប្បច្ច័យ វារៈ ៧ ក្នុងនអនន្តរប្បច្ច័យ ក្នុងនសមនន្តរប្បច្ច័យ ក្នុងនអញ្ញមញ្ញប្បច្ច័យ និងក្នុងនឧបនិស្សយប្បច្ច័យ វារៈ ៣៧ ក្នុងនបុរេជាតប្បច្ច័យ ក្នុងនបច្ឆាជាតប្បច្ច័យ និងក្នុងនអាសេវនប្បច្ច័យ វារៈ ១១ ក្នុងនកម្មប្បច្ច័យ វារៈ ៣៧ ក្នុងនវិបាកប្បច្ច័យ វារៈ ១ ក្នុងនអាហារប្បច្ច័យ វារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ វារៈ ១ ក្នុងនឈានប្បច្ច័យ វារៈ ៣៣ ក្នុងនមគ្គប្បច្ច័យ វារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ វារៈ ១១ ក្នុងនវិប្បយុត្តប្បច្ច័យ វារៈ ៧ ក្នុងនោនត្ថិប្បច្ច័យ វារៈ ៧ ក្នុងនោវិគតប្បច្ច័យ ។

បច្ចយវារៈ ចប់

ឯនិស្សយប្បច្ច័យ មិនផ្សេងគ្នាទេ ។

## សំសដ្ឋវារៈ

[ ១១៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ច្រឡំដោយ

ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡំដោយខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ប្រឡំដោយធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... វិតក្ក ប្រឡំដោយខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ។បេ។ ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ប្រឡំដោយធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... ខន្ធ ៣ ក្តី វិតក្កក្តី ប្រឡំដោយខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ។បេ។

[ ១១៥ ] ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ប្រឡំដោយធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡំដោយខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ប្រឡំដោយធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ប្រឡំដោយវិតក្ក ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ ប្រឡំដោយធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... វិចារ ប្រឡំដោយខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ វិចារ ប្រឡំដោយខន្ធទាំងឡាយ

ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ប្រទ្បំដោយធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... ខន្ធ ៣ ក្តី វិចារក្តី ប្រទ្បំដោយខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មិនមានវិចារ ប្រទ្បំដោយធម៌ដែលមិនមានវិតក្ក មិនមានវិចារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ខន្ធ ៣ ប្រទ្បំដោយខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ប្រទ្បំដោយខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ប្រទ្បំដោយធម៌ដែលមិនមានវិតក្ក មិនមានវិចារ ... ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ប្រទ្បំដោយវិចារ ប្រទ្បំដោយវិចារក្នុងខណៈនៃបដិសន្ធិ ។

[ ១១៦ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ប្រទ្បំដោយធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... ខន្ធ ៣ ប្រទ្បំដោយខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ខន្ធ ២ ។បេ។ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ប្រទ្បំដោយធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ប្រទ្បំដោយខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ខន្ធ ២ ផង វិតក្ក

ផង ក្នុងខណៈនៃបដិសន្ធិ ... ។ បច្ច័យទាំងអស់ បណ្ឌិតកាលយល់តាមនូវហេតុប្បច្ច័យ គប្បីឲ្យពិស្តារផងចុះ ។

[ ១១៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១១ ក្នុងបច្ច័យទាំងអស់ មានវារៈ ១១ គឺក្នុងអារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

**អនុលោម ចប់**

បណ្ឌិតកាលមិនកាន់ប្រឡំ គប្បីធ្វើនូវបច្ចនីយៈផងចុះ ។

[ ១១៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៦ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១១ ក្នុងនកម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៦ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១១ ។

**បច្ចនីយៈ ចប់**

ឯវារៈ ២ ក្រៅនេះ បណ្ឌិតគប្បីឲ្យពិស្តារចុះ ។

ទាំងសម្បយុត្តវារៈ បណ្ឌិតក៏គប្បីឲ្យពិស្តារផងដែរ ។

**សំសដ្ឋវារៈ ចប់**

## បញ្ហាវារៈ

[ ១១៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ១២០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្ក ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ១២១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃចិត្តសមុដ្ឋានរូបទាំងឡាយ ដោយហេតុប្បច្ច័យ ពួកហេតុដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ជាបច្ច័យនៃកដត្តារូបទាំងឡាយ ដោយហេតុប្បច្ច័យ ។

[ ១២២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយហេតុប្បច្ច័យ គឺពួកហេតុដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង ចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយហេតុប្បច្ច័យ ពួកហេតុ ដែលប្រកបដោយ

វិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង កដត្តារូបទាំងឡាយផង ដោយហេតុប្បច្ច័យ ។

[ ១២៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយហេតុប្បច្ច័យ គឺពួកហេតុដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្កផង ចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយហេតុប្បច្ច័យ ពួកហេតុដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ជាបច្ច័យនៃវិតក្កផង កដត្តារូបទាំងឡាយផង ដោយហេតុប្បច្ច័យ ។

[ ១២៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយហេតុប្បច្ច័យ គឺពួកហេតុដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង វិតក្កផង ដោយហេតុប្បច្ច័យ ។បេ។ ពួកហេតុ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង វិតក្កផង ដោយហេតុប្បច្ច័យ ។

[ ១២៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង

ដោយហេតុប្បច្ច័យ គឺពួកហេតុដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង វិតក្កផង ចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយហេតុប្បច្ច័យ ពួកហេតុដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង វិតក្កផង កដត្តារូបទាំងឡាយផង ដោយហេតុប្បច្ច័យ ។

[ ១២៦ ] ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដោយហេតុប្បច្ច័យ ពួកហេតុដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដោយហេតុប្បច្ច័យ ។

[ ១២៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិចារផង ចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយហេតុប្បច្ច័យ ពួកហេតុដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ជាបច្ច័យនៃវិចារផង កដត្តារូបទាំងឡាយផង ដោយហេតុប្បច្ច័យ ។

[ ១២៨ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយហេតុប្បច្ច័យ គឺពួកហេតុដែលមិនមានវិតក្ក មានត្រឹមតែ

វិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង វិចារផង ចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយហេតុប្បច្ច័យ ពួកហេតុដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង វិចារផង កដត្តារូបទាំងឡាយផង ដោយហេតុប្បច្ច័យ ។

[ ១២៩ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង ចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយហេតុប្បច្ច័យ ពួកហេតុ ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងខណៈនៃបដិសន្ធិ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង កដត្តារូបទាំងឡាយផង ដោយហេតុប្បច្ច័យ ។

[ ១៣០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយពិចារណានូវកុសលនោះ ពិចារណានូវកុសលទាំងឡាយ ដែលខ្លួនសន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... ចេញអំពីមគ្គ ... ចេញអំពីផល ហើយពិចារណានូវផល ព្រះអរិយៈទាំងឡាយ ពិចារណានូវកិលេសទាំងឡាយ ដែលលះបង់ហើយ ពិចារណានូវកិលេសទាំងឡាយ ដែលសង្កត់សង្កិនហើយ ដឹងនូវកិលេសទាំងឡាយដែលធ្លាប់សន្សំទុកមក ក្នុងកាលមុន ពិចារណាឃើញច្បាស់នូវខន្ធទាំងឡាយ

ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអររីករាយ រាគៈប្រារព្ធនូវខន្ធនោះ ទើបកើតឡើង ទោមនស្សកើតឡើង ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ប្រារព្ធនូវខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ។

[ ១៣១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយពិចារណានូវកុសលនោះ វិតក្ក ប្រារព្ធនូវកុសលនោះ ទើបកើតឡើង ពិចារណានូវកុសលទាំងឡាយ ដែលសន្សំហើយ ក្នុងកាលមុន ចេញចាកឈាន ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារៈ ... ចេញចាកមគ្គ ... ចេញចាកផលហើយពិចារណានូវផល វិតក្កប្រារព្ធផលនោះ ទើបកើតឡើង ព្រះអរិយៈទាំងឡាយ ពិចារណានូវកិលេសទាំងឡាយ ដែលលះបង់ហើយ ពិចារណានូវកិលេសទាំងឡាយ ដែលសង្កត់សង្កិនហើយ ដឹងនូវកិលេសទាំងឡាយដែលធ្លាប់សន្សំមក ក្នុងកាលមុន ពិចារណាឃើញច្បាស់នូវខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ វិតក្កប្រារព្ធនូវខន្ធនោះ ទើបកើតឡើង វិតក្កប្រារព្ធនូវខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ។

[ ១៣២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ដឹងនូវចិត្តនៃបុគ្គលអ្នកព្រមព្រៀងដោយចិត្ត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយចេតោបរិយញ្ញាណ ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ប្រារព្ធនូវខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ។

[ ១៣៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយពិចារណានូវកុសលនោះ ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ប្រារព្ធនូវកុសលនោះ ទើបកើតឡើង ពិចារណានូវកុសលទាំងឡាយ ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ចេញអំពីឈានដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... អំពីមគ្គ ... អំពីផល ... ហើយពិចារណានូវផល ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ប្រារព្ធនូវផលនោះ ទើបកើតឡើង ព្រះអរិយៈទាំងឡាយ ពិចារណានូវកិលេសទាំងឡាយ

ដែលលះបង់ហើយ ពិចារណានូវកិលេសទាំងឡាយ ដែលសង្កត់សង្កិន ហើយ ដឹងនូវកិលេសទាំងឡាយ ដែលសន្សំទុកមកក្នុងកាលមុន ពិចារណាឃើញច្បាស់នូវខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ទើបត្រេកអរ រីករាយ ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ប្រារព្ធនូវខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ទើបកើតឡើង ។

[ ១៣៤ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអារម្មណប្បច្ច័យ គឺព្រះអរិយ-បុគ្គល ចេញចាកឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... ចាកមគ្គ ... ចាកផល ... ហើយពិចារណានូវផល វិតក្កប្រារព្ធនូវផលនោះ ទើបកើតឡើង ពិចារណាឃើញច្បាស់នូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ វិតក្កប្រារព្ធនូវខន្ធនោះ ទើបកើតឡើង វិតក្កប្រារព្ធនូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ទើបកើតឡើង ។

[ ១៣៥ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអារម្មណប្បច្ច័យ គឺ

( ពួកព្រះអរិយបុគ្គល ) ចេញអំពីឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... អំពីមគ្គ ... អំពីផល ... ហើយពិចារណានូវផល ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ប្រារព្ធនូវផលនោះ ទើបកើតឡើង ពិចារណាឃើញច្បាស់នូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអររីករាយ រាគៈប្រារព្ធនូវខន្ធទាំងនោះ ទើបកើតឡើង ។បេ។ ទោមនស្សកើតឡើង ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ប្រារព្ធនូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ទើបកើតឡើង ។បេ។

[ ១៣៦ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ដឹងនូវចិត្តនៃបុគ្គលអ្នកព្រមព្រៀងដោយចិត្ត ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយចេតោបរិយញ្ញាណ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ប្រារព្ធនូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ទើបកើតឡើង ។

[ ១៣៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មាន

ត្រឹមតែវិចារផង ដោយអារម្មណប្បច្ច័យ គឺ ( ព្រះអរិយបុគ្គល ) ចេញអំពីឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... ចាកមគ្គ ... ចាកផល ... ហើយពិចារណានូវផល ... ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ប្រារព្ធនូវផលនោះ ទើបកើតឡើង ពិចារណាឃើញច្បាស់នូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ប្រារព្ធនូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ទើបកើតឡើង ។

[ ១៣៨ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអារម្មណប្បច្ច័យ គឺព្រះនិព្វានជាបច្ច័យនៃមគ្គ និងផល ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយអារម្មណប្បច្ច័យ ( បុគ្គល ) ឃើញនូវរូបដោយទិព្វចក្ខុ ឮនូវសំឡេងដោយទិព្វសោតធាតុ ដឹងនូវចិត្តនៃបុគ្គលអ្នកព្រមព្រៀងដោយចិត្ត ដែលមិនមានវិតក្ក មិនមានវិចារ ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ ជាបច្ច័យនៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ដោយអារម្មណប្បច្ច័យ រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ខន្ធទាំង

ឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និង អនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមាន វិតក្ក មិនមានវិចារ ប្រារព្ធនូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមាន វិចារផង វិចារផង ទើបកើតឡើង ។

[ ១៣៩ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែល ប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអារម្មណប្បច្ច័យ គឺព្រះអរិយ- បុគ្គលទាំងឡាយ ចេញចាកឈាន ដែលមិនមានវិតក្ក មិនមានវិចារ ... ចាកមគ្គ ... ចេញចាកផល ហើយពិចារណានូវផល ខន្ធទាំងឡាយ ដែល ប្រកបដោយវិតក្ក ប្រកបដោយវិចារ ប្រារព្ធនូវផលនោះ ទើបកើតឡើង ព្រះអរិយបុគ្គលទាំងឡាយ ពិចារណានូវព្រះនិព្វាន ព្រះនិព្វានជាបច្ច័យនៃ ការពិចារណានូវគោត្រភូ និងវោទាន: នូវមគ្គ និងផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអារម្មណប្បច្ច័យ ( បុគ្គល ) ពិចារណាឃើញ ច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ទោមនស្ស កើតឡើង ( ពិចារណា ឃើញច្បាស់ ) នូវសោតៈ ... ឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ វត្ថុ ... នូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ រាគៈប្រារព្ធនូវខន្ធនោះ ទើបកើតឡើង ទោមនស្សកើតឡើង ខន្ធ

ទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ប្រារព្ធនូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ទើបកើតឡើង ។បេ។

[ ១៨០ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអារម្មណប្បច្ច័យ គឺព្រះអរិយបុគ្គលទាំងឡាយ ចេញអំពីឈាន ដែលមិនមានវិតក្ក មិនមានវិចារ ... អំពីមគ្គ ... អំពីផល ... ហើយពិចារណានូវផល វិតក្ក ប្រារព្ធនូវផលនោះ ទើបកើតឡើង ព្រះអរិយបុគ្គលទាំងឡាយ ពិចារណានូវព្រះនិព្វាន ព្រះនិព្វានជាបច្ច័យនៃមគ្គ និងផល ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ដោយអារម្មណប្បច្ច័យ ( បុគ្គល ) ពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ... នូវវត្ថុ ... នូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន រមែងត្រេកអរ រីករាយ វិតក្ក ប្រារព្ធនូវខន្ធនោះ ទើបកើតឡើង វិតក្កប្រារព្ធនូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ទើបកើតឡើង ។

[ ១៨១ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអារម្មណប្បច្ច័យ គឺព្រះនិព្វានជាបច្ច័យនៃមគ្គ និងផល ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអារម្មណប្បច្ច័យ ។

[ ១៤២ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអារម្មណប្បច្ច័យ គឺព្រះអរិយបុគ្គលទាំងឡាយ ចេញអំពីឈាន ដែលមិនមានវិតក្ក មិនមានវិចារ ... អំពីមគ្គ ... ចេញអំពីផលហើយពិចារណានូវផល ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ប្រារព្ធនូវផលនោះ ទើបកើតឡើង ព្រះអរិយបុគ្គលទាំងឡាយ ពិចារណានូវព្រះនិព្វាន ព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទានៈ និងវិតក្កផង នៃមគ្គដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ និងវិតក្កផងនៃផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ និងវិតក្កផង នៃអាវជ្ជនៈ និងវិតក្កផង ដោយអារម្មណប្បច្ច័យ ( បុគ្គល ) ពិចារណាឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ពិចារណាឃើញច្បាស់នូវសោតៈ ... ។បេ។ នូវផោដ្ឋព្វៈ នូវវត្ថុ ... នូវខន្ធទាំងឡាយដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ប្រារព្ធនូវខន្ធទាំងនោះ ទើបកើតឡើង ។

[ ១៤៣ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយ ប្រកបដោយវិតក្ក

ប្រកបដោយវិចារ ប្រារព្ធនូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ទើបកើតឡើង ។

[ ១៨៤ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអារម្មណប្បច្ច័យ គឺវិតក្ក ប្រារព្ធនូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ទើបកើតឡើង ។

[ ១៨៥ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ប្រារព្ធនូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ទើបកើតឡើង ។

[ ១៨៦ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ប្រារព្ធនូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ទើបកើតឡើង ។

[ ១៨៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែល មិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអារម្មណបច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកប ដោយវិតក្ក ប្រកបដោយវិចារ ប្រារព្ធនូវខន្ធទាំងឡាយ ដែលប្រកបដោយ វិតក្ក ប្រកបដោយវិចារផង វិតក្កផង ទើបកើតឡើង ។

[ ១៨៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែល មិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មាន ត្រឹមតែវិចារ ដោយអារម្មណបច្ច័យ គឺវិតក្ក ប្រារព្ធនូវខន្ធទាំងឡាយ ដែល ប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ទើបកើតឡើង ។

[ ១៨៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែល មិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិន មានវិចារ ដោយអារម្មណបច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃចេតោបរិយញ្ញាណ បុព្វេនិវា-សានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអា-រម្មណបច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ប្រារព្ធនូវ ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ទើបកើតឡើង ។

[ ១៩០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែល មិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក

ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ប្រារព្ធនូវខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ទើបកើតឡើង ។

[ ១៥១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ ( បុគ្គល ) ឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើកុសលនោះ ឲ្យជាទីគោរព ហើយពិចារណា ធ្វើកុសលទាំងឡាយ ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ឲ្យជាទីគោរព ហើយពិចារណា ចេញហើយអំពីឈាន ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... អំពីមគ្គ ... អំពីផល ... ធ្វើផល ឲ្យជាទីគោរព ហើយពិចារណា ធ្វើខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ធ្វើខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺធម៌ជាអធិបតិ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដោយអធិបតិប្បច្ច័យ ។

[ ១៥២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ ( បុគ្គល ) ឲ្យ

ទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើកុសលនោះ ឲ្យជាទីគោរពហើយពិចារណា វិតក្ក ធ្វើកុសលនោះ ឲ្យជាទីគោរព ទើបកើតឡើង ធ្វើកុសលទាំងឡាយដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ឲ្យជាទីគោរព ហើយពិចារណាចេញហើយអំពីឈាន ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... ចេញហើយអំពីមគ្គ ... ចេញអំពីផល ធ្វើផល ឲ្យជាទីគោរព ហើយពិចារណាវិតក្ក ធ្វើផលនោះ ឲ្យជាទីគោរព ទើបកើតឡើង ( បុគ្គល ) ធ្វើខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ វិតក្ក ធ្វើខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ។ ឯសហជាតាធិបតិ គឺធម៌ជាអធិបតិដែលប្រកបដោយវិតក្ក ប្រកបដោយវិចារជាបច្ច័យនៃវិតក្ក ដោយអធិបតិប្បច្ច័យ ។

[ ១៥៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺធម៌ជាអធិបតិ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃចិត្តសមុដ្ឋានរូបទាំងឡាយ ដោយអធិបតិប្បច្ច័យ ។

[ ១៥៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺធម៌ជាអធិបតិ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង ចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយអធិប-

តិប្បច្ច័យ ។

[ ១៥៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្កមិនមានវិចារផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺធម៌ជាអធិបតិ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្កផងចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយអធិបតិប្បច្ច័យ ។

[ ១៥៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ ( បុគ្គល ) ឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើកុសលនោះ ឲ្យជាទីគោរព ហើយពិចារណាខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ទើបកើតឡើង ( បុគ្គល ) ធ្វើកុសលទាំងឡាយដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ឲ្យជាទីគោរព ហើយពិចារណាចេញអំពីឈាន ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... អំពីមគ្គ ... អំពីផល ... ធ្វើផលឲ្យជាទីគោរព ហើយពិចារណា ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ធ្វើផលនោះ ឲ្យជាទីគោរព ទើបកើតឡើង ( បុគ្គល ) ធ្វើខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ខន្ធទាំងឡាយដែល

ប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ធ្វើខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ។ ឯសហជាតាធិបតិ គឺ ( ធម៌ ) ជាអធិបតិដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង វិតក្កផង ដោយអធិបតិប្បច្ច័យ ។

[ ១៥៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្កមានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺ ( ធម៌ ) ជាអធិបតិ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង វិតក្កផង ចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយអធិបតិប្បច្ច័យ ។

[ ១៥៨ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ ( បុគ្គល ) ចេញហើយអំពីឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... អំពីមគ្គ ... អំពីផល ធ្វើផលឲ្យជាទីគោរព ហើយពិចារណាវិតក្ក ធ្វើផលនោះ ឲ្យជាទីគោរព ទើបកើតឡើង ( បុគ្គល ) ធ្វើខន្ធទាំងឡាយ ដែលមិនមានវិតក្កមានត្រឹមតែវិចារផង វិតក្កផង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយវិតក្ក ធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ។ ឯសហជាតាធិបតិ គឺ ( ធម៌ ) ជាអធិបតិដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃ

សម្បយុត្តកក្ខន្ធទាំងឡាយ ដោយអធិបតិប្បច្ច័យ ។

[ ១៥៩ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺ ( បុគ្គល ) ចេញហើយអំពីឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អំពីមគ្គ ... អំពីផល ... ធ្វើផលឲ្យជាទីគោរព ហើយ ពិចារណាខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ធ្វើ ផលនោះ ឲ្យជាទីគោរព ទើបកើតឡើង ( បុគ្គល ) ធ្វើខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ឲ្យជាទីគោរព ហើយ ត្រេកអរ រីករាយ រាគៈ ធ្វើខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើត ឡើង ។

[ ១៦០ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអធិបតិប្បច្ច័យ បានដល់ សហ-ជាតាធិបតិ គឺ ( ធម៌ ) ជាអធិបតិដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិចារផង ចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយអធិបតិប្បច្ច័យ ។

[ ១៦១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមាន វិចារផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺ ( ធម៌ ) ជាអធិបតិដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធ ទាំងឡាយផង វិចារផង ចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយអធិប-

តិប្បច្ច័យ ។

[ ១៦២ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺ ( បុគ្គល ) ចេញហើយអំពីឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អំពីមគ្គ ... អំពីផល ... ធ្វើផលឲ្យជាទីគោរព ហើយពិចារណាខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ធ្វើនូវផលនោះ ឲ្យជាទីគោរព ទើបកើតឡើង ( បុគ្គល ) ធ្វើខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ធ្វើខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ។

[ ១៦៣ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺព្រះនិព្វាន ជាបច្ច័យនៃមគ្គ និងផល ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយអធិបតិប្បច្ច័យ ។ ឯសហជាតាធិបតិ គឺ ( ធម៌ ) ជាអធិបតិដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង ចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយអធិបតិប្បច្ច័យ ។

[ ១៦៤ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែល

ប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺព្រះអរិយបុគ្គលទាំងឡាយ ចេញហើយអំពីឈាន ដែលមិនមានវិតក្ក មិនមានវិចារ ... អំពីមគ្គ ... ចេញហើយអំពីផល ធ្វើផលឲ្យជាទីគោរព ហើយពិចារណា ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ធ្វើនូវផលនោះ ឲ្យជាទីគោរព ទើបកើតឡើង ព្រះអរិយបុគ្គលទាំងឡាយ ធ្វើព្រះនិព្វាន ឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វានជាបច្ច័យនៃគោត្រភូ និងវោទាន: នៃមគ្គ និងផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអធិបតិប្បច្ច័យ ( បុគ្គល ) ធ្វើចក្ខុ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើចក្ខុនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ធ្វើនូវសោត: ... ឃាន: ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វ: វត្ថុ ... នូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈធ្វើខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ១៦៥ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺអរិយបុគ្គលទាំងឡាយ ចេញហើយអំពីឈាន ដែលមិនមានវិតក្ក មិនមានវិចារ: ... អំពីមគ្គ ... អំពីផល ... ធ្វើផលឲ្យជាទីគោរព ហើយពិចារណា វិតក្ក ធ្វើផលនោះ ឲ្យជាទីគោរព ទើបកើតឡើង ព្រះអរិយបុគ្គលទាំងឡាយ ធ្វើព្រះនិព្វានឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វានជាបច្ច័យ

នៃមគ្គនិងផល ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ដោយអធិបតិប្បច្ច័យ ( បុគ្គល ) ធ្វើនូវចក្ខុ ... វត្ថុ ... នូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ វិតក្កធ្វើខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ។

[ ១៦៦ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺព្រះនិព្វានជាបច្ច័យនៃមគ្គ និងផល ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអធិបតិប្បច្ច័យ ។

[ ១៦៧ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺព្រះអរិយបុគ្គលទាំងឡាយ ចេញហើយអំពីឈាន ដែលមិនមានវិតក្ក មិនមានវិចារ ... អំពីមគ្គ ... អំពីផល ធ្វើផលឲ្យជាទីគោរព ហើយពិចារណា ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ធ្វើផលនោះឲ្យជាទីគោរព ទើបកើតឡើង ព្រះអរិយបុគ្គលទាំងឡាយ ធ្វើព្រះនិព្វានឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វានជាបច្ច័យនៃគោត្រភូ វោទានៈ និងវិតក្កផង មគ្គដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ និងវិតក្កផង ផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ និងវិតក្កផង ដោយអធិប-

តិប្បច្ច័យ ធ្វើចក្ខុឲ្យជាទីគោរព ។ សេចក្ដីបង្រួញ ។ ( បុគ្គលធ្វើ ) នូវវត្ថុ ... នូវខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្ដី វិតក្កក្ដី ធ្វើខន្ធនោះឲ្យជាទីគោរព ទើបកើតឡើង ។

[ ១៦៨ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្ដី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្ដី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ធ្វើខន្ធទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ឲ្យជាទីគោរព ទើបកើតឡើង ។

[ ១៦៩ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្ដី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្ដី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺវិតក្ក ធ្វើខន្ធទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ឲ្យជាទីគោរព ទើបកើតឡើង ។

[ ១៧០ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្ដី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្ដី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអធិ-

បតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ធ្វើខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ឲ្យជាទីគោរព ទើបកើតឡើង ។

[ ១៧១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្កប្រកបដោយវិចារ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ធ្វើខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ឲ្យជាទីគោរព ទើបកើតឡើង ។

[ ១៧២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺវិតក្ក ធ្វើខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ឲ្យជាទីគោរព ទើបកើតឡើង ។

[ ១៧៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្កប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ធ្វើខន្ធទាំងឡាយ ដែលប្រកប

ដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ឲ្យជាទីគោរព ទើបកើតឡើង ។

[ ១៧៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរប្បច្ច័យ ខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ វោទានៈ ( ជាបច្ច័យ ) នៃមគ្គដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ មគ្គដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ( ជាបច្ច័យ ) នៃផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ( ជាបច្ច័យ ) នៃផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អនុលោម ( ជាបច្ច័យ ) នៃផលសមាបត្តិ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរប្បច្ច័យ ។

[ ១៧៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្កក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្តដែលប្រកបដោយវិតក្ក ប្រកប

ដោយវិចារ ( ជាបច្ច័យ ) នៃឧបបត្តិចិត្ត ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ( ជាបច្ច័យ ) នៃវុដ្ឋាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង បរិកម្មនៃឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ( ជាបច្ច័យ ) នៃឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គដែលមិនមានវិតក្ក មានត្រឹមតែវិចារ វោទានៈ ( ជាបច្ច័យ ) នៃមគ្គដែលមិនមានវិតក្ក មានត្រឹមតែវិចារ អនុលោម ( ជាបច្ច័យ ) នៃផលសមាបត្តិ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ដោយអនន្តរបច្ច័យ ។

[ ១៧៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអនន្តរបច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃវិញ្ញាណ ៥ ដោយអនន្តរបច្ច័យ ចុតិចិត្តដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃឧបបត្តិចិត្តដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយអនន្តរបច្ច័យ ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវុដ្ឋាន ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង បរិកម្មនៃទុតិយជ្ឈានជាបច្ច័យនៃវិចារក្នុងទុតិយជ្ឈាន ដោយអនន្តរបច្ច័យ បរិកម្មនៃតតិយជ្ឈាន ... បរិកម្មនៃចតុត្ថជ្ឈាន ... បរិកម្មនៃអាកាសានញ្ចាយតនៈ ... បរិកម្មនៃវិញ្ញាណញ្ចាយតនៈ ... បរិកម្មនៃអាកិញ្ចញ្ញាយតនៈ ... បរិកម្មនៃនេវសញ្ញានាសញ្ញាយតនៈ ... បរិកម្មនៃទិព្វចក្ខុ ... បរិកម្ម

នៃទិព្វសោតធាតុ ... បរិកម្មនៃឥទ្ធិវិធញ្ញាណ ... បរិកម្មនៃចេតោបរិយញ្ញាណ ... បរិកម្មនៃបុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ... គោត្រភូ ( ជាបច្ច័យ ) នៃមគ្គដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង វោទាន: ( ជាបច្ច័យ ) នៃមគ្គដែលមិនមានវិតក្កមិនមានវិចារផង វិចារផង អនុលោមជាបច្ច័យនៃផលសមាបត្តិ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ ។

[ ១៧៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្កមិនមានវិចារផង ដោយអនន្តរប្បច្ច័យ គឺចុតិចិត្ត ដែលប្រកបដោយវិតក្កប្រកបដោយវិចារ ជាបច្ច័យនៃឧបបត្តិចិត្ត ដែលមិនមានវិតក្ក: មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវុដ្ឋាន: ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ បរិកម្មនៃឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង វោទាន: ( ជាបច្ច័យ ) នៃមគ្គដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង អនុលោម ជាបច្ច័យនៃផលសមាបត្តិ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ ។

[ ១៧៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអនន្តរបច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរបច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូផង វិតក្កផង អនុលោម ( ជាបច្ច័យ ) នៃវោទានៈផង វិតក្កផង គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង វោទានៈ ( ជាបច្ច័យ ) នៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង មគ្គដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃផល ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ( ជាបច្ច័យ ) នៃផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង អនុលោម ជាបច្ច័យនៃផលសមាបត្តិដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរបច្ច័យ ។

[ ១៧៩ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរបច្ច័យ គឺវិតក្កមុនៗ ជាបច្ច័យនៃវិតក្កក្រោយៗ ដោយអនន្តរបច្ច័យ ខន្ធទាំងឡាយមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរបច្ច័យ មគ្គដែលមិនមាន

វិតក្ក មានត្រឹមតែវិចារ ( ជាបច្ច័យ ) នៃផលដែលមិនមានវិតក្ក មានត្រឹមតែវិចារ ផលដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃផលដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរបច្ច័យ ។

[ ១៨០ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរបច្ច័យ គឺវិតក្កមុនៗ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរបច្ច័យ ចុតិចិត្តដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃឧបបត្តិចិត្ត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរបច្ច័យ ភវង្គៈដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃអាវជ្ជនៈ ដោយអនន្តរបច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវុដ្ឋានៈដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរបច្ច័យ ។

[ ១៨១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអនន្តរបច្ច័យ គឺពួកខន្ធមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិចារក្រោយៗ ដោយអនន្តរបច្ច័យ ចុតិចិត្តដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិតក្កក្តី ជាបច្ច័យនៃឧបបត្តិចិត្តដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយអនន្តរបច្ច័យ ពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិតក្កក្តី ជាបច្ច័យនៃវុដ្ឋានៈ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយអនន្ត-

វប្បច្ច័យ ។បេ។

[ ១៨២ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ មគ្គដែលមិនមានវិតក្ក មានត្រឹមតែវិចារ ( ជាបច្ច័យ ) នៃផលដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ផលដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃផលដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ ។

[ ១៨៣ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអនន្តរប្បច្ច័យ គឺវិតក្កមុនៗ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរប្បច្ច័យ ចុតិចិត្តដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃឧបបត្តិចិត្ត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរប្បច្ច័យ ភវង្គៈដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃអាវជ្ជនៈផង វិតក្កផង ដោយអនន្តរប្បច្ច័យ ពួកខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវុដ្ឋាន ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរប្បច្ច័យ ។

[ ១៨៤ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែល មិនមានវិតក្ក មិនមានវិចារ ដោយអនន្តរប្បច្ច័យ គឺវិចារមុនៗ ជាបច្ច័យ នៃវិចារក្រោយៗ ដោយអនន្តរប្បច្ច័យ ។បេ។ ពួកខន្ធមុនៗ ដែលមិនមាន វិតក្ក មិនមានវិចារ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមិនមានវិតក្ក មិន មានវិចារ ដោយអនន្តរប្បច្ច័យ មគ្គដែលមិនមានវិតក្ក មិនមានវិចារ ( ជាបច្ច័យ ) នៃផល ដែលមិនមានវិតក្ក មិនមានវិចារ ផលដែលមិន មានវិតក្ក មិនមានវិចារ ជាបច្ច័យនៃផល ដែលមិនមានវិតក្ក មិនមាន វិចារ ដោយអនន្តរប្បច្ច័យ នេវសញ្ញានាសញ្ញាយតនៈ ( របស់បុគ្គល ) កាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដែលមិនមានវិតក្ក មិន មានវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ ។

[ ១៨៥ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែល ប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរប្បច្ច័យ គឺចុតិចិត្តដែល មិនមានវិតក្ក មិនមានវិចារក្តី វិចារក្តី ជាបច្ច័យនៃឧបបត្តិចិត្តដែលប្រកប ដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរប្បច្ច័យ ភវង្គៈដែលមិនមាន វិតក្ក មិនមានវិចារក្តី វិចារក្តី ជាបច្ច័យនៃអាវជ្ជនៈ ដោយអនន្តរប្បច្ច័យ ពួកខន្ធ ដែលមិនមានវិតក្ក មិនមានវិចារក្តី វិចារក្តី ជាបច្ច័យនៃវុដ្ឋានៈ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរប្បច្ច័យ នេវ-សញ្ញានាសញ្ញាយតនៈរបស់បុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យនៃផល-សមាបត្តិ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរប្បច្ច័យ ។

[ ១៨៦ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរប្បច្ច័យ គឺវិចារមុនៗ ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរប្បច្ច័យ ចុតិចិត្តដែលមិនមានវិតក្ក មិនមានវិចារក្តី វិចារក្តី ជាបច្ច័យនៃឧបបត្តិចិត្ត ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ដោយអនន្តរប្បច្ច័យ ពួកខន្ធដែលមិនមានវិតក្ក មិនមានវិចារក្តី វិចារក្តី ជាបច្ច័យនៃវុដ្ឋានៈ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ដោយអនន្តរប្បច្ច័យ នេវសញ្ញានាសញ្ញាយតនៈរបស់បុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ដោយអនន្តរប្បច្ច័យ ។

[ ១៨៧ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអនន្តរប្បច្ច័យ គឺចុតិចិត្តដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃឧបបត្តិចិត្ត ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ ពួកខន្ធដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃវុដ្ឋានៈដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ នេវសញ្ញានាសញ្ញាយតនៈ របស់បុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ ។

[ ១៨៨ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអនន្តរបច្ច័យ គឺចុតិចិត្ត ដែលមិនមានវិតក្ក មិនមានវិចារក្តី វិចារក្តី ជាបច្ច័យនៃឧបបត្តិចិត្ត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរបច្ច័យ ភវង្គៈ ដែលមិនមានវិតក្ក មិនមានវិចារក្តី វិចារក្តី ជាបច្ច័យនៃអាវជ្ជនៈផង វិតក្កផង ដោយអនន្តរបច្ច័យ ពួកខន្ធ ដែលមិនមានវិតក្ក មិនមានវិចារក្តី វិចារក្តី ជាបច្ច័យនៃវុដ្ឋានៈ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរបច្ច័យ នៃនេវសញ្ញានាសញ្ញាយតនៈរបស់បុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរបច្ច័យ ។

[ ១៨៩ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរបច្ច័យ គឺចុតិចិត្ត ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃឧបបត្តិចិត្ត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរបច្ច័យ ភវង្គៈដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃអាវជ្ជនៈ ដោយអនន្តរបច្ច័យ ពួកខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃវុដ្ឋានៈ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរបច្ច័យ ។

[ ១៩០ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរប្បច្ច័យ មគ្គដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃផល ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរប្បច្ច័យ ផលដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃផលដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរប្បច្ច័យ ។

[ ១៩១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃវិចារក្រោយៗ ដោយអនន្តរប្បច្ច័យ ចុតិចិត្ត ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃឧបបត្តិចិត្ត ដែលមិនមានវិតក្ក មិនមានវិចារ ដោយអនន្តរប្បច្ច័យ ពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃវុដ្ឋានៈ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអនន្តរប្បច្ច័យ ។

[ ១៩២ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអនន្តរប្បច្ច័យ

គឺពួកខន្ធមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ មគ្គដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃផលដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ គឺផលដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃផល ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ ។

[ ១៩៣ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអនន្តរប្បច្ច័យ គឺចុតិចិត្ត ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃឧបបត្តិចិត្ត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរប្បច្ច័យ ភវង្គៈដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃអាវជ្ជនៈផង វិតក្កផង ដោយអនន្តរប្បច្ច័យ ពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃវុដ្ឋានៈ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរប្បច្ច័យ ។

[ ១៩៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយ

វិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរបច្ច័យ អនុលោមក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃគោត្រភូ អនុលោមក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃវោទាន: គោត្រភូក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ វោទាន:ក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃមគ្គដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ។បេ។ មគ្គដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃផល ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃផល ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ អនុលោមក្តី វិតក្កក្តី ជាបច្ច័យនៃផលសមាបត្តិ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអនន្តរបច្ច័យ ។

[ ១៩៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរបច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃវិតក្កក្រោយៗ ដោយអនន្តរបច្ច័យ ចុតិចិត្តដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃឧបបត្តិចិត្ត ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរបច្ច័យ ពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃវុដ្ឋាន:ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរបច្ច័យ

បរិកម្មនៃឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិតក្កក្តី ជាបច្ច័យនៃឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរបច្ច័យ គោត្រភូក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃមគ្គដែលមិនមានវិតក្ក មានត្រឹមតែវិចារ វោទាន:ក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃមគ្គ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ អនុលោមក្តី វិតក្កក្តី ជាបច្ច័យនៃផលសមាបត្តិ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអនន្តរបច្ច័យ ។

[ ១៩៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអនន្តរបច្ច័យ គឺអាវជ្ជន:ក្តី វិតក្កក្តី ជាបច្ច័យនៃបញ្ច-វិញ្ញាណ ដោយអនន្តរបច្ច័យ ចុតិចិត្តដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃឧបបត្តិចិត្ត ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយអនន្តរបច្ច័យ ពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃវុដ្ឋាន: ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយអនន្តរបច្ច័យ បរិកម្មនៃទុតិយជ្ឈានក្តី វិតក្កក្តី ជាបច្ច័យនៃទុតិយជ្ឈានផង វិចារផង ដោយអនន្តរបច្ច័យ បរិកម្មនៃតតិយជ្ឈានក្តី វិតក្កក្តី បរិកម្មនៃចតុត្ថជ្ឈានក្តី វិតក្កក្តី បរិកម្មនៃអាកា-សានញ្ចាយតន:ក្តី វិតក្កក្តី បរិកម្មនៃវិញ្ញាណញ្ចាយតន:ក្តី វិតក្កក្តី បរិកម្មនៃអាកិញ្ចញ្ញាយតន:ក្តី វិតក្កក្តី បរិកម្មនៃនេវសញ្ញានាសញ្ញាយតន:ក្តី វិតក្កក្តី បរិកម្មនៃទិព្វចក្ខុក្តី វិតក្កក្តី បរិកម្មនៃទិព្វសោតធាតុក្តី វិតក្កក្តី បរិកម្ម

នៃឥទ្ធិវិធញ្ញាណក្តី វិតក្កក្តី បរិកម្មនៃចេតោបរិយញ្ញាណក្តី វិតក្កក្តី នៃបុព្វេនិវាសានុស្សតិញ្ញាណ ។បេ។ នៃយថាកម្មូបគញ្ញាណ ។បេ។ បរិកម្មនៃអនាគតំសញ្ញាណក្តី វិតក្កក្តី គោត្រភូក្តី វិតក្កក្តី ជាបច្ច័យនៃមគ្គដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង វោទានៈក្តី វិតក្កក្តី ជាបច្ច័យនៃមគ្គដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង អនុលោមក្តី វិតក្កក្តី ជាបច្ច័យនៃផលសមាបត្តិ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ ។

[ ១៩៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអនន្តរប្បច្ច័យ គឺចុតិចិត្ត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃឧបបត្តិចិត្ត ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ ពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃវុដ្ឋានៈដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ បរិកម្មនៃឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិតក្កក្តី ជាបច្ច័យនៃឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ គោត្រភូក្តី វិតក្កក្តី ជាបច្ច័យនៃមគ្គដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ វោទានៈក្តី វិតក្កក្តី ជាបច្ច័យនៃមគ្គ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ

ផង វិចារផង អនុលោមក្តី វិតក្កក្តី ជាបច្ច័យនៃផលសមាបត្តិ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអនន្តរប្បច្ច័យ ។

[ ១៩៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអនន្តរប្បច្ច័យ គឺពួកខន្ធមុនៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកខន្ធក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរប្បច្ច័យ អនុលោមក្តី វិតក្កក្តី ជាបច្ច័យនៃគោត្រភូ និងវិតក្ក អនុលោមក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃវោទានៈ និងវិតក្ក គោត្រភូក្តី វិតក្កក្តី ជាបច្ច័យនៃមគ្គដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង វោទានៈក្តី វិតក្កក្តី ជាបច្ច័យនៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរប្បច្ច័យ មគ្គដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃផលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង អនុលោមក្តី វិតក្កក្តី ជាបច្ច័យនៃផលសមាបត្តិ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអនន្តរប្បច្ច័យ ។

[ ១៩៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យ

នៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសមនន្តរប្បច្ច័យ ។ អនន្តរប្បច្ច័យក្តី សមនន្តរប្បច្ច័យក្តី មានសេចក្តីដូចគ្នា ។

[ ២០០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ដោយសហជាតប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយសហជាតប្បច្ច័យ ខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ( ជាបច្ច័យ ) នៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ... ។

[ ២០១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយសហជាតប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្ក ដោយសហជាតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២០២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយសហជាតប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២០៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមាន

វិតក្ក មិនមានវិចារផង ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលប្រកប ដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋាន-រូបផង ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង ពួកចិត្ត-សមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ សេចក្តី បង្រួញ ។

[ ២០៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យ នៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយសហជាតប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្កផង ពួកចិត្តសមុដ្ឋានរូបផង ដោយ សហជាតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២០៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យ នៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមាន វិតក្ក មានត្រឹមតែវិចារផង ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលប្រកប ដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ផង វិតក្កផង ដោយ សហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង វិតក្កផង ដោយសហ-ជាតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២០៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យ នៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមាន វិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង

ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ផង វិតក្កផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង វិតក្កផង ចិត្តសមុដ្ឋានរូបផង ( ដោយសហជាតប្បច្ច័យ ) ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២០៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃខន្ធ ៣ ដោយសហជាតប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យនៃខន្ធ ២ ) ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២០៨ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសហជាតប្បច្ច័យ គឺវិតក្ក ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសហជាតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២០៩ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយសហជាតប្បច្ច័យ គឺពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ វិតក្កជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២១០ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិន

មានវិចារផង ដោយសហជាតប្បច្ច័យ គឺវិតក្ក ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ វិតក្កក្នុងខណៈនៃបដិសន្ធិ ... ។

[ ២១១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃខន្ធ ៣ ផង វិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង វិចារផង ពួកចិត្ត-សមុដ្ឋានរូបផង ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២១២ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង ពួកចិត្ត-សមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ វិចារ ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃខន្ធ ៣ ផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ផង ពួកកដត្តារូបផង វិចារ ( ជាបច្ច័យ ) នៃពួកកដត្តារូប ពួកខន្ធ ( ជាបច្ច័យ ) នៃវត្ថុ វត្ថុ ( ជាបច្ច័យ ) នៃពួកខន្ធ វិចារ ( ជាបច្ច័យ ) នៃវត្ថុ វត្ថុ ( ជាបច្ច័យ ) នៃវិចារ មហាភូត ១ ( ជាបច្ច័យ )

នៃមហាភូត ៣ ពួកមហាភូត នៃពួកចិត្តសមុដ្ឋានរូប ពួកកដត្តារូប ពួកឧបាទារូប ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ១ ... របស់ពួកអសញ្ញសត្វ ... ពួកមហាភូត ជាបច្ច័យនៃពួកកដត្តារូប និងពួកឧបាទារូប ដោយសហជាតប្បច្ច័យ ។

[ ២១៣ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសហជាតប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ ។

[ ២១៤ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយសហជាតប្បច្ច័យ គឺវិចារ ជាបច្ច័យនៃពួកខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយសហជាតប្បច្ច័យ វិចារ ជាបច្ច័យនៃពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ វត្ថុ ជាបច្ច័យនៃពួកខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ វត្ថុ ជាបច្ច័យនៃវិតក្ក ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ ។

[ ២១៥ ] ធម៌ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយសហជាតប្បច្ច័យ គឺវិចារ ជាបច្ច័យនៃពួកខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ

វិចារ ( ជាបច្ច័យ ) នៃពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ វត្ថុ ជាបច្ច័យនៃពួកខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតបច្ច័យ ។

[ ២១៦ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយសហជាតបច្ច័យ គឺវត្ថុជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតបច្ច័យ ។

[ ២១៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសហជាតបច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតបច្ច័យ ខន្ធ ២ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ដោយសហជាតបច្ច័យ ។

[ ២១៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយសហជាតបច្ច័យ គឺពួកខន្ធ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វត្ថុក្តី ជាបច្ច័យនៃវិតក្ក ក្នុងខណៈនៃបដិសន្ធិ ដោយ

សហជាតប្បច្ច័យ ។

[ ២១៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយសហជាតប្បច្ច័យ គឺពួកខន្ធ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយសហ-ជាតប្បច្ច័យ ពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ពួកមហាភូតក្តី ( ជាបច្ច័យ ) នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ។

[ ២២០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្កប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ផង វិតក្កផង ដោយសហជាតប្បច្ច័យ ។

[ ២២១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសហជាតប្បច្ច័យ គឺវិតក្កក្តី វត្ថុក្តី ជាបច្ច័យនៃពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ ។

[ ២២២ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិន

មានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ខន្ធ ២ ក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ២ ដោយសហជាតប្បច្ច័យ ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ២ ក្តី វិចារក្តី ( ជាបច្ច័យ ) នៃខន្ធ ២ ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ ។

[ ២២៣ ] ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយសហជាតប្បច្ច័យ គឺពួកខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប វិតក្កក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ( ជាបច្ច័យ ) នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ពួកមហាភូតក្តី ( ជាបច្ច័យ ) នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ វិតក្កក្តី ពួកមហាភូតក្តី ( ជាបច្ច័យ ) នៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វត្ថុក្តី

ជាបច្ច័យនៃវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ ។

[ ២២៤ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ ខន្ធ ៣ ក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ១ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ ខន្ធ ២ ក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ២ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ៣ ផង ពួកកដត្តារូបផង ដោយសហជាតប្បច្ច័យ ខន្ធ ២ ... ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិតក្កី ជាបច្ច័យនៃខន្ធ ៣ ផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ ខន្ធ ២ ក្តី វិតក្កី ជាបច្ច័យនៃខន្ធ ២ ផង វិចារផង ដោយសហជាតប្បច្ច័យ ។

[ ២២៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធ ៣ ដោយសហជាតប្បច្ច័យ ខន្ធ ២ ក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធ ២ ដោយសហជាតប្បច្ច័យ

ក្នុងខណៈនៃបដិសន្ធិ ។បេ។

[ ២២៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយសហជាតប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២២៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ ខន្ធ ២ ក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធ ២ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហជាតប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២២៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ ខន្ធ ២ ក្តី វិតក្កក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ដោយសហជាតប្បច្ច័យ ។

[ ២២៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយសហជាតប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយសហជាតប្បច្ច័យ ពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ពួកមហាភូតក្តី ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ ។

[ ២៣០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៣១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្ក ដោយអញ្ញមញ្ញប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៣២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺពួកខន្ធ

ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៣៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង វត្ថុផង ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៣៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអញ្ញមញ្ញប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៣៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ផង វិតក្កផង ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង វិតក្កផង ដោយអញ្ញមញ្ញប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៣៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ផង វិតក្កផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង វិតក្កផង វត្ថុផង ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៣៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃខន្ធ ៣ ដោយអញ្ញ-មញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៣៨ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺវិតក្ក ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអញ្ញមញ្ញប្បច្ច័យ ។បេ។ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៣៩ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិចារ ដោយអញ្ញមញ្ញប្បច្ច័យ

ពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ វិតក្ក ជាបច្ច័យនៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៤០ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអញ្ញមញ្ញប្បច្ច័យ គឺវិតក្ក ជាបច្ច័យនៃពួកខន្ធ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៤១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃខន្ធ ៣ ផង វិចារផង ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង វិចារផង ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃខន្ធ ៣ ផង វិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង វិចារផង វត្ថុផង ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៤២ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃខន្ធ ៣ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ

២ ជាបច្ច័យនៃខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃខន្ធ ៣ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង វត្ថុផង ដោយអញ្ញមញ្ញប្បច្ច័យ ពួកខន្ធ ( ជាបច្ច័យ ) នៃវត្ថុ វត្ថុ ជាបច្ច័យនៃពួកខន្ធ វិចារ ( ជាបច្ច័យ ) នៃវត្ថុ វត្ថុ ( ជាបច្ច័យ ) នៃវិចារ មហាភូត ១ ( ជាបច្ច័យ ) នៃមហាភូត ៣ ពាហិរៈ ... អាហារសមុដ្ឋាន ... ឧតុ-សមុដ្ឋាន ... មហាភូត ១ របស់ពួកអសញ្ញសត្វ ... ។

[ ២៨៣ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺវត្ថុជាបច្ច័យនៃពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៨៤ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺវិចារ ជាបច្ច័យនៃពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអញ្ញមញ្ញប្បច្ច័យ វិចារ ជាបច្ច័យនៃពួកខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ វត្ថុជាបច្ច័យនៃវិតក្ក ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៨៥ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌

ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអញ្ញមញ្ញប្បច្ច័យ គឺវិចារ ជាបច្ច័យនៃពួកខន្ធដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញ-មញ្ញប្បច្ច័យ វត្ថុជាបច្ច័យនៃពួកខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៤៦ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្កមានត្រឹមតែវិចារផង ដោយអញ្ញមញ្ញប្បច្ច័យ គឺវត្ថុជាបច្ច័យនៃពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៤៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្កប្រកបដោយវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិខន្ធ ២ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៤៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺពួកខន្ធដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វត្ថុក្តី ជាបច្ច័យនៃវិតក្ក ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញ-

មញ្ញប្បច្ច័យ ។

[ ២៤៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្កប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តីវត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ផង វិតក្កផងដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៥០ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺវិតក្កក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៥១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ក្តីវិចារក្តី ជាបច្ច័យនៃខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ក្នុងខណៈ

នៃបដិសន្ធិ ខន្ធ ២ ក្តី វិចារក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ដោយអញ្ញ-មញ្ញប្បច្ច័យ ។

[ ២៥២ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញ-មញ្ញប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វត្ថុក្តី ជាបច្ច័យនៃវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៥៣ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ៣ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ២ ផង វត្ថុផង ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ផង វិចារផង ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៥៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក

ប្រកបដោយវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៥៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៥៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអញ្ញមញ្ញប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធ ៣ ផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធ ២ ផង វត្ថុផង ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៥៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអញ្ញ-

មញ្ញប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី វិត្តក្តី ជាបច្ច័យនៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ក្តី វិតក្កក្តី វិត្តក្តី ជាបច្ច័យនៃខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ។

[ ២៥៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយនិស្សយប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ( ជាបច្ច័យ ) នៃខន្ធ ៣ ។ សេចក្តីបង្រួញ ។ មានបញ្ហាវារៈ ៧[១] ។ ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយនិស្សយប្បច្ច័យ ។ សេចក្តីបង្រួញ ។ មានបញ្ហាវារៈ ៥ ។

[ ២៥៩ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយនិស្សយប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយនិស្សយប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយនិស្សយប្បច្ច័យ វិចារ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃខន្ធ ៣ ផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយនិស្សយប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ។ សេចក្តីបង្រួញ ។ មហាភូត ១ របស់ពួកអសញ្ញសត្វ ... ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយា-

---

១- មានវារៈ ៧ ។

យតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយនិស្សយប្បច្ច័យ ។

[ ២៦០ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយនិស្សយប្បច្ច័យ គឺវត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយនិស្សយប្បច្ច័យ វត្ថុក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៦១ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយនិស្សយប្បច្ច័យ គឺវិចារ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយនិស្សយប្បច្ច័យ វត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ដោយនិស្សយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។ សេចក្តីបង្រួញ ។

[ ២៦២ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយនិស្សយប្បច្ច័យ គឺវិចារ ( ជាបច្ច័យ ) នៃខន្ធទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ពួកចិត្តសមុដ្ឋានរូបផង វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយនិស្សយប្បច្ច័យ វិចារ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៦៣ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹម

តែវិចារផង ដោយនិស្សយប្បច្ច័យ គឺវត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយនិស្សយប្បច្ច័យ វត្ថុ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៦៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយនិស្សយប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយនិស្សយប្បច្ច័យ ។ បវត្តិក្តី បដិសន្ធិក្តី បណ្ឌិតគប្បីសម្តែងតទៅចុះ ។

[ ២៦៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយនិស្សយប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃវិតក្ក ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៦៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយនិស្សយប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី មហាភូតទាំងឡាយក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៦៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែល

មិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយនិស្សយប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ផង វិតក្កផង ដោយនិស្សយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៦៨ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយនិស្សយប្បច្ច័យ គឺវិតក្កក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៦៩ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយនិស្សយប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៧០ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយនិស្សយប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយនិស្សយប្បច្ច័យ

ខន្ធទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី មហាភូតទាំងឡាយក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប វិតក្កក្តី មហាភូតទាំងឡាយក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វត្ថុក្តី ជាបច្ច័យនៃវិចារ ដោយនិស្សយប្បច្ច័យ បដិសន្ធិមាន ៤ ។ សេចក្តីបង្រួញ ។

[ ២៧១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយនិស្សយប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយនិស្សយប្បច្ច័យ ខន្ធ ២ ក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ២ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយនិស្សយប្បច្ច័យ ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វត្ថុក្តី ( ជាបច្ច័យ ) នៃខន្ធ ៣ ផង វិចារផង ខន្ធ ២ ក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ២ ផង វិចារផង ដោយនិស្សយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ២៧២ ] ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ( ជាបច្ច័យ ) នៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... នៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ... នៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ... មានបញ្ហាវារៈ ៣ ។

[ ២៧៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... នៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយនិស្សយប្បច្ច័យ ។ វារៈ ២ បណ្ឌិតគប្បីឲ្យពិស្តារចុះ ។

[ ២៧៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ញុំាងឈានដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ឲ្យកើតឡើង ញុំាងវិបស្សនាឲ្យកើតឡើង ញុំាងមគ្គ ។បេ។ ញុំាងសមាបត្តិ ឲ្យកើតឡើង ដំឡើងមានះ ប្រកាន់ទិដ្ឋិ ( បុគ្គល ) អាស្រ័យសីល ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... សុតៈ ចាគៈ បញ្ញា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ ... សេចក្តីប្រាថ្នា ហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ញុំាងឈានដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ឲ្យកើតឡើង ញុំាងវិបស្សនាឲ្យកើតឡើង ញុំាងមគ្គ ... ញុំាងសមាបត្តិ ... សម្លាប់សត្វ បំបែកសង្ឃ សទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃសទ្ធាដែល

ប្រកបដោយវិតក្ក ប្រកបដោយវិចារ សីលៈ សុតៈ ចាគៈ បញ្ញា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ២៧៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធា ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ហើយញ៉ាំងឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារ ឲ្យកើតឡើង ញ៉ាំងមគ្គ ... ញ៉ាំងសមាបត្តិ ... សីល ដែលប្រកបដោយវិតក្កប្រកបដោយវិចារ ។ សេចក្តីបន្រ្ទញ ។ ( បុគ្គល ) អាស្រ័យសេចក្តីប្រាថ្នា ហើយញ៉ាំងឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ឲ្យកើតឡើង ញ៉ាំងមគ្គ ... ញ៉ាំងសមាបត្តិ ... សទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្ក មានត្រឹមតែវិចារៈនិងសីលៈ សុតៈ ចាគៈ បញ្ញាផង វិតក្កផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៧៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធា ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ហើយញ៉ាំងឈានដែលមិនមានវិតក្ក មិនមានវិចារ ឲ្យកើតឡើង ញ៉ាំងមគ្គ ... ញ៉ាំង

អភិញ្ញា ... ញុំាងសមាបត្តិឲ្យកើតឡើង សីលដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... អាស្រ័យសេចក្តីប្រាថ្នា ហើយញុំាងឈានដែលមិនមានវិតក្កមិនមានវិចារ ឲ្យកើតឡើង ញុំាងមគ្គ ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិឲ្យកើតឡើង សទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ។ សេចក្តីបន្រ្ទញ ។ សេចក្តីប្រាថ្នា ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្ក មិនមានវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិចារ កាយិកសុខ និងកាយិកទុក្ខផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៧៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្កមិនមានវិចារផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិចារផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៧៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្កមានត្រឹមតែវិចារផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃសទ្ធាដែល

ប្រកបដោយវិតក្ក ប្រកបដោយវិចារ និងសេចក្ដីប្រាថ្នាផង វិតក្កផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៧៩ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ហើយញ៉ាំងឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារ ឲ្យកើតឡើង ញ៉ាំងមគ្គ ... ញ៉ាំងសមាបត្តិឲ្យកើតឡើង អាស្រ័យសីលដែលមិនមានវិតក្ក មានត្រឹមតែវិចារៈ ... សុតៈ ចាគៈ បញ្ញា ... អាស្រ័យវិតក្ក ហើយញ៉ាំងឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារ ឲ្យកើតឡើង ញ៉ាំងមគ្គ ... ញ៉ាំងសមាបត្តិឲ្យកើតឡើង សទ្ធាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា ... វិតក្កក្ដី ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិតក្កផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨០ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ញ៉ាំងឈានដែល

ប្រកបដោយវិតក្ក ប្រកបដោយវិចារ ឲ្យកើតឡើង ញុំាងវិបស្សនា ... ញុំាងមគ្គ ... ញុំាងសមាបត្តិ ឲ្យកើតឡើង ដំឡើងមានះ ប្រកាន់ទិដ្ឋិ អាស្រ័យសីល ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... សុតៈ ចាគៈ បញ្ញា ... អាស្រ័យវិតក្ក ហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ញុំាងឈានដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ឲ្យកើតឡើង ញុំាងវិបស្សនាឲ្យកើតឡើង ញុំាងមគ្គ ឲ្យកើតឡើង ញុំាងសមាបត្តិឲ្យកើតឡើង សម្លាប់សត្វ បំបែកសង្ឃ សទ្ធាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា ... វិតក្កក្តី ជាបច្ច័យនៃសទ្ធា ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ និងសេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ញុំាងឈានដែលមិនមានវិតក្ក មិនមានវិចារ ឲ្យកើតឡើង ញុំាងមគ្គ ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិ ឲ្យកើតឡើង ( អាស្រ័យ ) សីលដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... សុតៈ ចាគៈ បញ្ញា ... អាស្រ័យវិតក្ក ហើយញុំាងឈានដែលមិនមានវិតក្ក មិនមានវិចារឲ្យកើតឡើង ញុំាងមគ្គ ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិ ឲ្យកើតឡើង សទ្ធាដែលមិនមានវិតក្ក មានត្រឹមតែវិចារៈ ... សីលៈ សុតៈ ចាគៈ បញ្ញា ... វិតក្កក្តី ជាបច្ច័យនៃសទ្ធា ដែលមិនមាន

វិតក្ក មិនមានវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិចារ កាយិកសុខ និងកាយិកទុក្ខផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨២ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា ... វិតក្កក្តី ជាបច្ច័យនៃសទ្ធាដែលមិនមានវិតក្ក មានត្រឹមតែវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិចារៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨៣ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា ... វិតក្កក្តី ជាបច្ច័យនៃសទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ និងសេចក្តីប្រាថ្នាផង វិតក្កផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨៤ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ

( បុគ្គល ) អាស្រ័យសទ្ធា ដែលមិនមានវិតក្ក មិនមានវិចារ ហើយញុំាង ឈាន ដែលមិនមានវិតក្ក មិនមានវិចារ ឲ្យកើតឡើង ញុំាងមគ្គ ... ញុំាង អភិញ្ញា ... ញុំាងសមាបត្តិ ឲ្យកើតឡើង អាស្រ័យសីល ដែលមិនមានវិតក្ក មិនមានវិចារ ... សុតៈ ចាគៈ បញ្ញា វិចារ កាយិកសុខ កាយិកទុក្ខ រដូវ ភោជន ... អាស្រ័យសេនាសនៈ ហើយញុំាងឈានដែលមិនមានវិតក្ក មិន មានវិចារ ឲ្យកើតឡើង ញុំាងមគ្គ ... ញុំាងអភិញ្ញា ... ញុំាងសមាបត្តិ ឲ្យ កើតឡើង សទ្ធាដែលមិនមានវិតក្ក មិនមានវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា វិចារ កាយិកសុខ កាយិកទុក្ខ រដូវ ភោជន ... សេនាសនៈ ជា បច្ច័យនៃសទ្ធា ដែលមិនមានវិតក្ក មិនមានវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញា វិចារ កាយិកសុខ កាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨៥ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែល ប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធាដែលមិនមានវិតក្ក មិនមានវិចារ ហើយឲ្យ ទាន សមាទានសីល ធ្វើឧបោសថកម្ម ញុំាងឈានដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ឲ្យកើតឡើង ញុំាងវិបស្សនា ... ញុំាងមគ្គ ... ញុំាង សមាបត្តិ ឲ្យកើតឡើង ជំឡើងមានះ ប្រកាន់ទិដ្ឋិ ( អាស្រ័យ ) សីល ដែលមិនមានវិតក្ក មិនមានវិចារ ... សុតៈ ចាគៈ បញ្ញា វិចារ កាយិក-សុខ កាយិកទុក្ខ រដូវ ភោជន ... អាស្រ័យសេនាសនៈ ហើយឲ្យទាន

សមាទានសីល ធ្វើឧបោសថកម្ម ញ៉ាំងឈានដែលប្រកបដោយវិតក្ក ប្រកបដោយវិចារឲ្យកើតឡើង ញ៉ាំងវិបស្សនា ... ញ៉ាំងមគ្គ ... ញ៉ាំងសមាបត្តិឲ្យកើតឡើង សម្លាប់សត្វ បំបែកសង្ឃ សទ្ធាដែលមិនមានវិតក្ក មិនមានវិចារ ។ សេចក្តីបង្រួញ ។ សេនាសនៈជាបច្ច័យនៃសទ្ធា ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ និងសីល ។បេ។ សេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨៦ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺ ( បុគ្គល ) អាស្រ័យសទ្ធា ដែលមិនមានវិតក្ក មិនមានវិចារ ហើយញ៉ាំងឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ឲ្យកើតឡើង ញ៉ាំងវិបស្សនា ... ញ៉ាំងមគ្គ ... ញ៉ាំងសមាបត្តិឲ្យកើតឡើង ( អាស្រ័យ ) សីលដែលមិនមានវិតក្ក មិនមានវិចារ ... អាស្រ័យសេនាសនៈ ហើយញ៉ាំងឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារ ឲ្យកើតឡើង ញ៉ាំងវិបស្សនា ... ញ៉ាំងមគ្គ ... ញ៉ាំងសមាបត្តិឲ្យកើតឡើង សទ្ធាដែលមិនមានវិតក្ក មិនមានវិចារ ... សេនាសនៈ ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិតក្កផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៨៧ ] ធម៌ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារ

ផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូប-និស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលមិនមានវិតក្ក មិនមានវិចារ ... សេនាសនៈ ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្ក មាន ត្រឹមតែវិចារ និងសីល សុតៈ ចាគៈ បញ្ញាផង វិចារផង ដោយឧប-និស្សយប្បច្ច័យ ។

[ ២៨៨ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែល ប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹម តែវិចារផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលមិន មានវិតក្ក មិនមានវិចារ ... សេនាសនៈជាបច្ច័យនៃសទ្ធាដែលប្រកបដោយ វិតក្ក ប្រកបដោយវិចារ នៃសីល និងសេចក្ដីប្រាថ្នាផង វិតក្កផង ដោយ ឧបនិស្សយប្បច្ច័យ ។

[ ២៨៩ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្ដី ធម៌ដែលមិន មានវិតក្ក មិនមានវិចារក្ដី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកប ដោយវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្ត-រូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលមិនមាន វិតក្ក មានត្រឹមតែវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា ... វិចារក្ដី ជាបច្ច័យ នៃសទ្ធា ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... នៃបញ្ញា ដោយ ឧបនិស្សយប្បច្ច័យ ។

[ ២៩០ ] ធម៌ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា ... វិចារក្តី ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិតក្កៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩១ ] ធម៌ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្កៈ មិនមានវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធា ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា ... វិចារក្តី ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្កៈ មិនមានវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិចារ កាយិកសុខ និងកាយិកទុក្ខផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩២ ] ធម៌ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធា ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ ... សីលៈ សុតៈ ចាគៈ

បញ្ញា ... វិចារក្តី ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិចារផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩៣ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធា ដែលមិនមានវិតក្ក មានត្រឹមតែវិចារៈ ... សីលៈ សុតៈ ចាគៈ បញ្ញា ... វិចារក្តី ជាបច្ច័យនៃសទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នាផង វិតក្កផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នា... វិតក្កក្តី ជាបច្ច័យនៃសទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ និងសីល ។បេ។ សេចក្តីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... សីលៈ ។បេ។ សេចក្តីប្រាថ្នា ... វិតក្កក្តី ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិតក្កផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា ។បេ។ សេចក្តីប្រាថ្នា ... វិតក្កក្តី ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្ក មិនមានវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិតក្ក កាយិកសុខ និងកាយិកទុក្ខផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យនិងបកតូបនិស្ស័យ ។ បកតូប-

និស្ស័យ គឺសទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា ។បេ។ សេចក្ដីប្រាថ្នា ... វិតក្កក្ដី ជាបច្ច័យនៃសទ្ធា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ និងសីលៈ សុតៈ ចាគៈ បញ្ញាផង វិចារផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្ដី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្ដី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ... សីលៈ សុតៈ ចាគៈ បញ្ញា រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ សេចក្ដីប្រាថ្នា ... វិតក្កក្ដី ជាបច្ច័យនៃសទ្ធា ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ។បេ។ នៃសេចក្ដីប្រាថ្នាផង វិតក្កផង ដោយឧបនិស្សយប្បច្ច័យ ។

[ ២៩៩ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) ឃើញរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ

កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយបុរេជាតប្បច្ច័យ ។

[ ៣០០ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) ឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ។បេ។ ( បុគ្គល ) ឃើញច្បាស់នូវផោដ្ឋព្វៈទាំងឡាយ ... នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួនហើយ ត្រេកអរ រីករាយ រាគៈប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ទោមនស្សក៏កើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយបុរេជាតប្បច្ច័យ ។

[ ៣០១ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) ឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ហើយត្រេកអរ រីករាយ វិតក្កប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ។ សេចក្តីបង្រួញ ។ ( បុគ្គល ) ឃើញច្បាស់នូវវត្ថុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ហើយត្រេកអរ រីករាយ វិតក្ក ប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ដោយបុរេជាតប្បច្ច័យ ។

[ ៣០២ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយបុរេជាតប្បច្ច័យ បានដល់ វត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយបុរេជា-តប្បច្ច័យ ។

[ ៣០៣ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេ-ជាត ។ អារម្មណបុរេជាត គឺ ( បុគ្គល ) ឃើញច្បាស់ នូវចក្ខុ ជាមិនទៀង ជាទុក្ខ មិនមែនខ្លួន ហើយត្រេកអរ រីករាយ ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ( បុគ្គល ) ឃើញច្បាស់នូវសោតៈ ... ឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ ... នូវវត្ថុ ជាមិនទៀង ជាទុក្ខ មិនមែនខ្លួន ហើយត្រេកអរ រីករាយ ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ប្រារព្ធនូវសោតៈ ( ជាដើម ) នោះ ទើបកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយបុរេជាតប្បច្ច័យ ។

[ ៣០៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយបច្ឆាជាតប្បច្ច័យ បានដល់

បច្ឆាជាត គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០៥ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិតក្កៈក្តី ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០៦ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារក្តី វិចារក្តី ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃកាយនេះ

ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៣០៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអាសេវនប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទាន: គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ វោទាន:ជាបច្ច័យនៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអាសេវនប្បច្ច័យ ។

[ ៣១០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្កក្រោយៗ ដោយអាសេវនប្បច្ច័យ បរិកម្មនៃឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ គោត្រភូជាបច្ច័យនៃមគ្គ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ វោទាន: ជាបច្ច័យនៃមគ្គ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ ។

[ ៣១១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអាសេវនប្បច្ច័យ បរិកម្ម

នៃទុតិយជ្ឈាន ជាបច្ច័យនៃវិចារ ក្នុងទុតិយជ្ឈាន ដោយអាសេវនប្បច្ច័យ បរិកម្មនៃតតិយជ្ឈាន ( ជាបច្ច័យ ) នៃតតិយជ្ឈាន បរិកម្មនៃចតុត្ថជ្ឈាន ( ជាបច្ច័យ ) នៃចតុត្ថជ្ឈាន បរិកម្មនៃអាកាសានញ្ចាយតនៈ ( ជាបច្ច័យ ) នៃអាកាសានញ្ចាយតនៈ បរិកម្មនៃវិញ្ញាណញ្ចាយតនៈ ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតនៈ បរិកម្មនៃអាកិញ្ចញ្ញាយតនៈ ( ជាបច្ច័យ ) នៃអាកិញ្ចញ្ញាយតនៈ បរិកម្មនៃនេវសញ្ញានាសញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ បរិកម្មនៃទិព្វចក្ខុ ( ជាបច្ច័យ ) នៃទិព្វចក្ខុ បរិកម្មនៃទិព្វសោតធាតុ ( ជាបច្ច័យ ) នៃទិព្វសោតធាតុ នៃឥទ្ធិវិធញ្ញាណ ។បេ។ នៃចេតោបរិយញ្ញាណ ។បេ។ បរិកម្មនៃបុព្វេនិវាសានុស្សតិញ្ញាណ ( ជាបច្ច័យ ) នៃបុព្វេនិវាសានុស្សតិញ្ញាណ ។បេ។ នៃយថាកម្មុបគញ្ញាណ ។បេ។ បរិកម្មនៃអនាគតំសញ្ញាណ ។បេ។ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង វោទានៈជាបច្ច័យនៃមគ្គ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយអាសេវនប្បច្ច័យ ។

[ ៣១២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអាសេវនប្បច្ច័យ គឺបរិកម្មនៃឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអាសេវនប្បច្ច័យ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង វោទានៈជាបច្ច័យ

នៃមគ្គ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអាសេវនប្បច្ច័យ ។

[ ៣១៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអាសេវនប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូផង វិតក្កផង អនុ-លោម ( ជាបច្ច័យ ) នៃវោទានៈផង វិតក្កផង គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង វោទានៈ ជាបច្ច័យនៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអាសេវនប្បច្ច័យ ។

[ ៣១៤ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ គឺវិតក្កមុនៗ ជាបច្ច័យនៃវិតក្កក្រោយៗ ដោយអាសេវនប្បច្ច័យ ខន្ធទាំងឡាយមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ ។

[ ៣១៥ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអាសេវនប្បច្ច័យ គឺវិតក្ក

មុនៗ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារៈ ដោយអាសេវនប្បច្ច័យ ។

[ ៣១៦ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិចារក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ៣១៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអាសេវនប្បច្ច័យ ។

[ ៣១៨ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអាសេវនប្បច្ច័យ គឺវិតក្កមុនៗ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអាសេវនប្បច្ច័យ ។

[ ៣១៩ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអាសេវនប្បច្ច័យ គឺវិចារមុនៗ ជាបច្ច័យនៃវិចារក្រោយៗ ដោយអាសេវនប្បច្ច័យ ខន្ធទាំងឡាយមុនៗ ដែល

មិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអាសេវនប្បច្ច័យ ។

[ ៣២០ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ គឺវិចារមុនៗ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ ។

[ ៣២១ ] ធម៌ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអាសេវនប្បច្ច័យ គឺវិចារមុនៗ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអាសេវនប្បច្ច័យ ។

[ ៣២២ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ ។

[ ៣២៣ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃវិចារក្រោយៗ ដោយអាសេវ-

នប្បច្ច័យ ។

[ ៣២៤ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអាសេវនប្បច្ច័យ ។

[ ៣២៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអាសេវនប្បច្ច័យ អនុលោមក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃគោត្រភូ អនុលោមក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃវោទាន: គោត្រភូក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ វោទាន:ក្តី វិតក្កក្តី ជាបច្ច័យនៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអាសេវនប្បច្ច័យ ។

[ ៣២៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មាន

ត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលប្រកប ដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃវិតក្កក្រោយៗ ដោយ អាសេវនប្បច្ច័យ បរិកម្មនៃឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិតក្កក្តី ជាបច្ច័យនៃឈាន ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយ អាសេវនប្បច្ច័យ គោត្រភូក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃមគ្គដែលមិនមាន វិតក្ក មានត្រឹមតែវិចារ វោទានៈក្តី វិតក្កក្តី ជាបច្ច័យនៃមគ្គ ដែលមិន មានវិតក្ក មានត្រឹមតែវិចារ ដោយអាសេវនប្បច្ច័យ ។

[ ៣២៧ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែល មិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិន មានវិចារ ដោយអាសេវនប្បច្ច័យ គឺបរិកម្មនៃទុតិយជ្ឈានក្តី វិតក្កក្តី ជា បច្ច័យនៃវិចារក្នុងទុតិយជ្ឈាន ដោយអាសេវនប្បច្ច័យ បរិកម្មនៃនេវសញ្ញា- នាសញ្ញាយតនៈក្តី វិតក្កក្តី ... បរិកម្មនៃទិព្វចក្ខុក្តី វិតក្កក្តី ... បរិកម្មនៃ អនាគតំសញ្ញាណក្តី វិតក្កក្តី ជាបច្ច័យនៃអនាគតំសញ្ញាណ ដោយអាសេ- វនប្បច្ច័យ គោត្រភូក្តី វិតក្កក្តី ជាបច្ច័យនៃមគ្គ ដែលមិនមានវិតក្ក មិន មានវិចារផង វិចារផង ដោយអាសេវនប្បច្ច័យ វោទានៈក្តី វិតក្កក្តី ជា បច្ច័យនៃមគ្គ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយ អាសេវនប្បច្ច័យ ។

[ ៣២៨ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែល មិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មាន

ត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអាសេ-វនប្បច្ច័យ គឺបរិកម្មនៃឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃឈានដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង គោត្រភូក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃមគ្គ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង វោទានក្តី វិតក្កក្តី ជាបច្ច័យនៃមគ្គដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយអាសេវនប្បច្ច័យ ។

[ ៣២៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្កប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអាសេវនប្បច្ច័យ អនុលោមក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃគោត្រភូផង វិតក្កផង អនុលោមក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃវោទានៈផង វិតក្កផង គោត្រភូក្តី វិតក្កក្តី ( ជាបច្ច័យ ) នៃមគ្គដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង វោទានៈក្តី វិតក្កក្តី ជាបច្ច័យនៃមគ្គ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយអាសេវនប្បច្ច័យ ។

[ ៣៣០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយកម្មប្បច្ច័យ បាន

ដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រកបដោយ វិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកសម្ប-យុត្តកក្ខន្ធ ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺ ចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយកម្មប្បច្ច័យ ។

[ ៣៣១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យ នៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្ក ដោយកម្មប្បច្ច័យ ចេតនាដែលប្រកប ដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្ក ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនា ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្កដែលជាវិបាក ដោយកម្មប្បច្ច័យ ។

[ ៣៣២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យ នៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ចេតនា ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកកដត្តារូប ក្នុង ខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែល

ប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលមិនមានវិតក្ក មិនមានវិចារផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៣៣៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្កមិនមានវិចារផង ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៣៣៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្កមិនមានវិចារផង ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្កផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្កផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែល

ប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្ក ដែលជាវិបាកផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៣៣៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង វិតក្កផង ដោយកម្មប្បច្ច័យ ចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនា ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយកម្មប្បច្ច័យ ។

[ ៣៣៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយកម្មប្បច្ច័យ បានដល់ សហជាតនិងនានាខណិកៈ ។ សហជាត គឺចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង វិតក្កផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ចេតនាដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ

ផង វិតក្កផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ ជាបច្ច័យនៃពួកវិបាកក្ខន្ធដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈផង វិតក្កៈផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៣៣៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ក្នុងខណៈនៃបដិ-សន្ធិ ... ។ ឯនានាខណិកៈ គឺចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយកម្មប្បច្ច័យ ។

[ ៣៣៨ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិបាកផង វិចារផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។ ឯនានា-ខណិកៈ គឺចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិបាកផង វិចារផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៣៣៩ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង វិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ចេតនា ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង វិចារផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារៈផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៣៤០ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ចេតនាដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនា ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃពួកវិបាកក្ខន្ធ ដែលមិនមានវិតក្ក មិនមានវិចារផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៣៨១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ដោយវិបាកប្បច្ច័យ ខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ ដោយវិបាកប្បច្ច័យ ។

[ ៣៨២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្ក ដោយវិបាកប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ បញ្ហា ៧ ដែលមានធម៌ប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាមូល ( ចប់ ) បរិបូណ៌ ។

[ ៣៨៣ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារៈជាបច្ច័យនៃខន្ធ ៣ ដោយវិបាកប្បច្ច័យ ខន្ធ ២ ... វិបាកក្ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ... ។ បញ្ហា ៥ ដែលមានធម៌មិនមានវិតក្ក មានត្រឹមតែវិចារ ជាមូល បណ្ឌិតគប្បីធ្វើចុះ ។ បណ្ឌិតគប្បីកំណត់ថាជាវិបាក ។

[ ៣៨៤ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង

ដោយវិបាកប្បច្ច័យ ខន្ធ ២ ។បេ។ វិចារៈជាវិបាក ជាបច្ច័យនៃពួកចិត្ត-សមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ខន្ធទាំងឡាយជាបច្ច័យនៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ ដោយវិបាកប្បច្ច័យ វិចារជាបច្ច័យនៃវត្ថុ ដោយវិបាកប្បច្ច័យ ។

[ ៣៨៥ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយវិបាកប្បច្ច័យ គឺវិចារជាវិបាក ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយវិបាក-ប្បច្ច័យ វិចារជាវិបាក ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយវិបាកប្បច្ច័យ ។

[ ៣៨៦ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយវិបាកប្បច្ច័យ គឺវិចារជាវិបាក ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយវិបា-កប្បច្ច័យ វិចារជាវិបាក ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយវិបាកប្បច្ច័យ ។

[ ៣៨៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ៣ ដោយវិបាកប្បច្ច័យ ខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៤៨ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយវិបាកប្បច្ច័យ ។

[ ៣៤៩ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយវិបាកប្បច្ច័យ វិបាកក្ខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ៣ ផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយវិបាកប្បច្ច័យ ។

[ ៣៥០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធ ៣ ដោយវិបាកប្បច្ច័យ ខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៥១ ] ធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែល

មិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្កៈ មិនមានវិចារ ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិបាកប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៥២ ] ធម៌ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារផង ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយវិបាកប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៥៣ ] ធម៌ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារ ដោយអាហារប្បច្ច័យ គឺពួកអាហារ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៥៤ ] ធម៌ ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ ដោយអាហារប្បច្ច័យ គឺពួកអាហារដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្កៈ ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ បញ្ហា ៧ ដែលមានធម៌ប្រកបដោយវិតក្កៈ ប្រកបដោយវិចារ ជាមូល បណ្ឌិតគប្បីចែកដោយហេតុនេះ

ចុះ ។

[ ៣៥៥ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអាហារប្បច្ច័យ គឺពួកអាហារដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៥៦ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអាហារប្បច្ច័យ គឺពួកអាហារដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៥៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយអាហារប្បច្ច័យ គឺពួកអាហារ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង វិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៥៨ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយអាហារប្បច្ច័យ គឺពួកអាហារដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ កពឡីង្ការាហារ ជាបច្ច័យនៃកាយនេះ ក្នុងខណៈនៃបដិសន្ធិ ដោយអាហារប្បច្ច័យ ។

[ ៣៥៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៦០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្ក ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ បញ្ហា ៧ ដែលមានធម៌ប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាមូល បណ្ឌិតគប្បីចែកដោយហេតុនេះចុះ ។

[ ៣៦១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៦២ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៦៣ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌

ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង វិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ... ។

[ ៣៦៤ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយឥន្ទ្រិយប្បច្ច័យ គឺពួកឥន្ទ្រិយដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្ត-សមុដ្ឋានរូបផង ដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ក្នុងខណៈនៃបដិសន្ធិ កាយិន្ទ្រិយ ជាបច្ច័យនៃកាយវិញ្ញាណ ដោយឥន្ទ្រិយប្បច្ច័យ រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃពួកកដត្តារូប ដោយឥន្ទ្រិ-យប្បច្ច័យ ។

[ ៣៦៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឈានប្បច្ច័យក្នុងខណៈនៃបដិសន្ធិ ... ។ បញ្ហា ៧ ដែលមានធម៌ប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាមូល បណ្ឌិតគប្បីចែកដោយហេតុនេះចុះ ។

[ ៣៦៦ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយឈានប្បច្ច័យ គឺអង្គឈានទាំង

ឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឈានបច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ បញ្ហា ៥ ដែលមានធម៌មិនមានវិតក្ក មានត្រឹមតែវិចារជាមូល បណ្ឌិតគប្បីចែកដោយហេតុនេះចុះ ។

[ ៣៦៧ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយឈានបច្ច័យ គឺអង្គឈានទាំងឡាយដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយឈានបច្ច័យ វិចារ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយឈានបច្ច័យ វិចារ ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយឈានបច្ច័យ វិចារជាបច្ច័យនៃវត្ថុ ដោយឈានបច្ច័យ ។

[ ៣៦៨ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយឈានបច្ច័យ គឺវិចារ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយឈានបច្ច័យ វិចារ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយឈានបច្ច័យ ។

[ ៣៦៩ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារ ផង ដោយឈានបច្ច័យ គឺវិចារ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ពួកចិត្តសមុដ្ឋានរូបផង ដោយឈានបច្ច័យ វិចារជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង

ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយឈានប្បច្ច័យ ។

[ ៣៧០ ] ធម៌ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឈានប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៧១ ] ធម៌ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្កៈ មិនមានវិចារ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយឈានប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៧២ ] ធម៌ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្កៈ មិនមានវិចារផង ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយឈានប្បច្ច័យ ។

[ ៣៧៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយឈានប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៧៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយឈានប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៧៥ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយឈានប្បច្ច័យ គឺអង្គឈានទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយឈានប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៧៦ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួក

សម្បយុត្តកក្ខន្ធ ដោយមគ្គប្បច្ច័យក្នុងខណៈនៃបដិសន្ធិ ... ។ បញ្ហា ៧ ដែលមានធម៌ប្រកបដោយវិតក្ក ប្រកបដោយវិចារជាមូល បណ្ឌិត គប្បីចែកដោយហេតុនេះចុះ ។

[ ៣៧៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយមគ្គប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ បញ្ហា ៥ ដែលមានធម៌មិនមានវិតក្ក មានត្រឹមតែវិចារជាមូល បណ្ឌិតគប្បីចែកដោយហេតុនេះចុះ ។

[ ៣៧៨ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយមគ្គប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៧៩ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយមគ្គប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៨០ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិន

មានវិចារ ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយមគ្គប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៨១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយមគ្គប្បច្ច័យ គឺអង្គមគ្គទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយមគ្គប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៨២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសម្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៨៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយសម្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្ក ដោយសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៨៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យ

នៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយសម្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ផង វិតក្កផង ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៨៥ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយសម្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃខន្ធ ៣ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៨៦ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសម្បយុត្តប្បច្ច័យ គឺវិតក្ក ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៨៧ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយសម្បយុត្តប្បច្ច័យ គឺខន្ធទាំងឡាយដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃវិចារ ដោយសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៨៨ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមាន

វិចារផង ដោយសម្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃខន្ធ ៣ ផង វិចារផង ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៨៩ ] ធម៌ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយសម្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃខន្ធ ៣ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៩០ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយសម្បយុត្តប្បច្ច័យ គឺវិចារ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយសម្ប-យុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៩១ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយសម្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃខន្ធ ៣ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ក្តី វិចារៈក្តី ជាបច្ច័យនៃខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៩២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយសម្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយ

វិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃខន្ធ ៣ ដោយសម្បយុត្តប្បច្ច័យ ខន្ធ ២ ក្តី វិតក្កក្តី ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៣៩៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៩៤ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មិនមានវិចារ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាតនិងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិតក្កក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៩៥ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែល

មិនមានវិតក្ក មិនមានវិចារ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាតនិងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ វិចារ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ វិចារ ជាបច្ច័យនៃពួកកដត្តារូប ដោយវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយ ជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ វិចារជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃវិចារ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយវិប្បយុត្តប្បច្ច័យ វត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារផង វិចារផង ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មិនមានវិចារក្តី វិចារក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៩៦ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកប

ដោយវិតក្ក ប្រកបដោយវិចារ ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៩៧ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺវត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ដោយវិប្ប-យុត្តប្បច្ច័យ ។ ឯបុរេជាត គឺវត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៩៨ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ធម៌ដែលមិនមានវិតក្ក មិនមានវិចារផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺវត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង វិចារផង ដោយវិប្បយុត្តប្បច្ច័យ ។

[ ៣៩៩ ] ធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារផង ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ។

ឯបុរេជាត គឺវត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារផង វិតក្កផង ដោយវិប្បយុត្តប្បច្ច័យ ។

[ ៤០០ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ធម៌ដែលមិនមានវិតក្ក មិនមានវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី វិចារក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៤០១ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី ធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារក្តី ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កៈក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារក្តី វិតក្កក្តី ជា

បច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៤០២ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៤០៣ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអត្ថិប្បច្ច័យ គឺខន្ធទាំងឡាយដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃវិតក្ក ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៤០៤ ] ធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មិនមានវិចារ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ បញ្ហាដ៏សេស ( ក្នុងធម៌ ) ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារជាមូល ប្រហែលគ្នានឹងសហជាតប្បច្ច័យដែរ ។

[ ៤០៥ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ( ជាបច្ច័យ ) នៃខន្ធ ២ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៤០៦ ] ធម៌ ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ជាបច្ច័យនៃធម៌ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអត្ថិប្បច្ច័យ គឺវិតក្កជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

នសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៧ ក្នុងនកម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។

អនុលោមប្បច្ចនីយៈ ចប់

[ ៦៤៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៧ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៦ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៧ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៧ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

បច្ចយវារៈ ចប់

និស្សយវារៈ បណ្ឌិតគប្បីធ្វើឲ្យប្រហែលគ្នានឹងបច្ចយវារៈដែរ ។

## សំសដ្ឋវារៈ

[ ៦៥០ ] ធម៌ ដែលគួរលះដោយទស្សនៈ ប្រឡូំនឹងធម៌ ដែលគួរលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡូំនឹងខន្ធ ១ ដែលគួរលះដោយទស្សនៈ ខន្ធ ២ ប្រឡូំនឹងខន្ធ ២ ។

[ ៦៥១ ] ធម៌ ដែលគួរលះដោយភាវនា ប្រឡូំនឹងធម៌ ដែលគួរលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ( ខន្ធ ៣ ) ប្រឡូំនឹងខន្ធ ១ ដែលគួរលះដោយភាវនា ។

[ ៦៥២ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ប្រឡូំនឹងធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ... ខន្ធ ៣ ប្រឡូំនឹងខន្ធ ១ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ។បេ។ ( ខន្ធ ៣ ) ប្រឡូំនឹងខន្ធ ១ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ក្នុងខណៈនៃបដិសន្ធិ ។

[ ៦៥៣ ] ធម៌ ដែលគួរលះដោយទស្សនៈ ប្រឡូំនឹងធម៌ ដែលគួរលះដោយទស្សនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ បទទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារចុះ សូទ្ធតែមានវារៈបីៗ ។

[ ៦៥៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុង

អញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

អនុលោម ចប់

[ ៦៥៥ ] ធម៌ ដែលគួរលះដោយទស្សនៈ ប្រទូរំនឹងធម៌ ដែលគួរលះដោយទស្សនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រព្រឹត្តទៅ មួយអន្លើដោយវិចិកិច្ឆា ប្រទូរំនឹងខន្ធទាំងឡាយដែលប្រព្រឹត្តទៅ មួយអន្លើដោយវិចិកិច្ឆា ។

[ ៦៥៦ ] ធម៌ ដែលគួរលះដោយភាវនា ប្រទូរំនឹងធម៌ ដែលគួរលះដោយភាវនា ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រព្រឹត្តទៅ មួយអន្លើដោយឧទ្ធច្ចៈ ប្រទូរំនឹងខន្ធទាំងឡាយដែលប្រព្រឹត្តទៅ មួយអន្លើដោយឧទ្ធច្ចៈ ។

[ ៦៥៧ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ប្រទូរំនឹងធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ទើប

កើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ប្រឡំនឹងអហេតុកក្ខន្ធ ១ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ... ។

[ ៦៥៨ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ ប្រឡំដោយធម៌ ដែលគួរលះដោយទស្សនៈ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ នកម្មប្បច្ច័យ និងនវិបាកប្បច្ច័យ ។ ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ។បេ។ ព្រោះនឈានប្បច្ច័យ គឺបញ្ចវិញ្ញាណ ។ ... ព្រោះនមគ្គប្បច្ច័យ គឺអហេតុកក្ខន្ធ ។ ( ធម៌ ) ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ។បេ។ ព្រោះនវិប្បយុត្តប្បច្ច័យ គឺមានវារៈ ៣ ។

[ ៦៥៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

### បច្ចនីយៈ ចប់

[ ៦៦០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ... ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុង នអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុង

នវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

អនុលោមប្បច្ចនីយៈ ចប់

[ ៦៦១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ២ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

បច្ចនីយានុលោម ចប់

សំសដ្ឋវារៈ ចប់

[ ៦៦២ ] ធម៌ ដែលគួរលះដោយទស្សនៈ ប្រកបដោយធម៌ដែលគួរលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

សម្បយុត្តវារៈ ប្រហែលគ្នានឹងសំសដ្ឋវារៈដែរ ។

# បញ្ហាវារៈ

[ ៦៦៣ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយហេតុប្បច្ច័យ គឺពួកហេតុដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។

[ ៦៦៤ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយហេតុប្បច្ច័យ គឺពួកហេតុ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។

[ ៦៦៥ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលគួរលះដោយទស្សនៈផង ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាផង ដោយហេតុប្បច្ច័យ គឺពួកហេតុដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ។

[ ៦៦៦ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនា ដោយហេតុប្បច្ច័យ គឺពួកហេតុដែលគួរលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយហេតុប្បច្ច័យ ។

[ ៦៦៧ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ... គឺពួកហេតុដែលគួរលះដោយភាវនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយហេតុប្បច្ច័យ ។

[ ៦៦៨ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនាផង ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា

ផង ... គឺពួកហេតុដែលគួរលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ។

[ ៦៦៩ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ... គឺពួកហេតុដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ពួកហេតុ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ដោយហេតុប្បច្ច័យ ។

[ ៦៧០ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយអារម្មណប្បច្ច័យ គឺបុគ្គលត្រេកអរ រីករាយ ចំពោះរាគៈដែលគួរលះដោយទស្សនៈ រាគៈដែលគួរលះដោយទស្សនៈ ប្រារព្ធនូវរាគៈនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្សដែលគួរលះដោយទស្សនៈកើតឡើង បុគ្គលត្រេកអរ រីករាយ ចំពោះទិដ្ឋិ រាគៈដែលគួរលះដោយទស្សនៈ ប្រារព្ធនូវទិដ្ឋិនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្សដែលគួរលះដោយទស្សនៈ កើតឡើង វិចិកិច្ឆា ប្រារព្ធនូវវិចិកិច្ឆា កើតឡើង ទិដ្ឋិកើតឡើង ទោមនស្សដែលគួរលះដោយទស្សនៈកើតឡើង ទោមនស្សដែលគួរលះដោយទស្សនៈ ប្រារព្ធនូវទោមនស្សដែលគួរលះដោយទស្សនៈ ទើបកើតឡើង វិចិកិច្ឆាកើតឡើង ។

[ ៦៧១ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអារម្មណប្បច្ច័យ គឺព្រះអរិយៈទាំងឡាយ ពិចារណានូវពួកកិលេសដែលគួរលះដោយទស្សនៈ ដែលលះបង់ហើយ ដឹងនូវពួកកិលេស ដែលធ្លាប់សន្សំមកហើយ ក្នុងកាលមុន ឃើញច្បាស់នូវខន្ធទាំងឡាយ ដែលគួរលះដោយទស្សនៈ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដឹងចិត្តនៃបុគ្គលអ្នកប្រកបដោយចិត្ត ដែលគួរលះដោយទស្សនៈ ដោយចេតោបរិយញ្ញាណ ខន្ធទាំងឡាយដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៦៧២ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនា ដោយអារម្មណប្បច្ច័យ គឺបុគ្គលត្រេកអរ រីករាយ ចំពោះរាគៈដែលគួរលះដោយភាវនា រាគៈដែលគួរលះដោយភាវនា ប្រារព្ធនូវរាគៈនោះ ទើបកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សដែលគួរលះដោយភាវនា កើតឡើង ឧទ្ធច្ចៈប្រារព្ធនូវឧទ្ធច្ចៈ ទើបកើតឡើង ទោមនស្សដែលគួរលះដោយភាវនា ទើបកើតឡើង ទោមនស្ស ដែលគួរលះដោយភាវនា ប្រារព្ធនូវទោមនស្សដែលគួរលះដោយភាវនា ទើបកើតឡើង ឧទ្ធច្ចៈកើតឡើង ។

[ ៦៧៣ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយអារម្មណប្បច្ច័យ គឺបុគ្គលត្រេកអរ រីករាយ ចំពោះរាគៈ ដែលគួរលះដោយភាវនា រាគៈដែលគួរលះដោយទស្សនៈ ប្រារព្ធនូវ

រាគៈនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្សដែលគួរលះដោយទស្សនៈ កើតឡើង ទិដ្ឋិប្រារព្ធនូវឧទ្ធច្ចៈទើបកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្សដែលគួរលះដោយទស្សនៈ កើតឡើង ទោមនស្សដែលគួរលះដោយទស្សនៈ ប្រារព្ធនូវទោមនស្ស ដែលគួរលះដោយភាវនា ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ។

[ ៦៧៤ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអារម្មណប្បច្ច័យ គឺព្រះអរិយៈទាំងឡាយ ពិចារណានូវកិលេស ដែលគួរលះដោយភាវនា ដែលលះបង់ហើយ ពិចារណានូវកិលេសដែលសង្កត់សង្កិនហើយ ឃើញច្បាស់នូវខន្ធទាំងឡាយ ដែលគួរលះដោយភាវនា ដែលធ្លាប់សន្សំមកហើយ ក្នុងកាលមុន ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដឹងនូវចិត្តនៃបុគ្គលអ្នកប្រកបដោយចិត្តដែលគួរលះដោយភាវនា ដោយចេតោបរិយញ្ញាណ ខន្ធទាំងឡាយដែលគួរលះដោយភាវនា ជាបច្ច័យនៃការពិចារណា នូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៦៧៥ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយពិចារណានូវកុសលនោះ ពិចារណានូវកុសលទាំងឡាយ ដែលធ្លាប់

សន្សំមកហើយ ក្នុងកាលមុន ចេញអំពីឈាន ហើយពិចារណានូវឈាន ព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ហើយពិចារណានូវមគ្គ ពិចារណានូវនិព្វាន ព្រះនិព្វានជាបច្ច័យនៃការពិចារណានូវគោត្រភូ វោទាន: មគ្គ និងផល ដោយអារម្មណប្បច្ច័យ បុគ្គលឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន នូវសោត: ... នូវឃាន: ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វ: ... នូវវត្ថុ ឃើញច្បាស់នូវខន្ធទាំងឡាយ ដែលមិនគួរលះដោយទស្សន: មិនគួរលះដោយភាវនា ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញរូបដោយទិព្វចក្ខុ ( ឮ ) សំឡេងដោយទិព្វសោតធាតុ ... ដឹងចិត្តនៃបុគ្គលអ្នកប្រកបដោយចិត្ត ដែលមិនគួរលះដោយទស្សន: មិនគួរលះដោយភាវនា ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតន: ( ជាបច្ច័យ ) នៃវិញ្ញាណញ្ចាយតន: អាកិញ្ចញ្ញាយតន: ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតន: រូបាយតន: ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយអារម្មណប្បច្ច័យ ផោដ្ឋព្វាយតន: ជាបច្ច័យនៃកាយវិញ្ញាណ ដោយអារម្មណប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនគួរលះដោយទស្សន: មិនគួរលះដោយភាវនា ជាបច្ច័យនៃការពិចារណានូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[ ៦៧៦ ] ធម៌ ដែលមិនគួរលះដោយទស្សន: មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សន: ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយត្រេកអរ រីករាយ ចំពោះ

កុសលនោះ រាគៈដែលគួរលះដោយទស្សនៈ ប្រារព្ធនូវកុសលនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្ស ដែលគួរលះដោយទស្សនៈ កើតឡើង ( ព្រះអរិយបុគ្គល ) ពិចារណានូវកុសលទាំងឡាយដែលធ្លាប់សន្សំមកហើយ ក្នុងកាលមុន ចេញអំពីឈាន ហើយត្រេកអរចំពោះឈាន រាគៈដែលគួរលះដោយទស្សនៈ ប្រារព្ធនូវឈាននោះ ... ទិដ្ឋិ ... វិចិកិច្ឆា ... កាលបើឈានសាបសូន្យហើយ វិប្បដិសារីបុគ្គល ... ទោមនស្ស ដែលគួរលះដោយទស្សនៈ កើតឡើង ត្រេកអរ រីករាយ ចំពោះចក្ខុ ចំពោះសោតៈ ... ចំពោះឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ ... វត្ថុ ត្រេកអរ រីករាយ ចំពោះខន្ធទាំងឡាយដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា រាគៈ ដែលគួរលះដោយទស្សនៈ ប្រារព្ធនូវខន្ធនោះ ... ទិដ្ឋិ ... វិចិកិច្ឆា ... ។

[ ៦៧៧ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនា ដោយអារម្មណប្បច្ច័យ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយត្រេកអរ រីករាយ ចំពោះកុសលនោះ រាគៈប្រារព្ធនូវកុសលនោះ ទើបកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សដែលគួរលះដោយភាវនា កើតឡើង នូវកុសលទាំងឡាយដែលធ្លាប់សន្សំមកហើយ ក្នុងកាលមុន ... ចេញអំពីឈាន ... ចំពោះចក្ខុ ... វត្ថុ ... ត្រេកអរចំពោះខន្ធទាំងឡាយ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា រាគៈដែលគួរលះដោយភាវនា ប្រារព្ធនូវខន្ធនោះទើបកើតឡើង ឧទ្ធច្ចៈ

កើតឡើង ទោមនស្សដែលគួរលះដោយភាវនា កើតឡើង ។

[ ៦៧៨ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវរាគៈ ដែលគួរលះដោយទស្សនៈ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈដែលគួរលះដោយទស្សនៈធ្វើនូវរាគៈនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង បុគ្គលធ្វើនូវទិដ្ឋិឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ដែលគួរលះដោយទស្សនៈ ធ្វើនូវទិដ្ឋិនោះឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។ ឯសហជាតាធិបតិ គឺធម៌ជាអធិបតិ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៦៧៩ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺធម៌ជាអធិបតិ ដែលគួរលះដោយទស្សនៈ ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។

[ ៦៨០ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈផង ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺធម៌ជាអធិបតិដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ៦៨១ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនា ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវរាគៈ ដែលគួរលះដោយភាវនាឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈដែលគួរលះដោយភាវនា ធ្វើនូវរាគៈឲ្យជាទីគោរព ទើបកើតឡើង ។ ឯសហជាតាធិបតិ គឺធម៌ជាអធិបតិដែលគួរលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអធិបតិប្បច្ច័យ ។

[ ៦៨២ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលធ្វើនូវរាគៈដែលគួរលះដោយភាវនា ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈដែលគួរលះដោយទស្សនៈ ធ្វើនូវរាគៈនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ៦៨៣ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺធម៌ជាអធិបតិ ដែលគួរលះដោយភាវនា ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។

[ ៦៨៤ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនាផង ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ គឺធម៌ជាអធិបតិដែល

គួរលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ។

[ ៦៨៥ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើនូវឧបោសថកម្ម ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ហើយពិចារណានូវកុសលទាំងឡាយ ដែលធ្លាប់សន្សំមកហើយ ក្នុងកាលមុន ... ចេញអំពីឈាន ធ្វើនូវឈានឲ្យជាទីគោរព ហើយពិចារណា ព្រះអរិយៈទាំងឡាយ ចេញអំពីមគ្គ ធ្វើនូវមគ្គឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវផលឲ្យជាទីគោរព ហើយពិចារណា ធ្វើនូវព្រះនិព្វានឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទាន: មគ្គ និងផល ដោយអធិបតិប្បច្ច័យ ។ ឯសហជាតាធិបតិ គឺធម៌ជាអធិបតិ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។

[ ៦៨៦ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ដែលគួរលះដោយទស្សនៈ ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើត

ឡើង ធ្វើនូវកុសលទាំងឡាយ ដែលធ្លាប់សន្សំមកហើយ ក្នុងកាលមុន ឲ្យជាទីគោរព ... ចេញអំពីឈាន ហើយធ្វើនូវឈានឲ្យជាទីគោរព ... នូវវត្ថុ ធ្វើនូវខន្ធទាំងឡាយ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈដែលគួរលះដោយទស្សនៈ ធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ទិដ្ឋិកើតឡើង ។

[ ៦៨៧ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ( ជាបច្ច័យ ) នៃធម៌ដែលគួរលះដោយភាវនា ... បានដល់ អារម្មណាធិបតិ គឺបុគ្គលឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ហើយត្រេកអរ រីករាយចំពោះកុសលនោះ រាគៈដែលគួរលះដោយភាវនា ធ្វើនូវកុសលនោះ ឲ្យជាទីគោរព ទើបកើតឡើង ក្នុងកាលមុន ។បេ។ ធ្វើនូវខន្ធទាំងឡាយដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈដែលគួរលះដោយភាវនា ធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ទើបកើតឡើង ។

[ ៦៨៨ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយអនន្តរបច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលគួរលះដោយទស្សនៈ ដោយអនន្តរបច្ច័យ ។

[ ៦៨៩ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ... គឺខន្ធទាំងឡាយដែលគួរលះ

ដោយទស្សនៈ ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរូបនិស្សយប្បច្ច័យ ។

[ ៦៩០ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនា ដោយអនន្តរប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលគួរលះដោយភាវនា ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលគួរលះដោយភាវនា ដោយអនន្តរប្បច្ច័យ ។

[ ៦៩១ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអនន្តរប្បច្ច័យ គឺខន្ធទាំងឡាយដែលគួរលះដោយភាវនា ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។

[ ៦៩២ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអនន្តរប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ។បេ។ ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទានៈ ( ជាបច្ច័យ ) នៃមគ្គ មគ្គ ( ជាបច្ច័យ ) នៃផល ផល ( ជាបច្ច័យ ) នៃផល អនុលោម ( ជាបច្ច័យ ) នៃផលសមាបត្តិ នេវសញ្ញានាសញ្ញាយតនៈ របស់បុគ្គល កាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[ ៦៩៣ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា

ជាបច្ច័យនៃធម៌ ដែលគួរលះដោយទស្សនៈ ។បេ។ អាវជ្ជនៈ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលគួរលះដោយទស្សនៈ ដោយអនន្តរប្បច្ច័យ ។

[ ៦៩៤ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលគួរលះដោយភាវនា ដោយអនន្តរប្បច្ច័យ គឺអាវជ្ជនៈ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលគួរលះដោយភាវនា ដោយអនន្តរប្បច្ច័យ ។

[ ៦៩៥ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈដោយសមនន្តរប្បច្ច័យ ។ ប្រហែលគ្នានឹងអនន្តរប្បច្ច័យដែរ ។

[ ៦៩៦ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយសហជាតប្បច្ច័យ គឺមានវារៈ ៣ ។

[ ៦៩៧ ] ធម៌ ដែលគួរលះដោយភាវនា ( ជាបច្ច័យ ) នៃធម៌ដែលគួរលះដោយភាវនា ... គឺមានវារៈ ៣ ។

[ ៦៩៨ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយសហជាតប្បច្ច័យ គឺខន្ធ ១ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយសហ-ជាតប្បច្ច័យ ខន្ធ ២ ... ខន្ធទាំងឡាយជាបច្ច័យនៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ ដោយសហជាតប្បច្ច័យ វត្ថុ ( ជាបច្ច័យ ) នៃខន្ធទាំងឡាយ មហាភូត ១ ( ជាបច្ច័យ ) នៃមហាភូត ៣ មហាភូតទាំងឡាយ ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... របស់ពួក

អសញ្ញសត្វ ... ។

[ ៦៩៩ ] ធម៌ ដែលគួរលះដោយទស្សនៈក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ... គឺខន្ធទាំងឡាយដែលគួរលះដោយទស្សនៈក្តី មហាភូតទាំងឡាយក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។

[ ៧០០ ] ធម៌ ដែលគួរលះដោយភាវនាក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយសហជាតបច្ច័យ គឺខន្ធទាំងឡាយដែលគួរលះដោយភាវនាក្តី មហាភូតទាំងឡាយក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។

[ ៧០១ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលគួរលះដោយទស្សនៈ ដោយអញ្ញមញ្ញបច្ច័យ គឺខន្ធ ១ ដែលគួរលះដោយទស្សនៈ ... ។

[ ៧០២ ] ធម៌ ដែលគួរលះដោយភាវនា ( ជាបច្ច័យ ) នៃធម៌ដែលគួរលះដោយភាវនា ... គឺខន្ធ ១ ដែលគួរលះដោយភាវនា ( ជាបច្ច័យ ) នៃខន្ធ ៣ ។

[ ៧០៣ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ( ជាបច្ច័យ ) នៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ... គឺខន្ធ ១ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា

ជាបច្ច័យនៃខន្ធ ៣ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ... ខន្ធ ១ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃខន្ធ ៣ ផង វត្ថុផងក្នុងខណៈនៃបដិសន្ធិ ដោយអញ្ញមញ្ញប្បច្ច័យ ខន្ធ ២ ... ខន្ធទាំងឡាយ ( ជាបច្ច័យ ) នៃវត្ថុ វត្ថុ ( ជាបច្ច័យ ) នៃខន្ធទាំងឡាយ មហាភូត ១ ជាបច្ច័យនៃមហាភូត ៣ ដោយអញ្ញមញ្ញប្បច្ច័យ របស់ពួកអសញ្ញសត្វ ... ។

[ ៧០៤ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយនិស្សយប្បច្ច័យ គឺមានវារៈ ៣ ។ ដោយភាវនា ... គឺមានវារៈ ៣ ។ ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ( ជាបច្ច័យនៃធម៌ ) ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ។បេ។ គឺខន្ធ ១ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ( ជាបច្ច័យ ) នៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ខន្ធ ២ ... ខន្ធទាំងឡាយ ( ជាបច្ច័យ ) នៃវត្ថុក្នុងខណៈនៃបដិសន្ធិ វត្ថុ ( ជាបច្ច័យ ) នៃខន្ធទាំងឡាយ មហាភូត ១ ... របស់ពួកអសញ្ញសត្វ ... ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ។បេ។ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយ-វិញ្ញាណ វត្ថុ ... ។

[ ៧០៥ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលគួរលះដោយទស្សនៈ ដោយនិស្សយប្បច្ច័យ គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយដែលគួរលះដោយទស្សនៈ ដោយនិស្សយប្បច្ច័យ ។ ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ( ជាបច្ច័យ )

នៃធម៌ដែលគួរលះដោយភាវនា ... គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលគួរលះដោយភាវនា ដោយនិស្សយប្បច្ច័យ ។

[ ៧០៦ ] ធម៌ ដែលគួរលះដោយទស្សនៈក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ ដែលគួរលះដោយទស្សនៈ ដោយនិស្សយប្បច្ច័យ គឺខន្ធ ១ ដែលគួរលះដោយទស្សនៈក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយនិស្សយប្បច្ច័យ ខន្ធ ២ ... ។

[ ៧០៧ ] ធម៌ ដែលគួរលះដោយទស្សនៈក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ... គឺខន្ធទាំងឡាយដែលគួរលះដោយទស្សនៈក្តី មហាភូតទាំងឡាយក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។

[ ៧០៨ ] ធម៌ ដែលគួរលះដោយភាវនាក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនា ដោយនិស្សយប្បច្ច័យ គឺខន្ធ ១ ដែលគួរលះដោយភាវនាក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយនិស្សយប្បច្ច័យ ខន្ធ ២ ... ។

[ ៧០៩ ] ធម៌ ដែលគួរលះដោយភាវនាក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយនិស្សយប្បច្ច័យ គឺខន្ធទាំងឡាយដែលគួរលះដោយភាវនាក្តី មហាភូតទាំងឡាយក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។

[ ៧១០ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរាគៈដែលគួរលះដោយទស្សនៈ ហើយសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនឲ្យ ... បំបែកសង្ឃ នូវទោសៈ ដែលគួរលះដោយទស្សនៈ ... នូវមោហៈ ... នូវទិដ្ឋិ ... អាស្រ័យនូវសេចក្តីប្រាថ្នា ហើយសម្លាប់សត្វ ... បំបែកសង្ឃ រាគៈដែលគួរលះដោយទស្សនៈ ... ទោសៈ មោហៈ ទិដ្ឋិ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ ទិដ្ឋិ និងសេចក្តីប្រាថ្នាដែលគួរលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ ។

[ ៧១១ ] ធម៌ ដែលគួរលះដោយទស្សនៈ ( ជាបច្ច័យ ) នៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ... បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរាគៈដែលគួរលះដោយទស្សនៈ ហើយឲ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ។ សេចក្តីបង្រ្កួញ ។ ញុំាងសមាបត្តិឲ្យកើតឡើង នូវទោសៈដែលគួរលះដោយទស្សនៈ ... អាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យទាន ... ញុំាងសមាបត្តិ ឲ្យកើតឡើង រាគៈដែលគួរលះដោយទស្សនៈ ... ទោសៈ មោហៈ ទិដ្ឋិ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃសទ្ធា បញ្ញា កាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៧១២ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលគួរលះ

ដោយការនៅ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺរាគៈដែលគួរលះដោយភាវនា ... ទោសៈ មោហៈ មានះ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ មានះ និងសេចក្តីប្រាថ្នា ដែលគួរលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ ។

[ ៧១៣ ] ធម៌ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលគួរលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យនិងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរាគៈ ដែលគួរលះដោយភាវនា ហើយសម្លាប់សត្វ ... បំបែកសង្ឃ នូវទោសៈដែលគួរលះដោយភាវនា ... នូវមោហៈ ... នូវមានះ ... អាស្រ័យនូវសេចក្តីប្រាថ្នា ហើយសម្លាប់សត្វ ... បំបែកសង្ឃ រាគៈ ដែលគួរលះដោយភាវនា ... ទោសៈ មោហៈ មានះ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ ទិដ្ឋិ និងសេចក្តីប្រាថ្នាដែលគួរលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ ធនុ-រាគៈក្នុងកណ្ឌៈរបស់ខ្លួន ជាបច្ច័យនៃធនុរាគៈក្នុងកណ្ឌៈនៃបុគ្គលដទៃ ដោយឧបនិស្សយប្បច្ច័យ ធនុរាគៈ ក្នុងទ្រព្យដែលខ្លួនហួងហែងហើយ ជាបច្ច័យនៃធនុរាគៈ ក្នុងទ្រព្យដែលបុគ្គលដទៃហួងហែងហើយ ដោយឧបនិស្សយប្បច្ច័យ ។

[ ៧១៤ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ បានដល់

អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរាគៈដែលគួរលះដោយភាវនាហើយឲ្យទាន ... ញុំាងសមាបត្តិឲ្យកើតឡើង នូវទោសៈដែលគួរលះដោយភាវនា ... នូវមោហៈ ... នូវមានះ ... អាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យទាន ... ញុំាងសមាបត្តិឲ្យកើតឡើង រាគៈដែលគួរលះដោយភាវនា ... ទោសៈ មោហៈ មានះ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃសទ្ធា និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៧១៥ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យទាន ... ញុំាងសមាបត្តិ ឲ្យកើតឡើង នូវសីល ... នូវសុតៈ ចាគៈ បញ្ញា កាយិកសុខ កាយិកទុក្ខ រដូវ ភោជន ... អាស្រ័យនូវសេនាសនៈ ហើយឲ្យទាន ... ញុំាងសមាបត្តិ ឲ្យកើតឡើង សទ្ធា ... សីល សុតៈ ចាគៈ បញ្ញា កាយិកសុខ កាយិកទុក្ខ រដូវ ភោជន ... សេនាសនៈ ជា បច្ច័យនៃសទ្ធា បញ្ញា កាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

[ ៧១៦ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូ-បនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ... ប្រកាន់ទិដ្ឋិ នូវសីល ... អាស្រ័យ

នូវសេនាសនៈ ហើយសម្លាប់សត្វ ... បំបែកសង្ឃ សទ្ធា ... សេនាសនៈ ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដែលគួរលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ ។

[ ៧១៧ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលគួរលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយដំឡើងមានះ នូវសីល ... នូវបញ្ញា កាយិកសុខ កាយិកទុក្ខ រដូវ ភោជន ... អាស្រ័យនូវសេនាសនៈ ហើយដំឡើងមានះ សទ្ធា ... បញ្ញា កាយិកសុខ កាយិកទុក្ខ រដូវ ភោជន ... សេនាសនៈ ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ មានះ និងសេចក្តីប្រាថ្នា ដែលគួរលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ ។

[ ៧១៨ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលឃើញច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន នូវសោតៈ ... នូវឃានៈ ជិវ្ហា កាយ ពួករូប ពួកសំឡេង ពួកក្លិន ពួករស ពួកផោដ្ឋព្វៈ វត្ថុ ... ឃើញរូប ដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺ

ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយបុរេជាតប្បច្ច័យ ។

[ ៧១៩ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលត្រេកអរ រីករាយចំពោះចក្ខុ រាគៈដែលគួរលះដោយទស្សនៈ ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្សដែលគួរលះដោយទស្សនៈ កើតឡើង ។បេ។ បុគ្គលត្រេកអរ រីករាយចំពោះវត្ថុ រាគៈដែលគួរលះដោយទស្សនៈ ប្រារព្ធនូវវត្ថុនោះទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្សដែលគួរលះដោយទស្សនៈកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលគួរលះដោយទស្សនៈ ដោយបុរេជាតប្បច្ច័យ ។

[ ៧២០ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលគួរលះដោយភាវនា ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលត្រេកអរ រីករាយចំពោះចក្ខុ រាគៈដែលគួរលះដោយភាវនា ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សដែលគួរលះដោយភាវនា កើតឡើង នូវសោតៈ ... កាយ ពួករូប ... ពួកផោដ្ឋព្វៈ ... ត្រេកអរ រីករាយ ចំពោះវត្ថុ

រាគៈដែលគួរលះដោយភាវនា ប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្ស ដែលគួរលះដោយភាវនា កើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលគួរលះដោយភាវនា ដោយបុរេជាតប្បច្ច័យ ។

[ ៧២១ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៧២២ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយ ដែលគួរលះដោយភាវនា ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៧២៣ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៧២៤ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលគួរលះ

ដោយទស្សនៈ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ៧២៥ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនា ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលគួរលះដោយភាវនា ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ៧២៦ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដោយអាសេវនប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទាន: គោត្រភូ ( ជាបច្ច័យ ) នៃមគ្គ វោទាន: ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ៧២៧ ] ធម៌ ដែលគួរលះដោយទស្សនៈ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយកម្មប្បច្ច័យ គឺចេតនាដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

[ ៧២៨ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺ ចេតនាដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃពួកវិបាកក្ខន្ធផង ពួកកដត្តារូប

ផង ដោយកម្មប្បច្ច័យ ។

[ ៧២៩ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈផង ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាផង ដោយកម្មប្បច្ច័យ គឺចេតនាដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ៧៣០ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនា ដោយកម្មប្បច្ច័យ គឺចេតនាដែលគួរលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

[ ៧៣១ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយកម្មប្បច្ច័យ គឺចេតនាដែលគួរលះដោយភាវនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយកម្មប្បច្ច័យ ។

[ ៧៣២ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនាផង ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាផង ដោយកម្មប្បច្ច័យ គឺចេតនាដែលគួរលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ៧៣៣ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺ ចេតនា ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃ

ពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ គឺចេតនា ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃពួកសម្ប-យុត្តកក្ខន្ធផង ពួកកដត្តារូបផង ក្នុងខណៈនៃបដិសន្ធិ ។ ឯនានាខណិកៈ គឺ ចេតនាដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃ ពួកវិបាកក្ខន្ធផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ៧៣៤ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយ វិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះ ដោយភាវនា ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយ វិបាកប្បច្ច័យ ខន្ធទាំងឡាយជាបច្ច័យនៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ ដោយ វិបាកប្បច្ច័យ ។

[ ៧៣៥ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះ ដោយទស្សនៈ ដោយអាហារប្បច្ច័យ ។ សេចក្តីបង្រួញ ។ កពឡិង្កា-រាហារ ។ បញ្ហា ៧ ។ ... ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ចក្ខុន្ទ្រិយក្តី រូប-ជីវិតិន្ទ្រិយក្តី ។ បញ្ហា ៧ ។ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យ ដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ជាបច្ច័យដោយវិប្ប-យុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺខន្ធទាំង ឡាយ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយ វិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយដែលគួរលះដោយទស្សនៈ

ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៧៣៦ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ បទនេះប្រហែលគ្នានឹងទស្សនៈដែរ ។

[ ៧៣៧ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃពួកកដត្តារូប ក្នុងខណៈនៃបដិសន្ធិ ដោយវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបុរេជាត គឺចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៧៣៨ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលគួរលះដោយទស្សនៈ ដោយវិប្បយុត្តប្បច្ច័យ បាន

ដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលគួរលះដោយទស្សនៈ ដោយវិប្បយុត្តប្បច្ច័យ ។

[ ៧៣៩ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលគួរលះដោយភាវនា ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលគួរលះដោយភាវនា ដោយវិប្បយុត្តប្បច្ច័យ ។

[ ៧៤០ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។

[ ៧៤១ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ៧៤២ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈផង ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាផង ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ដែលគួរលះដោយទស្សនៈ ( ជាបច្ច័យ ) នៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ខន្ធ ២ ... ។ ធម៌ដែលគួរលះដោយ

ភាវនា ( ជាបច្ច័យ ) នៃធម៌ដែលគួរលះដោយភាវនា ... គឺមានវារៈ ៣ ។ បណ្ឌិតគប្បីធ្វើឲ្យប្រហែលគ្នាដោយទស្សនៈដែរ ។

[ ៧៤៣ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃខន្ធ ៣ ផង ពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ខន្ធទាំងឡាយ ( ជាបច្ច័យ ) នៃវត្ថុ ក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដោយអត្ថិប្បច្ច័យ មហាភូត ១ ។ សេចក្តីបន្រ្ទញ ។ មហាភូត ១ របស់ពួកអសញ្ញសត្វ ... ។ ឯបុរេជាត គឺបុគ្គលឃើញច្បាស់នូវចក្ខុ ជាមិនទៀង ជាទុក្ខ មិនមែនខ្លួន នូវសោតៈ ... កាយ ពួករូប ... ពួកផោដ្ឋព្វៈ ... ឃើញច្បាស់នូវវត្ថុ ជាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឃើញនូវរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយ-វិញ្ញាណ ចក្ខាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ( ជា

បច្ច័យ ) នៃកាយនេះ រូបជីវិតិន្ទ្រិយ ( ជាបច្ច័យ ) នៃពួកកដត្តារូប ។

[ ៧៨៤ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលគួរលះដោយទស្សនៈ ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺបុគ្គលត្រេកអរ រីករាយ ចំពោះចក្ខុ រាគៈដែលគួរលះដោយទស្សនៈ ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្សកើតឡើង ចំពោះសោតៈ ... បុគ្គលត្រេកអរចំពោះវត្ថុ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលគួរលះដោយទស្សនៈ ដោយអត្ថិប្បច្ច័យ ។

[ ៧៨៥ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនា ដោយអត្ថិប្បច្ច័យ បានដល់ បុរេ-ជាត គឺបុគ្គលត្រេកអរ រីករាយចំពោះចក្ខុ រាគៈដែលគួរលះដោយភាវនា ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង ទោមនស្សដែលគួរលះដោយភាវនា ... ចំពោះសោតៈ ... បុគ្គលត្រេកអរ រីករាយ ចំពោះវត្ថុ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលគួរលះដោយភាវនា ដោយអត្ថិប្បច្ច័យ ។

[ ៧៨៦ ] ធម៌ ដែលគួរលះដោយទស្សនៈក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលគួរលះដោយទស្សនៈក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ក្តី វត្ថុក្តី ... ។

[ ៧៨៧ ] ធម៌ ដែលគួរលះដោយទស្សនៈក្តី ធម៌ដែលមិនគួរលះដោយ

ទស្សនៈ មិនគួរលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺខន្ធទាំងឡាយដែលគួរលះដោយទស្សនៈក្តី មហាភូតទាំងឡាយក្តី ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលគួរលះដោយទស្សនៈក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលគួរលះដោយទស្សនៈក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[ ៧៤៨ ] ធម៌ ដែលគួរលះដោយភាវនាក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលគួរលះដោយភាវនា ... ។បេ។ បញ្ហា ២ គប្បីធ្វើចុះ ។

[ ៧៤៩ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយនត្ថិប្បច្ច័យ ជាបច្ច័យដោយវិគតប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។

[ ៧៥០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៨ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៨ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុង

បច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៧៥១ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៧៥២ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ៧៥៣ ] ធម៌ ដែលគួរលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈផង ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាផង ដោយសហជាតប្បច្ច័យ ។

[ ៧៥៤ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនា ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៧៥៥ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៧៥៦ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។

[ ៧៥៧ ] ធម៌ ដែលគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនាផង ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាផង ដោយសហជាតប្បច្ច័យ ។

[ ៧៥៨ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ៧៥៩ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា

ជាបច្ច័យនៃធម៌ដែលគួរលះដោយទស្សនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ៧៦០ ] ធម៌ ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាបច្ច័យនៃធម៌ដែលគួរលះដោយភាវនា ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ៧៦១ ] ធម៌ ដែលគួរលះដោយទស្សនៈក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលគួរលះដោយទស្សនៈ ... បានដល់ សហជាត និងបុរេជាត ។

[ ៧៦២ ] ធម៌ ដែលគួរលះដោយទស្សនៈក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ... បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ៧៦៣ ] ធម៌ ដែលគួរលះដោយភាវនាក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលគួរលះដោយភាវនា ... បានដល់ សហជាត និងបុរេជាត ។

[ ៧៦៤ ] ធម៌ ដែលគួរលះដោយភាវនាក្តី ធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ... បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ៧៦៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៤ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៤ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១៤ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១៤ ក្នុងនសហជាតប្បច្ច័យ មានវារៈ ១០ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១០ ក្នុងននិស្សយប្បច្ច័យ មានវារៈ ១០ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១៤ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៤ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៤ ក្នុងនកម្មប្បច្ច័យ មានវារៈ ១៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១៤ ក្នុងនអាហារប្បច្ច័យ មានវារៈ ១៤ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១៤ ក្នុងនឈានប្បច្ច័យ មានវារៈ ១៤ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១០ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៨ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៨ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១៤ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៨ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយៈ ចប់

[ ៧៦៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុង

នសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៧ ក្នុងនកម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៧ ក្នុងនអាហារប្បច្ច័យ មានវារៈ ៧ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងនឈានប្បច្ច័យ មានវារៈ ៧ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ៧៦៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៨ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៨ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុង

កម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

ទស្សនត្តិកៈទី ៨ ចប់

# អដ្ឋកថា

## ទស្សនត្តិកៈ

[ ៥៧៨-៧៦៧ ] ក្នុងទស្សនត្តិកៈ បទទាំងឡាយថា **ទស្សនេន បហាតព្វោ រាគោ ឧប្បជ្ជតិ**[១] ជាដើម អ្នកសិក្សាគប្បីជ្រាបថា ធម៌ដែលកើតឡើងដល់ព្រះអរិយបុគ្គលខាងក្រោម រមែងមិនកើតឡើងដល់ព្រះអរិយបុគ្គលខាងលើយ៉ាងនេះ គឺរាគៈគប្បីលះដោយទស្សនៈ ( សោតាបត្តិមគ្គ ) រមែងកើតដល់បុថុជ្ជន រាគៈដែលគប្បីលះដោយភាវនា ( មគ្គខាងលើ ៣ ) រមែងកើតដល់ព្រះសោតាបន្នក៏បាន ធម៌ដែលគប្បីលះដោយទស្សនៈ រមែងមិនជាបច្ច័យដល់ធម៌ដែលគប្បីលះដោយភាវនាដោយបច្ច័យណាមួយ ។ ពាក្យដ៏សេសក្នុងអធិការនេះ អ្នកសិក្សាគប្បីពិនិត្យពិច័យតាមបាលី ហើយជ្រាបដោយអំណាចនៃលក្ខណៈ ដែលពោលក្នុងកុសលត្តិកៈ ។ល។

**អដ្ឋកថាទស្សនត្តិកៈ ចប់**

---

១- បិដកខ្មែរ លេខឃ្នាប ៦៧០ ។

# អភិធម្មបិដក

## បដ្ឋាន បញ្ចមភាគ

## ឧស្សនេនបហាតព្វហេតុកត្តិកៈ

## បដិច្ចវារៈ

[ ១ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានហេតុត្រូវលះដោយទស្សនៈ ... ខន្ធ ២ ។ ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈ ។ ធម៌ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី អាស្រ័យធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានហេតុត្រូវលះដោយទស្សនៈ អាស្រ័យខន្ធ ២ ។

[ ២ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា អាស្រ័យធម៌ ដែលមានហេតុត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានហេតុត្រូវលះដោយភាវនា ... ខន្ធ ២ ។ ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យ

ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយភាវនា ។ ធម៌ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានហេតុត្រូវលះដោយភាវនា ... ខន្ធ ២ ។

[ ៣ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ចិត្តសមុដ្ឋានរូប អាស្រ័យមោហៈ ដែលប្រកបដោយវិចិកិច្ឆា ក្នុងខណៈនៃបដិសន្ធិ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... ខន្ធ ២ វត្ថុ អាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយអាស្រ័យវត្ថុ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យមហាភូត ១ អាស្រ័យមហាភូតទាំងឡាយ ។ ធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ អាស្រ័យធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពួកសម្ប-

យុត្តកក្ខន្ធ អាស្រ័យមោហៈ ដែលប្រកបដោយវិចិកិច្ឆា ធម៌ដែលមានហេតុត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យមោហៈ ដែលប្រកបដោយឧទ្ធច្ចៈ ។ ធម៌ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី អាស្រ័យធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យមោហៈដែលប្រកបដោយវិចិកិច្ឆា ។ ធម៌ដែលមានហេតុត្រូវលះដោយភាវនាក្តី ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី អាស្រ័យធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... គឺពួកសម្បយុត្តកក្ខន្ធក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យមោហៈដែលប្រកបដោយឧទ្ធច្ចៈ ។

[ ៤ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង ខន្ធ ២ អាស្រ័យខន្ធ ២ ផង មោហៈផង ។ ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំង

ឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈផង មហាភូតទាំងឡាយផង ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង ។ ធម៌ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង អាស្រ័យខន្ធ ២ ផង មោហៈផង ... ។

[ ៥ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រកបដោយឧទ្ធច្ចៈផង មោហៈផង ខន្ធ ២ អាស្រ័យខន្ធ ២ ផង មោហៈផង ។ ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយភាវនាផង មហាភូតទាំងឡាយផង ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយឧទ្ធច្ចៈផង មោហៈផង ។ ធម៌ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី អាស្រ័យធម៌ ដែលមាន

ហេតុ ត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយឧទ្ធច្ចៈផង មោហៈផង ។

[ ៦ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានហេតុត្រូវលះដោយទស្សនៈ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ទើបកើតឡើងព្រោះអារម្មណប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា អាស្រ័យខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆា ។ ធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង អាស្រ័យធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ... ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ក្តី មោហៈក្តី អាស្រ័យខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ខន្ធ ២ ក្តី មោហៈក្តី អាស្រ័យខន្ធ ២ ។

[ ៧ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ( បានដល់ ពាក្យបុច្ឆា និងវិសជ្ជនា ) ៣ លើក ។ ( ដំណើរនេះ ) បណ្ឌិតគប្បីចែកដូចជាទស្សនៈដែរ ។

[ ៨ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះ

ដោយភាវនា អាស្រ័យធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ខន្ធ ២ អាស្រ័យខន្ធ ២ ខន្ធទាំងឡាយអាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ៩ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ អាស្រ័យធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យមោហៈ ដែលច្រឡំដោយវិចិកិច្ឆា ។

[ ១០ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា អាស្រ័យធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... ព្រោះអារម្មណប្បច្ច័យ គឺពួកសម្បយុត្តកក្ខន្ធ អាស្រ័យមោហៈ ដែលច្រឡំដោយឧទ្ធច្ចៈ ។

[ ១១ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលច្រឡំដោយវិចិកិច្ឆាផង មោហៈផង ខន្ធ ២ អាស្រ័យខន្ធ ២ ផង មោហៈផង ។

[ ១២ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា អាស្រ័យធម៌ ដែល

មានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈមិនត្រូវលះដោយភាវនាផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលប្រឡំដោយឧទ្ធច្ចៈផង មោហៈផង ខន្ធ ២ អាស្រ័យខន្ធ ២ ផង មោហៈផង ។

[ ១៣ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ទើបកើតឡើងព្រោះអធិបតិប្បច្ច័យ ( បានដល់ ពាក្យបុច្ឆា និងវិសជ្ជនា ) ៣ លើក ។ ( វារៈនេះ ) ដូចគ្នានឹងហេតុប្បច្ច័យ ។ អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយភាវនា ... ( បានដល់ ពាក្យបុច្ឆា និងវិសជ្ជនា ) ៣ លើក ។ ( វារៈនេះ ) ដូចគ្នានឹងហេតុប្បច្ច័យ ។ មោហៈ មិនមានក្នុងអធិបតិប្បច្ច័យទេ ។

[ ១៤ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... ខន្ធ ២ មហាភូតរូប ៣ អាស្រ័យមហាភូតរូប ១ ចិត្តសមុដ្ឋានរូប ឧបាទារូប អាស្រ័យមហាភូតរូបទាំងឡាយ ។

[ ១៥ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... ព្រោះ

អធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈផង មហាភូតរូបទាំងឡាយផង ។

[ ១៦ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យធម៌ ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយភាវនាផង មហាភូតរូបទាំងឡាយផង ។ ដោយទស្សនៈមិនត្រូវលះដោយភាវនា ។បេ។ ព្រោះអនន្តរប្បច្ច័យ ព្រោះសមនន្តរប្បច្ច័យ ។ ( ពាក្យនេះ ) ដូចគ្នានឹងអារម្មណប្បច្ច័យ ។

[ ១៧ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានហេតុត្រូវលះដោយទស្សនៈ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ... ព្រោះសហជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលមានហេតុត្រូវលះដោយទស្សនៈ មោហៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆា ។ ធម៌ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ... ព្រោះសហជាតប្បច្ច័យ គឺខន្ធ

៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានហេតុត្រូវលះដោយទស្សនៈ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី មោហៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលប្រឡំដោយវិចិកិច្ឆា ។

[ ១៨ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា អាស្រ័យធម៌ ដែលមានហេតុត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានហេតុត្រូវលះដោយភាវនា ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយភាវនា ... ព្រោះសហជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលមានហេតុត្រូវលះដោយភាវនា មោហៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធទាំងឡាយដែលប្រឡំដោយឧទ្ធច្ចៈ ។ ធម៌ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី អាស្រ័យធម៌ដែលមានហេតុត្រូវលះដោយភាវនា ... ព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានហេតុត្រូវលះដោយភាវនា ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ខន្ធ ៣ ក្តី មោហៈក្តី ចិត្ត-សមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលប្រឡំដោយឧទ្ធច្ចៈ ។

[ ១៩ ] ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អាស្រ័យធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... ព្រោះសហជាតប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី

[ ១១៧ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ត្រេកអរ រីករាយ ចំពោះរាគៈ ដែលមានហេតុត្រូវលះដោយទស្សនៈ រាគៈដែលមានហេតុត្រូវលះដោយទស្សនៈ ប្រារព្ធនូវរាគៈនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្ស ដែលមានហេតុត្រូវលះដោយទស្សនៈកើតឡើង ( បុគ្គល ) ត្រេកអរ រីករាយ ចំពោះទិដ្ឋិ រាគៈដែលមានហេតុត្រូវលះដោយទស្សនៈ ប្រារព្ធនូវទិដ្ឋិនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្ស ដែលមានហេតុត្រូវលះដោយទស្សនៈកើតឡើង វិចិកិច្ឆាប្រារព្ធនូវវិចិកិច្ឆាទើបកើតឡើង ទិដ្ឋិកើតឡើង ទោមនស្សដែលមានហេតុត្រូវលះដោយទស្សនៈ កើតឡើង ទោមនស្សដែលមានហេតុត្រូវលះដោយទស្សនៈ ប្រារព្ធនូវទោមនស្ស ដែលមានហេតុត្រូវលះដោយទស្សនៈ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ។

[ ១១៨ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយ

អារម្មណប្បច្ច័យ គឺពួកព្រះអរិយៈ ពិចារណាពួកកិលេស ដែលមានហេតុត្រូវលះដោយទស្សនៈ ដែលលះបង់ហើយ នូវពួកកិលេស ដែលសង្កត់សង្កិនហើយ ... ក្នុងកាលមុន ។បេ។ ( ពិចារណា ) នូវពួកខន្ធ ដែលមានហេតុត្រូវលះដោយទស្សនៈ ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ... ដោយចេតោបរិយញ្ញាណ ពួកខន្ធដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ អនាគតំសញ្ញាណ និងមោហៈ ដោយអារម្មណប្បច្ច័យ ។

[ ១១៩ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈផង ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺពួកខន្ធ ដែលប្រឡំដោយវិចិកិច្ឆាក្តី មោហៈក្តី ប្រារព្ធនូវពួកខន្ធ ដែលមានហេតុត្រូវលះដោយទស្សនៈ ទើបកើតឡើង ។

[ ១២០ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនា ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ត្រេកអរ រីករាយ ចំពោះរាគៈ ដែលមានហេតុត្រូវលះដោយភាវនា រាគៈដែលមានហេតុត្រូវលះដោយភាវនា ប្រារព្ធនូវរាគៈនោះ ទើបកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សដែលមានហេតុត្រូវលះដោយភាវនា កើតឡើង ឧទ្ធច្ចៈប្រារព្ធនូវឧទ្ធច្ចៈ ទើបកើតឡើង ទោមនស្ស ដែលមានហេតុត្រូវលះដោយភាវនាកើតឡើង ទោមនស្សដែលមានហេតុត្រូវលះដោយភាវនា ប្រារព្ធនូវ

ទោមនស្ស ដែលមានហេតុត្រូវលះដោយភាវនា ទើបកើតឡើង ឧទ្ធច្ចៈកើតឡើង ។

[ ១២១ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ... គឺ ( បុគ្គល ) ត្រេកអរ រីករាយចំពោះរាគៈដែលមានហេតុត្រូវលះដោយភាវនា រាគៈដែលមានហេតុត្រូវលះដោយទស្សនៈ ប្រារព្ធនូវរាគៈនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្សដែលមានហេតុត្រូវលះដោយទស្សនៈ កើតឡើង ទិដ្ឋិប្រារព្ធនូវឧទ្ធច្ចៈ ទើបកើតឡើង វិចិកិច្ឆាកើតឡើង ទោមនស្ស ដែលមានហេតុត្រូវលះដោយទស្សនៈ កើតឡើង ទោមនស្ស ដែលមានហេតុត្រូវលះដោយទស្សនៈ ប្រារព្ធនូវទោមនស្ស ដែលមានហេតុត្រូវលះដោយភាវនា ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ។

[ ១២២ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... គឺពួកព្រះអរិយបុគ្គល ពិចារណានូវកិលេស ដែលមានហេតុត្រូវលះដោយភាវនាដែលលះបង់ហើយ នូវកិលេសដែលសង្កត់សង្កិនហើយ ... ( ពួកកិលេស ) ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ... ពួកខន្ធដែលមានហេតុត្រូវលះដោយភាវនា ជាមិនទៀង ... ពួកខន្ធដែលមានហេតុត្រូវលះដោយភាវនា ដោយចេតោបរិយញ្ញាណ ជាបច្ច័យនៃការពិចារណានូវចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ អនាគតំសញ្ញាណ និងមោហៈ

ដោយអារម្មណប្បច្ច័យ ។

[ ១២៣ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយដែលប្រទូំដោយវិចិកិច្ឆាក្តី មោហៈក្តី ប្រារព្ធនូវខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយភាវនា ទើបកើតឡើង ។

[ ១២៤ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ( ជាបច្ច័យ ) នៃធម៌ ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធទាំងឡាយ ដែលប្រទូំដោយឧទ្ធច្ចៈក្តី មោហៈក្តី ប្រារព្ធនូវខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយភាវនា ទើបកើតឡើង ។

[ ១២៥ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ឲ្យទាន ... ។ ( ពាក្យនេះ ) ប្រាកដស្មើដោយទស្សនត្តិកៈដែលបណ្ឌិតគប្បីឲ្យពិស្តារ ។ ... ជាបច្ច័យនៃការពិចារណាផង នៃមោហៈផង ដោយអារម្មណប្បច្ច័យ ។

[ ១២៦ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ឲ្យទាន ... ។ ដូចទស្សនត្តិកៈ ។

[ ១២៧ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយភាវនា ដោយអារម្មណប្បច្ច័យ គឺ ( បុគ្គល ) ឲ្យទាន ... ។ ដូចទស្សនត្តិកៈ ។

[ ១២៨ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធទាំងឡាយដែលប្រឡំដោយវិចិកិច្ឆាក្តី មោហៈក្តី ប្រារព្ធនូវចក្ខុ ទើបកើតឡើងនូវសោតៈ ... នូវវត្ថុ ... ខន្ធទាំងឡាយ ដែលប្រឡំដោយវិចិកិច្ឆាក្តី មោហៈក្តី ប្រារព្ធនូវខន្ធទាំងឡាយ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ទើបកើតឡើង ។

[ ១២៩ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយដែលប្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ប្រារព្ធនូវចក្ខុ ... នូវវត្ថុ ... នូវខន្ធទាំងឡាយ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ទើបកើតឡើង ។

[ ១៣០ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ... គឺខន្ធទាំងឡាយ ដែលមានហេតុត្រូវលះ

ដោយទស្សនៈ ប្រារព្ធនូវខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង ទើបកើតឡើង ។

[ ១៣១ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី មោហៈក្តី ប្រារព្ធនូវខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង ទើបកើតឡើង ។

[ ១៣២ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ប្រារព្ធនូវខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង ទើបកើតឡើង ។

[ ១៣៣ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ គឺខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈ ប្រារព្ធនូវខន្ធទាំងឡាយ ដែលប្រកបដោយឧទ្ធច្ចៈផង មោហៈផង ទើបកើតឡើង ។

[ ១៣៤ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនា គឺខន្ធទាំងឡាយដែលមានហេតុត្រូវលះដោយភាវនា ប្រារព្ធនូវខន្ធទាំងឡាយដែលប្រកបដោយឧទ្ធច្ចៈផង មោហៈផង ទើបកើតឡើង ។

[ ១៣៥ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... គឺខន្ធទាំងឡាយ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី មោហៈក្តី ប្រារព្ធនូវខន្ធទាំងឡាយ ដែលប្រកបដោយឧទ្ធច្ចៈផង មោហៈផង ទើបកើតឡើង ។

[ ១៣៦ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ប្រារព្ធនូវខន្ធទាំងឡាយ ដែលប្រកបដោយឧទ្ធច្ចៈផង មោហៈផង ទើបកើតឡើង ។

[ ១៣៧ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែល

មានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធទាំងឡាយ ដែលប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ប្រារព្ធនូវខន្ធទាំងឡាយ ដែលប្រកបដោយឧទ្ធច្ចៈផង មោហៈផង ទើបកើតឡើង ។

[ ១៣៨ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអធិបតិប្បច្ច័យ ។ ( ពាក្យនេះ ) ប្រាកដស្មើដោយទស្សនត្តិកៈដែរ ។ ប្រស្នា ១០ យ៉ាង ។

[ ១៣៩ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអនន្តរប្បច្ច័យ គឺខន្ធទាំងឡាយ មុនៗ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃខន្ធទាំងឡាយ ក្រោយៗ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអនន្តរប្បច្ច័យ ។

[ ១៤០ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយអនន្តរប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិចិកិច្ឆា ជាបច្ច័យនៃមោហៈក្រោយៗ ដោយអនន្តរប្បច្ច័យ ខន្ធទាំងឡាយដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃវុដ្ឋានៈ ( ការចេញ ) ដោយអនន្តរប្បច្ច័យ ។

[ ១៤១ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអនន្តរប្បច្ច័យ គឺខន្ធទាំងឡាយ

មុនៗ ដែលប្រឡំដោយវិចិកិច្ឆា ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រឡំដោយវិចិកិច្ឆាផង មោហៈផង ដោយអនន្តរប្បច្ច័យ ។

[ ១៤២ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនា ដោយអនន្តរប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមានហេតុត្រូវលះដោយភាវនា ដោយអនន្តរប្បច្ច័យ ។

[ ១៤៣ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... គឺខន្ធទាំងឡាយមុនៗ ដែលប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈក្រោយៗ ដោយអនន្តរប្បច្ច័យ ខន្ធទាំងឡាយដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។

[ ១៤៤ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធទាំងឡាយមុនៗ ដែលប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រឡំដោយឧទ្ធច្ចៈផង មោហៈផង ដោយអនន្តរប្បច្ច័យ ។

[ ១៤៥ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... គឺមោហៈមុនៗ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយ

ឧទ្ធច្ចៈ ជាបច្ច័យនៃមោហៈក្រោយៗ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ ខន្ធទាំងឡាយមុនៗ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយអនន្តរប្បច្ច័យ អនុលោម ( ជាបច្ច័យ ) នៃគោត្រភូ អនុលោម ( ជាបច្ច័យ ) នៃវោទានៈ ។ សេចក្តីបង្រួញ ។ នេវសញ្ញានាសញ្ញាយតនៈ ( របស់ព្រះអរិយបុគ្គល ) កាលចេញអំពីនិរោធ ជាបច្ច័យនៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[ ១៤៦ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ... គឺមោហៈមុនៗ ដែលប្រឡំដោយវិចិកិច្ឆា ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រឡំដោយវិចិកិច្ឆា ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ( ការពិចារណា ) ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអនន្តរប្បច្ច័យ ។

[ ១៤៧ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនា ... គឺមោហៈមុនៗ ដែលប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រឡំដោយឧទ្ធច្ចៈ ដោយអនន្តរប្បច្ច័យ អាវជ្ជនៈជាបច្ច័យនៃខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយភាវនា ដោយអនន្តរប្បច្ច័យ ។

[ ១៤៨ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺមោហៈមុនៗ ដែលប្រកបដោយវិចិកិច្ឆា ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង ដោយអនន្តរប្បច្ច័យ អាវជ្ជនៈ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង ដោយអនន្តរប្បច្ច័យ ។

[ ១៤៩ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺមោហៈមុនៗ ដែលប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយឧទ្ធច្ចៈផង មោហៈផង ដោយអនន្តរប្បច្ច័យ អាវជ្ជនៈជាបច្ច័យនៃខន្ធទាំងឡាយដែលប្រកបដោយឧទ្ធច្ចៈផង មោហៈផង ដោយអនន្តរប្បច្ច័យ ។

[ ១៥០ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអនន្តរប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិចិកិច្ឆា ដោយអនន្តរប្បច្ច័យ ។

[ ១៥១ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុ

មិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃមោហៈក្រោយៗ ដោយអនន្តរប្បច្ច័យ ខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃវុដ្ឋានៈ ដោយអនន្តរប្បច្ច័យ ។

[ ១៥២ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង ដោយអនន្តរប្បច្ច័យ ។

[ ១៥៣ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនា ដោយអនន្តរប្បច្ច័យ ( បានដល់ ពាក្យបុច្ឆានិងវិសជ្ជនា ) ៣ លើក ។ ដំណើរ ( នេះ ) ប្រាកដស្មើដោយទស្សនៈដែរ ។

[ ១៥៤ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយសមនន្តរប្បច្ច័យ ។ ( ពាក្យនេះ ) ប្រាកដស្មើដោយអនន្តរប្បច្ច័យដែរ ។ ជាបច្ច័យ ដោយសហជា-

តប្បច្ច័យ ។ សេចក្តីបង្រួញ ។ ( ពាក្យនេះ ) ប្រាកដស្មើដោយសហជាតប្បច្ច័យ ក្នុងបដិច្ចវារៈដែរ ។ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ។ សេចក្តីបង្រួញ ។ ( ពាក្យនេះ ) ប្រាកដស្មើដោយអញ្ញមញ្ញប្បច្ច័យ ក្នុងបដិច្ចវារៈដែរ ។ ជាបច្ច័យដោយនិស្សយប្បច្ច័យ ។ សេចក្តីបង្រួញ ។ ( ពាក្យនេះ ) ប្រាកដស្មើដោយនិស្សយវារៈ ក្នុងបច្ចយវារៈដែរ ។ តំណាផ្សេងគ្នា ( នៃធម៌ទាំងនោះ ) មិនមានទេ ។

[ ១៥៥ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរាគៈ ដែលមានហេតុត្រូវលះដោយទស្សនៈ ហើយសម្លាប់សត្វ ... បំបែកសង្ឃ នូវទោសៈដែលមានហេតុត្រូវលះដោយទស្សនៈ ... នូវមោហៈ ... នូវទិដ្ឋិ ... អាស្រ័យនូវសេចក្តីប្រាថ្នា ហើយសម្លាប់សត្វ ... បំបែកសង្ឃ រាគៈដែលមានហេតុត្រូវលះដោយទស្សនៈ ... ទោសៈ មោហៈ ទិដ្ឋិ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃរាគៈ និងសេចក្តីប្រាថ្នា ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៥៦ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរាគៈ ដែលមានហេតុត្រូវលះដោយទស្សនៈ

ហើយឲ្យទាន ... ញុំាងសមាបត្តិឲ្យកើតឡើង នូវទោសៈដែលមានហេតុត្រូវលះដោយទស្សនៈ ... នូវមោហៈ ... នូវទិដ្ឋិ ... អាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យទាន ... ញុំាងសមាបត្តិឲ្យកើតឡើង រាគៈដែលមានហេតុត្រូវលះដោយទស្សនៈ ... សេចក្តីប្រាថ្នាជាបច្ច័យនៃសទ្ធា បញ្ញា កាយិកសុខ កាយិកទុក្ខ ផលសមាបត្តិ និងមោហៈ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៥៧ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺរាគៈដែលមានហេតុត្រូវលះដោយទស្សនៈ ... ទោសៈ មោហៈ ទិដ្ឋិ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ១៥៨ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺរាគៈ ដែលមានហេតុត្រូវលះដោយភាវនា ... ទោសៈ មោហៈ មានះ ... សេចក្តីប្រាថ្នា ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ មានះ និងសេចក្តីប្រាថ្នា ដែលមានហេតុត្រូវលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ ។

[ ១៥៩ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌

ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរាគៈដែលមានហេតុត្រូវលះដោយភាវនា ហើយសម្លាប់សត្វ ... បំបែកសង្ឃ នូវទោសៈដែលមានហេតុត្រូវលះដោយភាវនា ... នូវមោហៈ ... នូវមានះ អាស្រ័យនូវសេចក្តីប្រាថ្នា ហើយសម្លាប់សត្វ ... បំបែកសង្ឃ រាគៈដែលមានហេតុត្រូវលះដោយភាវនា ... សេចក្តីប្រាថ្នា ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ ទិដ្ឋិ និងសេចក្តីប្រាថ្នា ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ ឆន្ទរាគៈ ក្នុងទ្រព្យរបស់ខ្លួន ជាបច្ច័យនៃឆន្ទរាគៈក្នុងទ្រព្យរបស់បុគ្គលដទៃ ដោយឧបនិស្សយប្បច្ច័យ ឆន្ទ-រាគៈក្នុងការហួងហែងរបស់ខ្លួន ជាបច្ច័យនៃឆន្ទរាគៈក្នុងការហួងហែង របស់បុគ្គលដទៃ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៦០ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បក-តូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវរាគៈ ដែលមានហេតុត្រូវលះដោយភាវនា ហើយឲ្យទាន ... ញ៉ាំងសមាបត្តិឲ្យកើតឡើង នូវទោសៈ ដែលមានហេតុត្រូវលះដោយភាវនា ... នូវមោហៈ ... នូវមានះ ... អាស្រ័យនូវសេចក្តីប្រាថ្នា ហើយឲ្យទាន ... ញ៉ាំងសមាបត្តិឲ្យកើតឡើង រាគៈ ដែលមានហេតុត្រូវលះដោយភាវនា ... សេចក្តីប្រាថ្នាជាបច្ច័យនៃសទ្ធាបញ្ញា កាយិកសុខ កាយិកទុក្ខ

ផលសមាបត្តិ និងមោហៈ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៦១ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ( ជាបច្ច័យ ) នៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... បកតូបនិស្ស័យ គឺរាគៈដែលមានហេតុត្រូវលះដោយភាវនា ... សេចក្តីប្រាថ្នា ជាបច្ច័យនៃខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆាផង មោហៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ១៦២ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយឧបនិស្សយប្បច្ច័យ បានដល់អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺរាគៈដែលមានហេតុត្រូវលះដោយភាវនា ... សេចក្តីប្រាថ្នា ជាបច្ច័យនៃខន្ធទាំងឡាយដែលប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ១៦៣ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូប-និស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ហើយឲ្យទាន ... ញុំាងសមាបត្តិឲ្យកើតឡើង នូវសីល ... នូវបញ្ញា កាយិកសុខ កាយិកទុក្ខ ឧតុ ភោជន សេនាសនៈ ... អាស្រ័យនូវមោហៈ ហើយឲ្យទាន ... សទ្ធា ... មោហៈ ជាបច្ច័យនៃសទ្ធា នៃផល-

សមាបត្តិ និងមោហៈ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៦៤ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសទ្ធា ... ប្រកាន់ទិដ្ឋិ នូវសីល ... នូវបញ្ញា នូវកាយិកសុខ នូវកាយិកទុក្ខ នូវសេនាសនៈ ... អាស្រ័យនូវមោហៈហើយសម្លាប់សត្វ ... បំបែកសង្ឃ សទ្ធា ... សេនាសនៈ ... និងមោហៈ ជាបច្ច័យនៃរាគៈ និងសេចក្ដីប្រាថ្នា ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៦៥ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបុគ្គលអាស្រ័យសទ្ធា ... ដំឡើងមានះ អាស្រ័យមោហៈ ដំឡើងមានះ សទ្ធា ... សេនាសនៈ ... និងមោហៈ ជាបច្ច័យនៃរាគៈ និងសេចក្ដីប្រាថ្នា ដែលមានហេតុត្រូវលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ ។

[ ១៦៦ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយ

ឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធា ... បញ្ញា កាយិកសុខ កាយិកទុក្ខ សេនាសនៈ ... និងមោហៈ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ១៦៧ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺសទ្ធា ... សេនាសនៈ ... និងមោហៈជាបច្ច័យនៃខន្ធទាំងឡាយដែលប្រកបដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ១៦៨ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃរាគៈនៃសេចក្តីប្រាថ្នាដែលមានហេតុត្រូវលះដោយទស្សនៈ ដោយឧបនិស្សយប្បច្ច័យ ។

[ ១៦៩ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយឧប-

និស្ស្រយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បក-តូបនិស្ស័យ គឺខន្ធទាំងឡាយដែលប្រឡំដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃសទ្ធា បញ្ញា កាយិកសុខ កាយិកទុក្ខ ផលសមាបត្តិផង នៃមោហៈផង ដោយឧបនិស្ស្រយប្បច្ច័យ ។

[ ១៧០ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈមិនត្រូវលះដោយភាវនាផង ដោយឧបនិស្ស្រយប្បច្ច័យ បានដល់ អនន្ត-រូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺខន្ធទាំងឡាយ ដែលប្រឡំដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រឡំដោយវិចិកិច្ឆាផង នៃមោហៈផង ដោយឧបនិស្ស្រយប្បច្ច័យ ។

[ ១៧១ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយឧបនិស្ស្រយប្បច្ច័យ បានដល់ អនន្ត-រូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺខន្ធទាំងឡាយ ដែលប្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃរាគៈ នៃសេចក្តីប្រាថ្នាដែលមានហេតុត្រូវលះដោយទស្សនៈ ដោយឧបនិស្ស្រយប្បច្ច័យ ។

[ ១៧២ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែល

មានហេតុត្រូវលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺខន្ធទាំងឡាយ ដែលប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃរាគៈ នៃសេចក្តីប្រាថ្នាដែលមានហេតុត្រូវលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ ។

[ ១៧៣ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺខន្ធទាំងឡាយដែលប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃសទ្ធា នៃផលសមាបត្តិផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ១៧៤ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធទាំងឡាយ ដែលប្រកបដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ១៧៥ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ

មិនត្រូវលះដោយភាវនាផង ដោយឧបនិស្សយប្បច្ច័យ បានដល់ អនន្តរូប-និស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺខន្ធទាំងឡាយដែលប្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃខន្ធទាំងឡាយដែលប្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយឧបនិស្សយប្បច្ច័យ ។

[ ១៧៦ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលឃើញច្បាស់នូវចក្ខុ ថាមិនទៀង ... ឃើញច្បាស់នូវសោតៈ ... នូវវត្ថុ ថាមិនទៀង ... នូវរូបដោយចក្ខុដូចជាទិព្វ ... ដោយទិព្វសោតធាតុ ... រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខាយតនៈ ... កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង នៃមោហៈផង ដោយបុរេជាតប្បច្ច័យ ។

[ ១៧៧ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណ-បុរេជាត គឺបុគ្គលត្រេកអរ រីករាយ ចំពោះចក្ខុ ... ចំពោះវត្ថុ រាគៈដែលមានហេតុត្រូវលះដោយទស្សនៈ ប្រារព្ធនូវចក្ខុនោះ ... ទិដ្ឋិ ... វិចិកិច្ឆា ... ទោមនស្ស

ដែលមានហេតុត្រូវលះដោយទស្សនៈ កើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជា បច្ច័យនៃខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយ បុរេជាតប្បច្ច័យ ។

[ ១៧៨ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះ ដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយភាវនា ដោយ បុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណ-បុរេជាត គឺបុគ្គលត្រេកអរ រីករាយចំពោះចក្ខុ ... ចំពោះវត្ថុ រាគៈដែលមាន ហេតុត្រូវលះដោយភាវនា ប្រារព្ធនូវវត្ថុនោះ ទើបកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សដែលមានហេតុត្រូវលះដោយភាវនា កើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយភាវនា ដោយ បុរេជាតប្បច្ច័យ ។

[ ១៧៩ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះ ដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែល មានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយ បុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណ-បុរេជាត គឺខន្ធទាំងឡាយដែលច្រឡំដោយវិចិកិច្ឆាក្តី មោហៈក្តី ប្រារព្ធនូវ ចក្ខុ ... នូវវត្ថុ ទើបកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំង ឡាយដែលច្រឡំដោយវិចិកិច្ឆាផង នៃមោហៈផង ដោយបុរេជាតប្បច្ច័យ ។

[ ១៨០ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះ

ដោយការនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយការនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយការនាផង ដោយបុរេជាតប្បច្ច័យ បានដល់ អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណ-បុរេជាត គឺខន្ធទាំងឡាយ ដែលប្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ប្រារព្ធនូវចក្ខុ ... នូវវត្ថុ ទើបកើតឡើង ។ ឯវត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រឡំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយបុរេជាតប្បច្ច័យ ។

[ ១៨១ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយការនា ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ១៨២ ] ធម៌ ដែលមានហេតុត្រូវលះដោយការនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយការនា ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយដែលមានហេតុត្រូវលះដោយការនា ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ១៨៣ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយការនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយការនា ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយការនា ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ១៨៤ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយបច្ឆា-ជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយដែលប្រឡំដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ១៨៥ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយបច្ឆា-ជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយដែលប្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ១៨៦ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអាសេវនប្បច្ច័យ ។

[ ១៨៧ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... គឺខន្ធទាំងឡាយមុនៗ ដែលប្រឡំដោយវិចិកិច្ឆា ជាបច្ច័យនៃមោហៈក្រោយៗ ដោយអាសេវនប្បច្ច័យ ។

[ ១៨៨ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌

ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលប្រកបដោយវិចិកិច្ឆា ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលប្រកបដោយវិចិកិច្ឆាផង នៃមោហៈផង ដោយអាសេវនប្បច្ច័យ ។

[ ១៨៩ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនា ។ សេចក្តីបង្រួញ ។ ពាក្យទាំងនេះ បានដល់វារៈ ៣ លើក ។ មិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ។បេ។ ( កិលេសជាត ) ដែលបុគ្គលត្រូវលះ ( ជាបច្ច័យ ) នៃការចេញផង នៃការពិចារណាផង ដូចក្នុងអាសេវនប្បច្ច័យ ជាមូល ។ បញ្ហា ១៧ ដ៏បរិបូណ៌ ប្រាកដស្មើដោយអនន្តរប្បច្ច័យ ។

[ ១៩០ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយកម្មប្បច្ច័យ គឺចេតនា ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

[ ១៩១ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃមោហៈផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ គឺចេតនាដែលមាន

ហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃខន្ធទាំងឡាយ ជាវិបាកផង ពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ១៩២ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺចេតនា ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង មោហៈផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ១៩៣ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនា ដោយកម្មប្បច្ច័យ គឺចេតនាដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយកម្មប្បច្ច័យ ។

[ ១៩៤ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយកម្មប្បច្ច័យ គឺចេតនាដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃមោហៈផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ១៩៥ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយកម្មប្បច្ច័យ គឺចេតនាដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង មោហៈផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ។

[ ១៩៦ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយកម្មប្បច្ច័យ បានដល់ សហជាត និងនានាខណិកៈ ។ សហជាត គឺចេតនាដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង ពួកចិត្តសមុដ្ឋានរូបផង ដោយកម្មប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ឯនានាខណិកៈ គឺចេតនាដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃខន្ធទាំងឡាយជាវិបាកផង នៃពួកកដត្តារូបផង ដោយកម្មប្បច្ច័យ ។

[ ១៩៧ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយវិបាកប្បច្ច័យ ។ បវត្តិប្បដិសន្ធិ ។ ខន្ធទាំងឡាយជាវិបាក ជាបច្ច័យនៃវត្ថុ ។

[ ១៩៨ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអាហារប្បច្ច័យ បានដល់ អាហារដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ដោយអាហារប្បច្ច័យ ។

[ ១៩៩ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... បានដល់ អាហារដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃមោហៈផង

ពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ។

[ ២០០ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... បានដល់ អាហារដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង មោហៈផង ពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ ដោយភាវនា ... ( បានដល់ ពាក្យបុច្ឆានិងវិសជ្ជនា ) ៣ លើក ។ ( ពាក្យនេះ ) ប្រាកដស្មើដោយទស្សនៈ ។

[ ២០១ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយអាហារប្បច្ច័យ បានដល់ អាហារដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអាហារប្បច្ច័យ កពឡិង្ការាហារ ជាបច្ច័យនៃកាយនេះ ក្នុងខណៈនៃបដិសន្ធិ ។

[ ២០២ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ... ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ( បានដល់ ពាក្យបុច្ឆា និងវិសជ្ជនា ) ៣ លើក ។ ( ពាក្យនេះ ) ប្រាកដស្មើដោយអាហារប្បច្ច័យ ។ មោហៈក៏បណ្ឌិតគប្បីធ្វើ ( ឲ្យដូចគ្នា ) ដោយភាវនា ... ( បានដល់ ពាក្យថា បុច្ឆា និងវិសជ្ជនា ) ៣ លើក ។

[ ២០៣ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះ

ដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... គឺឥន្ទ្រិយទាំងឡាយដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃពួកសម្បយុត្តកក្ខន្ធ ។ សេចក្តីបង្រួញ ។ ចក្ខុន្ទ្រិយ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយិន្ទ្រិយ ... រូបជីវិតិន្ទ្រិយ ជាបច្ច័យនៃកដត្តារូបទាំងឡាយ ដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ។ ពួកធម៌ដែលប្រព្រឹត្តទៅមួយអន្លើដោយហេតុទាំងនេះ បណ្ឌិតគប្បីធ្វើ ។ ជាបច្ច័យដោយសម្បយុត្តប្បច្ច័យ ។ ( ពាក្យនេះ ) ប្រាកដស្មើដោយសម្បយុត្តវារៈ ក្នុងបដិច្ចវារៈ ។

[ ២០៤ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ ( ពាក្យនេះ ) ប្រាកដស្មើដោយទស្សនត្តិកៈ ។

[ ២០៥ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ ( ពាក្យនេះ ) ប្រាកដស្មើដោយទស្សនត្តិកៈ ។

[ ២០៦ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិន

ត្រូវលះដោយភាវនា ... បានដល់ សហជាត បុរេជាត និងបច្ឆាជាត ។ ( ពាក្យនេះ ) ប្រាកដស្មើដោយទស្សនត្តិកៈ ។ បច្ឆាជាត គឺខន្ធទាំងឡាយ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះ ដែលកើតមុន ។

[ ២០៧ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ... ។ បុរេជាត គឺវត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈ ។

[ ២០៨ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនា ... ។ បុរេ-ជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយភាវនា ។

[ ២០៩ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... ។ បុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាផង នៃមោហៈផង ដោយវិប្បយុត្តប្បច្ច័យ ។

[ ២១០ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... ។

បុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយដែលប្រឡំដោយឧទ្ធច្ចៈផង មោហៈផង ដោយវិប្បយុត្តប្បច្ច័យ ។

[ ២១១ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយដែលប្រឡំដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃចិត្តសមុដ្ឋានរូបទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលប្រឡំដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ២១២ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយ ដែលប្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ( ជាបច្ច័យ ) នៃពួកចិត្តសមុដ្ឋានរូប ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលប្រឡំដោយឧទ្ធច្ចៈក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ២១៣ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ដែល

មានហេតុត្រូវលះដោយទស្សនៈ ... ។

[ ២១៤ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃចិត្តសមុដ្ឋានរូបទាំងឡាយ ដោយអត្ថិប្បច្ច័យ ។ ( មួយទៀត ) សហជាត គឺខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាជាបច្ច័យនៃមោហៈផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ២១៥ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ( ជាបច្ច័យ ) នៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ... គឺខន្ធ ១ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃខន្ធ ៣ ផង នៃចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយអត្ថិប្បច្ច័យ ខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆា ជាបច្ច័យនៃខន្ធ ៣ ផង មោហៈផង ចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ ។ ធម៌ដែលមានហេតុត្រូវលះដោយភាវនា ... ( បានដល់ ពាក្យបុច្ឆា និងវិសជ្ជនា ) ៣ លើក ។

[ ២១៦ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយអត្ថិប្បច្ច័យ បានដល់ សហជាត បុរេជាត

បច្ឆាជាត អាហារនិងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃខន្ធ ៣ ផង នៃចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយអត្ថិប្បច្ច័យ មោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ជាបច្ច័យនៃចិត្តសមុដ្ឋានរូបទាំងឡាយ ដោយអត្ថិប្បច្ច័យ នៃពួកអសញ្ញសត្វ ក្នុងខណៈនៃបដិសន្ធិ ... ។ ឯបុរេជាត គឺ ( បុគ្គលត្រេកអរ រីករាយ ) ចំពោះចក្ខុ ... ចំពោះវត្ថុ ... ថាមិនទៀង ... បុគ្គលឃើញរូបដោយទិព្វចក្ខុ ឮសំឡេងដោយទិព្វសោតធាតុ រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយ-វិញ្ញាណ ចក្ខាយតនៈ ... កាយាយតនៈ ... វត្ថុជាបច្ច័យនៃខន្ធទាំងឡាយដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង នៃមោហៈផង ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ( ជាបច្ច័យ ) នៃកាយនេះ រូបជីវិតិន្ទ្រិយ ( ជាបច្ច័យ ) នៃកដត្តារូបទាំងឡាយ ។

[ ២១៧ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺមោហៈដែលប្រឡំដោយវិចិកិច្ឆា ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺបុគ្គលត្រេកអរ រីករាយចំពោះចក្ខុ ... ចំពោះវត្ថុ រាគៈដែលមាន

ហេតុត្រូវលះដោយទស្សនៈ ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆា ... ទោមនស្ស ដែលមានហេតុត្រូវលះដោយទស្សនៈកើតឡើង វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអត្ថិប្បច្ច័យ ។

[ ២១៨ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយភាវនា ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺមោហៈដែលប្រកបដោយឧទ្ធច្ចៈ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺបុគ្គលត្រេកអរ រីករាយ ចំពោះចក្ខុ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយភាវនា ដោយអត្ថិប្បច្ច័យ ។

[ ២១៩ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺមោហៈដែលប្រកបដោយវិចិកិច្ឆា ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង នៃចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ប្រារព្ធនូវចក្ខុ ទើបកើតឡើង វត្ថុប្រារព្ធនូវវត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាផង នៃមោហៈផង ដោយអត្ថិប្បច្ច័យ ។

[ ២២០ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺមោហៈដែលប្រទូរំដោយឧទ្ធច្ចៈ ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង នៃចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយអត្ថិប្បច្ច័យ ។ ឯបុរេជាត គឺខន្ធទាំងឡាយដែលប្រទូរំដោយឧទ្ធច្ចៈក្តី មោហៈក្តី ប្រារព្ធនូវចក្ខុ ទើបកើតឡើង វត្ថុប្រារព្ធនូវវត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលប្រទូរំដោយឧទ្ធច្ចៈផង នៃមោហៈផង ដោយអត្ថិប្បច្ច័យ ។

[ ២២១ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ខន្ធ ១ ដែលប្រទូរំដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។

[ ២២២ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... បាន

ដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី មហាភូតទាំងឡាយក្តី ជាបច្ច័យនៃចិត្តសមុដ្ឋានរូបទាំងឡាយ ដោយអត្ថិប្បច្ច័យ ។ ( មួយទៀត ) សហជាត គឺខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃចិត្តសមុដ្ឋានរូបទាំងឡាយ ដោយអត្ថិប្បច្ច័យ ។ ( មួយវិញទៀត ) សហជាត គឺខន្ធទាំងឡាយ ដែលប្រកបដោយវិចិកិច្ឆាក្តី វត្ថុក្តី ជាបច្ច័យនៃមោហៈ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ ( មួយទៀត ) បច្ឆាជាត គឺខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ ( មួយវិញទៀត ) បច្ឆាជាត គឺខន្ធទាំងឡាយ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃកដត្តារូបទាំងឡាយ ដោយអត្ថិប្បច្ច័យ ។

[ ២២៣ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ផង មោហៈផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ខន្ធ ១ ដែលប្រកបដោយវិចិកិច្ឆាក្តី មោហៈក្តី ជាបច្ច័យនៃខន្ធ ៣ ផង នៃចិត្ត-

សមុដ្ឋានរូបទាំងឡាយផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ក្តី មោហៈ ក្តី ... ។

[ ២២៤ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ដោយភាវនា ... ។ សេចក្តីបង្រួញ ។ ប្រស្នា ៣ យ៉ាង បណ្ឌិតគប្បីចែកតាមទស្សនទ្ទ័យ ។ ពាក្យថា ឧទ្ធច្ចៈ បណ្ឌិតគប្បីកំណត់បាន ។

## នត្ថិវិគតអវិគតប្បច្ច័យ ចប់

[ ២២៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២១ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១៧ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១៧ ក្នុងវិគតប្បច្ច័យ មានវារៈ ១៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះ ។

## អនុលោម ចប់

[ ២២៦ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ២២៧ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយ អារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ។

[ ២២៨ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយ ទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ២២៩ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយភាវនា ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយ សហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ២៣០ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។

[ ២៣១ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយ

អារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧប-និស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។

[ ២៣២ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ២៣៣ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហ-ជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ២៣៤ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ២៣៥ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧប-

និស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ២៣៦ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយភាវនា ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ២៣៧ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ២៣៨ ] ធម៌ ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ជាបច្ច័យនៃធម៌ ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ២៣៩ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ សហជាតប្បច្ច័យ

និងបុរេជាតប្បច្ច័យដែលតាំងនៅក្នុងការប្រឡុំគ្នា រមែងមានក្នុងទីនេះ បណ្ឌិតគប្បីធ្វើតាម ( ឲ្យដូច ) ក្នុងបាលី បណ្ឌិតគប្បីពិចារណាហើយរាប់ ( តាមលំដាប់ ) នៃការរាប់ ។

[ ២៤០ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ ពួកអារម្មណប្បច្ច័យ និងឧបនិស្សយប្បច្ច័យ រមែងមានក្នុងទីនេះដែរ មិនមានក្នុងបាលីទេ បណ្ឌិតកាលរាប់ គប្បីពិចារណាហើយរាប់ចុះ ។

[ ២៤១ ] ធម៌ ដែលមានហេតុត្រូវលះដោយទស្សនៈក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ សហជាតប្បច្ច័យ និងបុរេជាតប្បច្ច័យ ដែលជាមិស្សកប្បញ្ហា ក៏មានក្នុងទីនេះដែរ បណ្ឌិតកុំគប្បីធ្វើដូចក្នុងបាលីឡើយ ។

[ ២៤២ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយ

ឧបនិស្សយប្បច្ច័យ ។

[ ២៤៣ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនា ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ សហជាតប្បច្ច័យ និងបុរេជាតប្បច្ច័យ ដែលជាមិស្សកបញ្ហា ក៏មានក្នុងទីនេះដែរ ។

[ ២៤៤ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ( ជាបច្ច័យ ) នៃធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ... បានដល់ សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ អារម្មណប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ក៏មានក្នុងទីនេះដែរ ។

[ ២៤៥ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយទស្សនៈផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ២៤៦ ] ធម៌ ដែលមានហេតុត្រូវលះដោយភាវនាក្តី ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនាក្តី ជាបច្ច័យនៃធម៌ដែលមានហេតុត្រូវលះដោយភាវនាផង ដែលមានហេតុមិនត្រូវលះដោយទស្សនៈ

មិនត្រូវលះដោយការនាផង ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហ-ជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ សហជាតប្បច្ច័យ និង បុរេជាតប្បច្ច័យ ក៏មានក្នុងទីនេះដែរ ពួកប្រស្នាណា ដែលលោកមិនបាន សរសេរហើយ ពួកប្រស្នានោះ មិនសមដោយព្យញ្ជនៈរបស់លោក កាល រាប់ក្នុងបាលី ពួកប្រស្នានោះ លោកមិនបានសរសេរទុកក្នុងបាលីទេ តែការ រាប់ ក៏រមែងប្រាកដ បើសេចក្ដីសង្ស័យកើតឡើង បណ្ឌិតគប្បីពិនិត្យមើល ក្នុងអត្ថិប្បច្ច័យ ដែលជាអនុលោមចុះ ។

[ ២៤៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២១ ក្នុងនអារម្មណប្បច្ច័យ ក្នុងនអធិបតិប្បច្ច័យ ក្នុងនអនន្តរប្បច្ច័យ ក្នុងនសមនន្តរប្បច្ច័យ ក្នុងនសហជាតប្បច្ច័យ ក្នុងនអញ្ញមញ្ញប្បច្ច័យ ក្នុងននិស្សយប្បច្ច័យ ក្នុងនឧប-និស្សយប្បច្ច័យ ក្នុងនបុរេជាតប្បច្ច័យ ក្នុងនបច្ឆាជាតប្បច្ច័យ ក្នុងនអា-សេវនប្បច្ច័យ ក្នុងនកម្មប្បច្ច័យ ក្នុងនវិបាកប្បច្ច័យ ក្នុងនអាហារប្បច្ច័យ ក្នុងនឥន្ទ្រិយប្បច្ច័យ ក្នុងនឈានប្បច្ច័យ ក្នុងនមគ្គប្បច្ច័យ ក្នុងនសម្ប-យុត្តប្បច្ច័យ ក្នុងនវិប្បយុត្តប្បច្ច័យ ក្នុងនោអត្ថិប្បច្ច័យ ក្នុងនោនត្ថិប្បច្ច័យ ក្នុងនោវិគតប្បច្ច័យ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ២១ ទាំងអស់ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះ ។

## បច្ចនីយៈ ចប់

[ ២៤៨ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១១ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ ក្នុងនអនន្តរប្បច្ច័យ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ

១១ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ ក្នុងនបុរេជាតប្បច្ច័យ ក្នុងនបច្ឆាជាតប្បច្ច័យ ក្នុងនអាសេវនប្បច្ច័យ ក្នុងនកម្មប្បច្ច័យ ក្នុងនវិបាកប្បច្ច័យ ក្នុងនអាហារប្បច្ច័យ ក្នុងនឥន្ទ្រិយប្បច្ច័យ ក្នុងនឈានប្បច្ច័យ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ២៤៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២១ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២១ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១៧ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ

មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១៧ ក្នុងវិគតប្បច្ច័យ មានវារៈ ១៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះ ។

បច្ចនីយានុលោម ចប់

ទសកនេទ បហាតព្វហេតុកត្តិកៈទី ៩ ចប់

# អដ្ឋកថា

## ទស្សនេន បហាតព្វហេតុកត្តិកៈ

[ ១-២៤៩ ] ក្នុងទស្សនេនបហាតព្វហេតុកត្តិកៈ អ្នកសិក្សាគប្បីជ្រាបការចែកធម៌ ដែលមានហេតុដែលគប្បីលះដោយទស្សនៈ ដោយន័យដែលលោកពោលទុក ក្នុងអដ្ឋកថាកណ្ឌ ( ក្នុងធម្មសង្គណី ) មោហៈដែលសហគតៈដោយវិចិកិច្ឆា និងឧទ្ធច្ចៈ រាប់ចូលក្នុងពួកទី ៣ ព្រោះមិនមានហេតុ ។ ក្នុងអធិការនេះ ធម៌ដែលមានហេតុត្រូវលះដោយទស្សនៈ ដែលមានហេតុត្រូវលះដោយភាវនា ដូចពោលមកហើយនោះ ធម៌ទាំងនោះ ឈ្មោះថា ធម៌ដែលមានហេតុត្រូវលះ ។ ធម៌ទាំងឡាយណាមិនមានហេតុ ធម៌ទាំងឡាយនោះ ឈ្មោះថា ធម៌ដែលមានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា អ្នកសិក្សាគប្បីជ្រាបវិភាគនៃបហាតព្វហេតុកធម៌ និងនបហាតព្វហេតុកធម៌ ដូច្នេះហើយ គប្បីជ្រាបពាក្យដ៏សេសតាមគន្លងនៃលក្ខណៈដែលសម្ដែងទុកក្នុងទស្សនេនបហាតព្វត្តិកៈ និងកុសលត្តិកៈ ។

**អដ្ឋកថាទស្សនេនបហាតព្វហេតុកត្តិកៈ ចប់**

# អភិធម្មបិដក

## អាចយគាមិត្តិកៈ

## បដិច្ចវារៈ

[ ២៥០ ] ធម៌ ដែលដល់នូវការសន្សំ អាស្រ័យធម៌ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវការសន្សំ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលដល់នូវការសន្សំ ។ ធម៌ដែលដល់នូវការសន្សំក្តី ធម៌ដែលមិនដែលដល់នូវការសន្សំ មិនដល់នូវការមិនសន្សំក្តី អាស្រ័យធម៌ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលដល់នូវការសន្សំ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។

[ ២៥១ ] ធម៌ ដែលដល់នូវការមិនសន្សំ អាស្រ័យធម៌ដែលដល់នូវការមិនសន្សំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវការមិនសន្សំ ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ដែលដល់នូវការមិនសន្សំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលដល់នូវការមិនសន្សំ ។ ធម៌ដែលដល់នូវការមិនសន្សំក្តី ធម៌ដែលមិន

ដល់នូវការសន្សំ មិនដល់នូវការមិនសន្សំក្តី អាស្រ័យធម៌ដែលដល់នូវការមិនសន្សំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលដល់នូវការមិនសន្សំ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ២ ។

[ ២៥២ ] ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... វត្ថុ អាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយអាស្រ័យវត្ថុ មហាភូត ៣ អាស្រ័យមហាភូត ១ មហាភូត ២ អាស្រ័យមហាភូត ២ ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ២៥៣ ] ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ដែលដល់នូវការសន្សំផង ធម៌ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការសន្សំផង មហាភូតទាំងឡាយផង ។ ធម៌ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ដែលដល់នូវការមិនសន្សំផង ធម៌ដែលមិនដល់នូវការសន្សំ មិនដល់នូវការ

មិនសន្សំផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវការមិនសន្សំផង មហាភូតទាំងឡាយផង ។

[ ២៥៤ ] ធម៌ ដែលដល់នូវការសន្សំ អាស្រ័យធម៌ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវការសន្សំ នូវខន្ធ ២ ... ។

[ ២៥៥ ] ធម៌ ដែលដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលដល់នូវការមិនសន្សំ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវការមិនសន្សំ នូវខន្ធ ២ ... ។

[ ២៥៦ ] ធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យខន្ធ ២ ... ខន្ធទាំងឡាយអាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ២៥៧ ] ធម៌ ដែលដល់នូវការសន្សំ អាស្រ័យធម៌ ដែលដល់នូវការសន្សំ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ ( បានដល់ ពាក្យបុច្ឆា និងវិសជ្ជនា ) ៣ លើក ។ ... ធម៌ដែលដល់នូវការមិនសន្សំ ... ព្រោះអធិ-បតិប្បច្ច័យ ( បានដល់ ពាក្យបុច្ឆា និងវិសជ្ជនា ) ៣ លើក ។ ធម៌ដែលមិនដល់នូវការសន្សំ មិនដល់នូវការមិនសន្សំ អាស្រ័យធម៌ ដែលមិនដល់នូវការសន្សំ ... មិនដល់នូវការមិនសន្សំ បានដល់ វារៈ ១ ។ បដិសន្ធិ

[ ៤៩៩ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ( ជាបច្ច័យ ) នៃធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ... គឺអារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ

គឺផលសមាបត្តិដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃកាយិកសុខ ដោយឧបនិស្សយប្បច្ច័យ ។

[ ៥០០ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយឧបនិស្សយប្បច្ច័យ គឺអារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ បកតូបនិស្ស័យ ។ ឯបកតូបនិស្ស័យ គឺបុគ្គលអាស្រ័យនូវសំឡេងដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ហើយឲ្យទាន សីល ... នូវឧបោសថកម្ម ... នូវឈាន ... នូវវិបស្សនា ... នូវអភិញ្ញា ... ញុំាងសមាបត្តិឲ្យកើត ជំឡើងមានះ នូវទិដ្ឋិ ... នូវសីល ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ... នូវបញ្ញា នូវរាគៈ នូវមោហៈ នូវកាយិកសុខ នូវរដូវ នូវភោជន ... បុគ្គលអាស្រ័យនូវសេនាសនៈទើបឲ្យទាន សីល ... ញុំាងសមាបត្តិឲ្យកើត សម្លាប់សត្វ បំបែកសង្ឃ សទ្ធាដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខ-បុគ្គល ... បញ្ញា រាគៈ បត្ថនា កាយិកសុខ ... សេនាសនៈ ជាបច្ច័យនៃសទ្ធា ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល នៃបញ្ញា នៃរាគៈ នៃបត្ថនា នៃកាយិកសុខ នៃកាយិកទុក្ខ ដោយឧបនិស្សយប្បច្ច័យ បរិកម្មរបស់បឋមជ្ឈាន ជាបច្ច័យនៃបឋមជ្ឈាន ដោយឧបនិស្សយប្បច្ច័យ បរិកម្ម របស់នេវសញ្ញានាសញ្ញាយតនៈ ( ជាបច្ច័យ ) នៃនេវសញ្ញានាសញ្ញាយតនៈ បឋមជ្ឈាន ជាបច្ច័យនៃទុតិយជ្ឈាន ដោយ

ឧបនិស្សយប្បច្ច័យ អាកិញ្ចញ្ញាយតនៈជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនៈ ដោយឧបនិស្សយប្បច្ច័យ ។

[ ៥០១ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់សេក្ខបុគ្គល ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺបរិកម្មរបស់មគ្គទី ១ ជាបច្ច័យនៃមគ្គទី ១ ដោយឧបនិស្សយប្បច្ច័យ បរិកម្មរបស់មគ្គទី ៤ ជាបច្ច័យនៃមគ្គទី ៤ ដោយឧបនិស្សយប្បច្ច័យ ។

[ ៥០២ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលជារបស់អសេក្ខបុគ្គល ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បកតូបនិស្ស័យ គឺកាយិកសុខ ... កាយិកទុក្ខ រដូវ ភោជន ... សេនាសនៈ ជាបច្ច័យនៃផលសមាបត្តិ ដែលជារបស់អសេក្ខបុគ្គល ដោយឧបនិស្សយប្បច្ច័យ ។

[ ៥០៣ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយបុរេជាតប្បច្ច័យ គឺអារម្មណបុរេជាត វត្ថុបុរេជាត ។ អារម្មណបុរេជាត គឺបុគ្គលឃើញច្បាស់នូវចក្ខុ ដោយសេចក្ដីជាមិនទៀង ... ហើយត្រេកអរ រីករាយ រាគៈប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង

ទោមនស្ស ... បុគ្គលឃើញច្បាស់នូវសោតៈ ... នូវវត្ថុ ... ដោយសេចក្តីថា មិនទៀង ជាទុក្ខ ជាអនត្តា ... ទោមនស្ស កើតឡើង នូវរូបដោយចក្ខុដូចជាទិព្វ ... នូវសំឡេងដោយសោតធាតុដូចជាទិព្វ ... រូបាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺចក្ខ្វាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយបុរេជាតប្បច្ច័យ ។

[ ៥០៤ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់សេក្ខបុគ្គល ដោយបុរេជាតប្បច្ច័យ បានដល់ វត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលជារបស់សេក្ខបុគ្គល ដោយបុរេជាតប្បច្ច័យ ។

[ ៥០៥ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់អសេក្ខបុគ្គល ដោយបុរេជាតប្បច្ច័យ បានដល់ វត្ថុបុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលជារបស់អសេក្ខបុគ្គល ដោយបុរេជាតប្បច្ច័យ ។

[ ៥០៦ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យ

នៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

[ ៥០៧ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃកាយនេះ ដែលកើតមុន ... ។

[ ៥០៨ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ( ជាបច្ច័យ ) នៃធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយបច្ឆាជាតប្បច្ច័យ បានដល់ បច្ឆាជាត គឺខន្ធទាំងឡាយ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ( ជាបច្ច័យ ) នៃកាយនេះដែលកើតមុន ។

[ ៥០៩ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយមុនៗ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃខន្ធទាំងឡាយក្រោយៗ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយអាសេវនប្បច្ច័យ អនុលោមជាបច្ច័យនៃគោត្រភូ អនុលោម ជាបច្ច័យនៃវោទាន: ដោយអាសេវនប្បច្ច័យ ។

[ ៥១០ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់សេក្ខបុគ្គល ដោយអាសេវ-

នប្បច្ច័យ គឺគោត្រភូ ជាបច្ច័យនៃមគ្គ វោទាន: ជាបច្ច័យនៃមគ្គ ដោយអាសេវនប្បច្ច័យ ។

[ ៥១១ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលជារបស់សេក្ខបុគ្គល ដោយកម្មប្បច្ច័យ គឺសហជាត និងនានាខណិក: សហជាត គឺចេតនា ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដោយកម្មប្បច្ច័យ ។ ឯនានាខណិក: គឺចេតនាដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃវិបាកក្ខន្ធទាំងឡាយដែលជារបស់សេក្ខបុគ្គល ដោយកម្មប្បច្ច័យ ។

[ ៥១២ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់អសេក្ខបុគ្គល ដោយកម្មប្បច្ច័យ បានដល់ នានាខណិក: គឺចេតនាដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃខន្ធទាំងឡាយដែលជារបស់អសេក្ខ-បុគ្គល ដោយកម្មប្បច្ច័យ ។

[ ៥១៣ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយកម្មប្បច្ច័យ បានដល់ សហជាត គឺចេតនាដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃចិត្ត-សមុដ្ឋានរូបទាំងឡាយ ដោយកម្មប្បច្ច័យ ។

[ ៥១៤ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់សេក្ខបុគ្គលផង នៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលផង ដោយកម្មប្បច្ច័យ គឺចេតនាដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង នៃចិត្តសមុដ្ឋានរូបទាំងឡាយផង

ដោយកម្មប្បច្ច័យ ។

[ ៥១៥ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់អសេក្ខបុគ្គល ដោយកម្មប្បច្ច័យ គឺចេតនាដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយ ដោយកម្មប្បច្ច័យ ។

[ ៥១៦ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយកម្មប្បច្ច័យ គឺចេតនាដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃចិត្តសមុដ្ឋានរូបទាំងឡាយ ដោយកម្មប្បច្ច័យ ។

[ ៥១៧ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់អសេក្ខបុគ្គលផង នៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលផង ដោយកម្មប្បច្ច័យ គឺចេតនាជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង នៃចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយកម្មប្បច្ច័យ ។

[ ៥១៨ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយកម្មប្បច្ច័យ គឺសហជាត និងនានាខណិកៈ ។ សហជាត គឺចេតនា ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃសម្បយុត្តកក្ខន្ធទាំងឡាយផង នៃចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយកម្មប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។ ឯនានាខណិកៈ

គឺចេតនាដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាវិបាកផង នៃកដត្តារូបទាំងឡាយផង ដោយកម្មប្បច្ច័យ ។

[ ៥១៩ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់សេក្ខបុគ្គល ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលជារបស់សេក្ខ-បុគ្គល ជាបច្ច័យនៃខន្ធ ៣ ។ ក្នុងសេក្ខមូលកៈ មានវារៈ ៣ ។

[ ៥២០ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់អសេក្ខបុគ្គល ដោយវិបាកប្បច្ច័យ គឺខន្ធ ១ ដែលជារបស់អសេក្ខ-បុគ្គល ( ជាបច្ច័យ ) នៃខន្ធ ៣ ... ។ ក្នុងអសេក្ខមូលកៈ មានវារៈ ៣ ។

[ ៥២១ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ( ជាបច្ច័យ ) នៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយវិបាកប្បច្ច័យ គឺវិបាកក្ខន្ធ ១ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ( ជាបច្ច័យ ) នៃខន្ធ ៣ ខន្ធទាំងឡាយ ជាបច្ច័យនៃវត្ថុ ដោយវិបាកប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ។

[ ៥២២ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលជារបស់សេក្ខបុគ្គល ដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យដោយឈានប្បច្ច័យ ជាបច្ច័យដោយមគ្គប្បច្ច័យ ជាបច្ច័យដោយសម្ប-យុត្តប្បច្ច័យ ។

[ ៥២៣ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយវិប្បយុត្តប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃចិត្តសមុដ្ឋានរូបទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៥២៤ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយវិប្បយុត្តប្បច្ច័យ គឺសហជាត និងបច្ឆាជាត ប្រាកដស្មើដោយសេក្ខធម៌ ។

[ ៥២៥ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយវិប្បយុត្តប្បច្ច័យ គឺសហជាត បុរេជាត និងបច្ឆាជាត ។ សហជាត គឺខន្ធទាំងឡាយដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃចិត្តសមុដ្ឋានរូបទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ខន្ធទាំងឡាយ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃកដត្តារូបទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយ ជាបច្ច័យនៃវត្ថុ ដោយវិប្បយុត្តប្បច្ច័យវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដោយវិប្បយុត្តប្បច្ច័យ ។ បុរេជាត គឺចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយ-

វិញ្ញាណ វត្ថុ ( ជាបច្ច័យ ) នៃខន្ធទាំងឡាយ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយវិប្បយុត្តប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយវិប្បយុត្តប្បច្ច័យ ។

[ ៥២៦ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់សេក្ខបុគ្គល ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលជារបស់សេក្ខបុគ្គល ដោយវិប្បយុត្តប្បច្ច័យ ។

[ ៥២៧ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់អសេក្ខបុគ្គល ដោយវិប្បយុត្តប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលជារបស់អសេក្ខបុគ្គល ដោយវិប្បយុត្តប្បច្ច័យ ។

[ ៥២៨ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់សេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ដែលជារបស់សេក្ខបុគ្គល ( ជាបច្ច័យ ) នៃខន្ធ ៣ ។

[ ៥២៩ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ បានដល់ សហជាត និងបច្ឆាជាត ។ សហជាត គឺពួកខន្ធ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆា-

ជាត គឺខន្ធទាំងឡាយដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃកាយនេះ ដែលកើតមុន ដោយអត្ថិប្បច្ច័យ ។

[ ៥៣០ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលជារបស់សេក្ខបុគ្គលផង នៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលផង ដោយអត្ថិប្បច្ច័យ គឺខន្ធ ១ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃខន្ធ ៣ ផង នៃចិត្តសមុដ្ឋានរូបទាំងឡាយផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។

[ ៥៣១ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់អសេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ បានដល់ វារៈ ៣ ប្រាកដស្មើដោយធម៌ដែលជារបស់សេក្ខបុគ្គល ។

[ ៥៣២ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ គឺសហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺខន្ធ ១ ដែលមិនមែនជារបស់សេក្ខ-បុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃខន្ធ ៣ ផង នៃចិត្ត-សមុដ្ឋានរូបទាំងឡាយផង ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ខន្ធទាំងឡាយជាបច្ច័យនៃវត្ថុ ដោយអត្ថិប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដោយអត្ថិប្បច្ច័យ ។បេ។ នូវមហាភូត ១ ... នូវពាហិរ ។ សេចក្តីបង្រួញ ។ របស់ពួកអសញ្ញសត្វ ... ។ បុរេជាត គឺបុគ្គលឃើញ

ច្បាស់នូវចក្ខុ ថាមិនទៀង ជាទុក្ខ ជាអនត្តា ហើយត្រេកអរ រីករាយ រាគៈ ប្រារព្ធនូវចក្ខុនោះ ទើបកើតឡើង ទោមនស្ស ... បុគ្គលឃើញច្បាស់នូវសោតៈ ... នូវវត្ថុ ថាមិនទៀង ... នូវរូបដោយចក្ខុដូចជាទិព្វ ... នូវសំឡេងដោយសោតធាតុដូចជាទិព្វ ... រូបាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ ចក្ខ្វាយតនៈ ( ជាបច្ច័យ ) នៃចក្ខុវិញ្ញាណ កាយាយតនៈ ( ជាបច្ច័យ ) នៃកាយវិញ្ញាណ វត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយអត្ថិប្បច្ច័យ ។ កពឡិង្ការាហារ ( ជាបច្ច័យ ) នៃកាយនេះ រូបជីវិតិន្ទ្រិយជាបច្ច័យនៃកដត្តារូបទាំងឡាយ ដោយអត្ថិប្បច្ច័យ ។

[ ៥៣៣ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលជារបស់សេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលជារបស់សេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ ។

[ ៥៣៤ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលជារបស់អសេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ បានដល់ បុរេជាត គឺវត្ថុជាបច្ច័យនៃខន្ធទាំងឡាយ ដែលជារបស់អសេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ ។

[ ៥៣៥ ] ធម៌ ដែលជារបស់សេក្ខបុគ្គលក្តី ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលក្តី ជាបច្ច័យនៃធម៌ដែលជារបស់សេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ គឺសហជាត និងបុរេជាត ។ សហជាត គឺខន្ធ ១ ដែលជារបស់សេក្ខបុគ្គលក្តី វត្ថុក្តី ជាបច្ច័យនៃខន្ធ ៣ ដោយអត្ថិប្បច្ច័យ ខន្ធ ២ ... ។

[ ៥៣៦ ] ធម៌ ដែលជារបស់សេក្ខបុគ្គលក្តី ធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលក្តី ជាបច្ច័យនៃធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ គឺសហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ សហជាត គឺខន្ធទាំងឡាយដែលជារបស់សេក្ខបុគ្គលក្តី មហាភូតទាំងឡាយក្តី ជាបច្ច័យនៃចិត្តសមុដ្ឋានរូបទាំងឡាយ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយដែលជារបស់សេក្ខបុគ្គលក្តី កពឡិង្ការាហារក្តី ជាបច្ច័យនៃកាយនេះ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺខន្ធទាំងឡាយដែលជារបស់សេក្ខបុគ្គលក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យនៃកដត្តារូបទាំងឡាយ ដោយអត្ថិប្បច្ច័យ ។

[ ៥៣៧ ] ធម៌ ដែលជារបស់សេក្ខបុគ្គលក្តី ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលក្តី ជាបច្ច័យនៃធម៌ដែលជារបស់អសេក្ខបុគ្គល ដោយអត្ថិប្បច្ច័យ ។ បញ្ហា ២ យ៉ាង បណ្ឌិតគប្បីធ្វើឲ្យប្រាកដស្មើដោយធម៌ដែលជារបស់សេក្ខបុគ្គល ។

[ ៥៣៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៨ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៨ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៨ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងវិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៨ ក្នុងវិគតប្បច្ច័យ មានវារៈ ៨ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៥៣៩ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលជារបស់សេក្ខបុគ្គល ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ធម៌ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់អសេក្ខបុគ្គល ដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤០ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។

[ ៥៤១ ] ធម៌ ដែលជារបស់សេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលជារបស់សេក្ខបុគ្គលផង នៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលផង ដោយសហជាតប្បច្ច័យ ។

[ ៥៤២ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលជារបស់អសេក្ខបុគ្គល ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៥៤៣ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ។

[ ៥៤៤ ] ធម៌ ដែលជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់អសេក្ខបុគ្គលផង នៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលផង ដោយសហជាតប្បច្ច័យ ។

[ ៥៤៥ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយកម្មប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ៥៤៦ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់

អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ ដែលជារបស់សេក្ខបុគ្គល ដោយឧបនិស្ស-យប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ៥៤៧ ] ធម៌ ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជាបច្ច័យនៃធម៌ដែលជារបស់អសេក្ខបុគ្គល ដោយឧបនិស្ស-យប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ។

[ ៥៤៨ ] ធម៌ ដែលជារបស់សេក្ខបុគ្គលក្តី ធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលក្តី ( ជាបច្ច័យ ) នៃធម៌ដែលជារបស់សេក្ខបុគ្គល ... បានដល់ សហជាត និងបុរេជាត ។

[ ៥៤៩ ] ធម៌ ដែលជារបស់សេក្ខបុគ្គលក្តី ធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលក្តី ( ជាបច្ច័យ ) នៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ... បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ៥៥០ ] ធម៌ ដែលជារបស់អសេក្ខបុគ្គលក្តី ធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលក្តី ( ជាបច្ច័យ ) នៃធម៌ដែលជារបស់អសេក្ខបុគ្គល ... បានដល់ សហជាត និងបុរេជាត ។

[ ៥៥១ ] ធម៌ ដែលជារបស់អសេក្ខបុគ្គលក្តី ធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គលក្តី ( ជាបច្ច័យ ) នៃធម៌ដែលមិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ... បានដល់ សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។

[ ៥៥២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១៤ ក្នុងនអារម្មណប្បច្ច័យ នអធិបតិប្បច្ច័យ នអនន្តរប្បច្ច័យ និងនសមនន្តរប្បច្ច័យ មានវារៈ ១៤ ក្នុងនសហជាតប្បច្ច័យ មានវារៈ ១០ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១០ ក្នុងននិស្សយប្បច្ច័យ មានវារៈ ១០ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៤ ក្នុងនអាសេវនប្បច្ច័យ នកម្មប្បច្ច័យ នវិបាកប្បច្ច័យ នអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ និងនមគ្គប្បច្ច័យ មានវារៈ ១៤ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១០ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៨ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៨ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១៤ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១៤ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៨ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៥៥៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ នបុរេជាតប្បច្ច័យ នបច្ឆាជាតប្បច្ច័យ នអាសេវនប្បច្ច័យ នកម្មប្បច្ច័យ នវិបាកប្បច្ច័យ នអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ និងនមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ

៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ៥៥៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះនហេតុប្បច្ច័យ ... ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៨ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៨ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៨ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងវិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៨ ក្នុងវិគតប្បច្ច័យ មានវារៈ ៨ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយានុលោម ចប់

## បញ្ហាវារៈ ចប់

## សេក្ខត្តិកៈ ជាគម្រប់ ១១ ចប់

# អភិធម្មបិដក

## បរិត្តត្តិកៈ

## បដិច្ចវារៈ

[ ៥៥៥ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានសភាពតូចឆ្មារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានសភាពតូចឆ្មារ នូវខន្ធ ២ ... ខន្ធ ៣ ក្តី កដត្តា-រូបក្តី អាស្រ័យខន្ធ ១ ដែលមានសភាពតូចឆ្មារ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... វត្ថុអាស្រ័យខន្ធទាំងឡាយ ខន្ធទាំងឡាយអាស្រ័យវត្ថុ មហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប អាស្រ័យមហាភូត ២ ធម៌ដែលដល់នូវសភាពធំអាស្រ័យធម៌ដែលមានសភាពតូចឆ្មារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយដែលដល់សភាពធំ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ ដែលមានសភាពតូចឆ្មារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយដែលដល់នូវសភាពធំ អាស្រ័យវត្ថុ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ។

[ ៥៥៦ ] ធម៌ ដែលដល់នូវសភាពធំ អាស្រ័យធម៌ដែលដល់នូវសភាពធំ ... ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំនូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលដល់នូវសភាពធំ ... ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំ កដត្តារូប អាស្រ័យខន្ធទាំង

ឡាយដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ... ធម៌ដែលមានសភាពតូចថ្ការក្តី ធម៌ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ ដែលដល់នូវសភាពធំ ... ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។

[ ៥៥៧ ] ធម៌ ដែលមានប្រមាណមិនបាន អាស្រ័យធម៌ ដែលមានប្រមាណមិនបាន ... ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានប្រមាណមិនបាន នូវខន្ធ ២ ... ។ ធម៌ដែលមានសភាពតូចថ្ការ អាស្រ័យធម៌ដែលមានប្រមាណមិនបាន ... ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលមានប្រមាណមិនបាន ។ ធម៌ដែលមានសភាពតូចថ្ការក្តី ធម៌ដែលមានប្រមាណមិនបានក្តី អាស្រ័យធម៌ដែលមានប្រមាណមិនបាន ... ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានប្រមាណមិនបាន នូវខន្ធ ២ ... ។

[ ៥៥៨ ] ធម៌ ដែលមានសភាពតូចថ្ការ អាស្រ័យធម៌ដែលមានសភាពតូចថ្ការផង ធម៌ដែលមានប្រមាណមិនបានផង ... ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលមានប្រមាណមិនបានផង មហាភូតទាំងឡាយផង ។

[ ៥៥៩ ] ធម៌ ដែលមានសភាពតូចថ្ការ អាស្រ័យធម៌ដែលមានសភាពតូចថ្ការផង ធម៌ដែលដល់នូវសភាពធំផង ... ព្រោះហេតុប្បច្ច័យ គឺចិត្ត-

សមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំផង មហាភូត ទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលដល់នូវសភាពធំអាស្រ័យ ធម៌ ដែលមានសភាពតូចឆ្មារផង ធម៌ដែលដល់នូវសភាពធំផង ... ព្រោះ ហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ដែលមានសភាពតូចឆ្មារផង ធម៌ដែល ដល់នូវសភាពធំផង ... ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែល ដល់នូវសភាពធំផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... កដត្តារូប អាស្រ័យខន្ធទាំងឡាយដែលដល់នូវសភាពធំផង មហាភូតទាំងឡាយផង ។

[ ៥៦០ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានសភាព តូចឆ្មារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានសភាពតូចឆ្មារ នូវខន្ធ ២ ... ខន្ធទាំងឡាយ អាស្រ័យវត្ថុ ក្នុង ខណៈនៃបដិសន្ធិ ។ ធម៌ដែលដល់នូវសភាពធំ អាស្រ័យធម៌ ដែលមាន សភាពតូចឆ្មារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធទាំងឡាយដែល ដល់នូវសភាពធំ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ៥៦១ ] ធម៌ ដែលដល់នូវសភាពធំ អាស្រ័យធម៌ ដែលដល់នូវ សភាពធំ ... ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់ នូវសភាពធំ នូវខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៥៦២ ] ធម៌ ដែលមានប្រមាណមិនបាន អាស្រ័យធម៌ ដែលមាន

ប្រមាណមិនបាន ... ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានប្រមាណមិនបាន នូវខន្ធ ២ ... ។

[ ៥៦៣ ] ធម៌ ដែលដល់នូវសភាពធំ អាស្រ័យធម៌ ដែលមានសភាពតូចថ្មារផង ធម៌ដែលដល់នូវសភាពធំផង ... ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំផង នូវវត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។

[ ៥៦៤ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាពតូចថ្មារ ... ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានសភាពតូចថ្មារ ខន្ធ ២ ... មហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប និងឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៥៦៥ ] ធម៌ ដែលដល់នូវសភាពធំ អាស្រ័យធម៌ដែលដល់នូវសភាពធំ ... ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំ នូវខន្ធ ២ ... ។ ធម៌ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលដល់នូវសភាពធំ ... ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលដល់នូវសភាពធំ ។ ធម៌ដែលមានសភាពតូចថ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ដែលដល់នូវសភាពធំ ... ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំ នូវខន្ធ ២ ... ។

[ ៥៦៦ ] ធម៌ ដែលមានប្រមាណមិនបាន អាស្រ័យធម៌ ដែលមាន

ប្រមាណមិនបាន ... ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានប្រមាណមិនបាន នូវខន្ធ ២ ... ។ ធម៌ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានប្រមាណមិនបាន ... ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានប្រមាណមិនបាន ។ ធម៌ដែលមានសភាពតូចថ្មារក្តី ធម៌ដែលមានប្រមាណមិនបានក្តី អាស្រ័យធម៌ដែលមានប្រមាណមិនបាន ... ព្រោះអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានប្រមាណមិនបាន នូវខន្ធ ២ ... ។

[ ៥៦៧ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាពតូចថ្មារផង ធម៌ដែលមានប្រមាណមិនបានផង ... ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានប្រមាណមិនបានផង នូវមហាភូតទាំងឡាយផង ។

[ ៥៦៨ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ ដែលមានសភាពតូចថ្មារផង ធម៌ដែលដល់នូវសភាពធំផង ... ព្រោះអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំផង នូវមហាភូតទាំងឡាយផង ។

[ ៥៦៩ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាពតូចថ្មារ ទើបកើតឡើង ព្រោះអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ និងសហជាតប្បច្ច័យ បណ្ឌិតគប្បីធ្វើឲ្យដូចជាមហាភូតទាំងអស់ ។ ព្រោះអញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ និងបុរេជាតប្បច្ច័យ បណ្ឌិតគប្បីធ្វើបញ្ហា

ទាំង ៣ ។ ព្រោះអាសេវនប្បច្ច័យ បណ្ឌិតគប្បីធ្វើបញ្ហាទាំង ៣ ។ ព្រោះកម្មប្បច្ច័យ និងវិបាកប្បច្ច័យ បណ្ឌិត ( គប្បីធ្វើ ) បញ្ហាទាំង ១៣ ។ ព្រោះអាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ និងអវិគតប្បច្ច័យ ។

[ ៥៧០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ១៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១៣ ក្នុងអាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ មានវារៈ ១៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងវិគតប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

## អនុលោម ចប់

[ ៥៧១ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាពតូចថ្មារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានសភាពតូចថ្មារ ជាអហេតុកៈ នូវខន្ធ ២ ...

វត្ថុអាស្រ័យខន្ធទាំងឡាយ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធទាំងឡាយអាស្រ័យវត្ថុ ពាហិរ ... អាស្រ័យមហាភូត ១ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មោហៈដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ អាស្រ័យមហាភូត ១ របស់ពួកអសញ្ញសត្វ អាស្រ័យខន្ធទាំងឡាយ ដែលប្រឡំដោយវិចិកិច្ឆា ប្រឡំដោយឧទ្ធច្ចៈ ។

[ ៥៧២ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានសភាពតូចឆ្មារទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានសភាពតូចឆ្មារ កដត្តារូបអាស្រ័យខន្ធទាំងឡាយដែលមានសភាពតូចឆ្មារ ក្នុងខណៈនៃបដិសន្ធិ វត្ថុអាស្រ័យខន្ធទាំងឡាយនូវមហាភូត ១ ... ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន ... មហាភូត ១ របស់ពួកអសញ្ញសត្វ ... ។

[ ៥៧៣ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលដល់នូវសភាពធំ កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ។

[ ៥៧៤ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ ដែលមានប្រមាណមិនបាន ... ព្រោះនអារម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានប្រមាណមិនបាន ។

[ ៥៧៥ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានសភាព

តូចថ្មារផង ធម៌ដែលមានប្រមាណមិនបានផង ទើបកើតឡើង ព្រោះនអា-រម្មណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលមានប្រមាណមិនបានផង មហាភូតទាំងឡាយផង ។

[ ៥៧៦ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាពតូចថ្មារផង ធម៌ដែលដល់នូវសភាពធំផង ទើបកើតឡើង ព្រោះនអារម្ម-ណប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលដល់នូវសភាពធំផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំផង នូវមហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។

[ ៥៧៧ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាពតូចថ្មារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានសភាពតូចថ្មារ វត្ថុអាស្រ័យខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយអាស្រ័យវត្ថុ នូវមហាភូត ១ ... ។ សេចក្តីបង្រួញ ។ របស់ពួកអសញ្ញសត្វ ។បេ។ ធម៌ដែលដល់នូវសភាពធំ អាស្រ័យធម៌ដែលមានសភាពតូចថ្មារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ខន្ធទាំងឡាយដែលដល់នូវសភាពធំអាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមានសភាពតូចថ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ ដែលមានសភាពតូចថ្មារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធទាំងឡាយ ដែលដល់នូវសភាពធំ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៥៧៨ ] ធម៌ ដែលដល់នូវសភាពធំ អាស្រ័យធម៌ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺមហគ្គតាធិបតិ អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំជាវិបាក ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺចិត្ត-សមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលដល់នូវសភាពធំជាវិបាក កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្ត-សមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំ ជាវិបាក នូវខន្ធ ២ ... ។ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៥៧៩ ] ធម៌ ដែលមានប្រមាណមិនបាន អាស្រ័យធម៌ ដែលមានប្រមាណមិនបាន ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអប្បមាណាធិបតិ អាស្រ័យខន្ធទាំងឡាយ ដែលមានប្រមាណមិនបាន ។

[ ៥៨០ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានសភាពតូចឆ្មារផង ធម៌ដែលដល់នូវសភាពធំផង ទើបកើតឡើង ព្រោះនអធិប-តិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ជាវិបាកផង មហាភូតទាំងឡាយផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំផង នូវមហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។

ធម៌ដែលដល់នូវសភាពធំ អាស្រ័យធម៌ ដែលមានសភាពតូចឆ្មារផង ធម៌ដែលដល់នូវសភាពធំផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ដែលមានសភាពតូចឆ្មារផង ធម៌ដែលដល់នូវសភាពធំផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... កដត្តារូប អាស្រ័យ ខន្ធទាំងឡាយដែលដល់នូវសភាពធំផង មហាភូតទាំងឡាយផង ។

[ ៥៨១ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានសភាពតូចឆ្មារ ... ព្រោះនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ និងនឧបនិស្សយប្បច្ច័យ ។

[ ៥៨២ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានសភាពតូចឆ្មារ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានសភាពតូចឆ្មារក្នុងអរូបភព នូវខន្ធ ២ ... ចិត្តសមុដ្ឋានរូបអាស្រ័យខន្ធទាំងឡាយ ដែលមានសភាពតូចឆ្មារ ខន្ធ ៣ ក្តី កដត្តារូបក្តី អាស្រ័យខន្ធ ១ ដែលមានសភាពតូចឆ្មារ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ។បេ។ បណ្ឌិតគប្បីធ្វើមហាភូតទាំងអស់ឲ្យពិស្តារ ។ បញ្ហា ៣ ក្នុងបរិត្តមូលកៈ ( ក៏បណ្ឌិតគប្បីធ្វើឲ្យពិស្តារចុះ ) ។

[ ៥៨៣ ] ធម៌ ដែលដល់នូវសភាពធំ អាស្រ័យធម៌ដែលដល់នូវសភាព

ធំ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ នូវខន្ធ ១ ដែលដល់នូវសភាព ធំ ក្នុងអរូបភព ... ក្នុងខណៈនៃបដិសន្ធិ ... ធម៌ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ ដែលដល់នូវសភាពធំ ។បេ។ ព្រោះនបុរេជាតប្បច្ច័យ គឺចិត្ត-សមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំ កដត្តារូប អា-ស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ដែល ដល់នូវសភាពធំ ... ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ ក្តី កដត្តារូបក្តី អា-ស្រ័យខន្ធ ១ ដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។

[ ៥៨៤ ] ធម៌ ដែលមានប្រមាណមិនបាន អាស្រ័យធម៌ ដែលមាន ប្រមាណមិនបាន... ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ១ ដែលមានប្រមាណមិន បាន ក្នុងអរូប ... ។ ធម៌ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ ដែលមាន ប្រមាណមិនបាន ... ព្រោះនបុរេជាតប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធ ទាំងឡាយ ដែលមានប្រមាណមិនបាន ។

[ ៥៨៥ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានសភាព តូចឆ្មារផង ធម៌ដែលមានប្រមាណមិនបានផង ... ព្រោះនបុរេជាតប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានប្រមាណមិនបានផង មហាភូតទាំងឡាយផង ។

[ ៥៨៦ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានសភាព តូចឆ្មារផង ធម៌ដែលដល់នូវសភាពធំផង ... ព្រោះនបុរេជាតប្បច្ច័យ គឺចិត្ត-

សមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលដល់នូវសភាពធំផង នូវមហាភូត ទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលដល់នូវសភាពធំអាស្រ័យ ធម៌ដែលមានសភាពតូចថ្មារផង ធម៌ដែលដល់នូវសភាពធំផង ... ព្រោះ នបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមានសភាពតូចថ្មារក្តី ធម៌ដែល ដល់នូវសភាពធំក្តី អាស្រ័យធម៌ ដែលមានសភាពតូចថ្មារផង ធម៌ដែល ដល់នូវសភាពធំផង ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំផង មហាភូតទាំងឡាយផង ។

[ ៥៨៧ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាព តូចថ្មារ ទើបកើតឡើង ព្រោះនបច្ឆាជាតប្បច្ច័យ និងនអាសេវនប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានសភាពតូចថ្មារ នូវខន្ធ ២ ... វត្ថុ អាស្រ័យខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយ អាស្រ័យវត្ថុ មហាភូត ១ ។ សេចក្តីបង្រួញ ។ មហាភូត ១ របស់ពួក អសញ្ញសត្វ ... ។

[ ៥៨៨ ] ធម៌ដែលដល់នូវសភាពធំ អាស្រ័យធម៌ ដែលមានសភាព តូចថ្មារ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយ ដែល ដល់នូវសភាពធំអាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមានសភាព

តូចឆ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ ដែលមានសភាពតូចឆ្មារ ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធទាំងឡាយ ដែលដល់នូវសភាពធំ អាស្រ័យវត្ថុ ក្នុងខណៈនៃបដិសន្ធិ កដត្តារូប អាស្រ័យមហាភូតទាំងឡាយ ។

[ ៥៨៩ ] ធម៌ ដែលដល់នូវសភាពធំ អាស្រ័យធម៌ ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំ ជាវិបាក នូវខន្ធ ២ ... ខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ ដែលដល់នូវសភាពធំ ... ព្រោះនអាសេវនប្បច្ច័យ គឺចិត្ត-សមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ដែលដល់នូវសភាពធំ ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំ ជាវិបាក នូវខន្ធ ២ ... ខន្ធ ១ ដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ។

[ ៥៩០ ] ធម៌ ដែលមានប្រមាណមិនបាន អាស្រ័យធម៌ ដែលមានប្រមាណមិនបាន ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានប្រមាណមិនបាន ជាវិបាក ខន្ធ ២ អាស្រ័យខន្ធ ២ ។ ធម៌ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានប្រមាណមិនបាន ... ព្រោះនអាសេវនប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានប្រមាណមិនបាន ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលមានប្រមាណ

មិនបានក្តី អាស្រ័យធម៌ ដែលមានប្រមាណមិនបាន ... ព្រោះនអាសេវ-នប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានប្រមាណមិនបាន ជាវិបាក ។

[ ៥៩១ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានសភាពតូចឆ្មារផង ធម៌ដែលមានប្រមាណមិនបានផង ... ព្រោះនអាសេវនប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានប្រមាណមិនបានផង មហាភូតទាំងឡាយផង ។

[ ៥៩២ ] ធម៌ ដែលមានសភាពតូចឆ្មារ អាស្រ័យធម៌ដែលមានសភាពតូចឆ្មារផង ធម៌ដែលដល់នូវសភាពធំផង ... ព្រោះនអាសេវនប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំផង មហា-ភូតទាំងឡាយផង កដត្តារូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលដល់នូវសភាពធំ អាស្រ័យធម៌ដែលមានសភាពតូចឆ្មារផង ធម៌ដែលដល់នូវសភាពធំផង ... ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ ដែលមានសភាពតូចឆ្មារផង ធម៌ដែលដល់នូវសភាពធំផង ទើបកើតឡើង ព្រោះនអាសេវនប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំផង វត្ថុផង ក្នុងខណៈនៃបដិសន្ធិ នូវខន្ធ ២ ... កដត្តារូប អាស្រ័យខន្ធទាំង

ឡាយ ដែលដល់នូវសភាពធំផង មហាភូតទាំងឡាយផង ។

[ ៥៩៣ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាពតូចថ្មារ ទើបកើតឡើង ព្រោះនកម្មប្បច្ច័យ គឺចេតនាដែលមានសភាពតូចថ្មារ អាស្រ័យខន្ធទាំងឡាយ ដែលមានសភាពតូចថ្មារ ពាហិរ ... អាហារសមុដ្ឋាន ... ឧតុសមុដ្ឋាន មហាភូត ១ ... ។

[ ៥៩៤ ] ធម៌ ដែលដល់នូវសភាពធំ អាស្រ័យធម៌ដែលដល់នូវសភាពធំ ... ព្រោះនកម្មប្បច្ច័យ គឺចេតនាដែលដល់នូវសភាពធំ អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ។

[ ៥៩៥ ] ធម៌ ដែលមានប្រមាណមិនបាន អាស្រ័យធម៌ ដែលមានប្រមាណមិនបាន ... ព្រោះនកម្មប្បច្ច័យ គឺចេតនាដែលមានប្រមាណមិនបាន អាស្រ័យខន្ធទាំងឡាយ ដែលមានប្រមាណមិនបាន ។

[ ៥៩៦ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាពតូចថ្មារ ... ព្រោះនវិបាកប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានសភាពតូចថ្មារ នូវខន្ធ ២ ... មហាភូត ៣ អាស្រ័យមហាភូត ១ ចិត្តសមុដ្ឋានរូប និងឧបាទារូប អាស្រ័យមហាភូតទាំងឡាយ ពាហិរ ... អាហារ ... ឧតុ ... មហាភូត ១ របស់ពួកអសញ្ញសត្វ ... ។

[ ៥៩៧ ] ធម៌ ដែលដល់នូវសភាពធំ អាស្រ័យធម៌ដែលដល់នូវសភាពធំ ... ព្រោះនវិបាកប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំ នូវខន្ធ ២ ... ។ ធម៌ដែលមានសភាពតូចថ្មារ អាស្រ័យ

ធម៌ដែលដល់នូវសភាពធំ ... ព្រោះនវិបាកប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ។ ធម៌ដែលមានសភាពតូចថ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី អាស្រ័យធម៌ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលដល់នូវសភាពធំ នូវខន្ធ ២ ... ។

[ ៥៩៨ ] ធម៌ ដែលមានប្រមាណមិនបាន អាស្រ័យធម៌ ដែលមានប្រមាណមិនបាន ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានប្រមាណមិនបាន ។ ធម៌ដែលមានសភាពតូចថ្មារ អាស្រ័យ ធម៌ដែលមានប្រមាណមិនបាន ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានប្រមាណមិនបាន ។ ធម៌ដែលមានសភាពតូចថ្មារក្តី ធម៌ដែលមានប្រមាណមិនបានក្តី អាស្រ័យធម៌ ដែលមានប្រមាណមិនបាន ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យខន្ធ ១ ដែលមានប្រមាណមិនបាន នូវខន្ធ ២ ... ។

[ ៥៩៩ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាពតូចថ្មារផង ធម៌ដែលមានប្រមាណមិនបានផង ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយ ដែលមានប្រមាណមិនបានផង មហាភូតទាំងឡាយផង ។

[ ៦០០ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាព

តូចថ្មារផង ធម៌ដែលដល់នូវសភាពធំផង ទើបកើតឡើង ព្រោះនវិបាកប្បច្ច័យ គឺចិត្តសមុដ្ឋានរូប អាស្រ័យខន្ធទាំងឡាយដែលដល់នូវសភាពធំផង មហាភូតទាំងឡាយផង ។

[ ៦០១ ] ធម៌ ដែលមានសភាពតូចថ្មារ អាស្រ័យធម៌ដែលមានសភាពតូចថ្មារ ទើបកើតឡើង ព្រោះនអាហារប្បច្ច័យ គឺពាហិរ ... ឧតុ ... របស់ពួកអសញ្ញសត្វ ... ។ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។ ព្រោះនឥន្ទ្រិយប្បច្ច័យ ពាហិរ ... អាហារ ... ឧតុ ... រូបជីវិតិន្ទ្រិយ អាស្រ័យមហាភូតទាំងឡាយរបស់ពួកអសញ្ញសត្វ ខន្ធ ១ ដែលប្រកបដោយបញ្ចវិញ្ញាណ ... ពាហិរ ... ព្រោះនឈានប្បច្ច័យ ។ សេចក្តីបង្រួញ ។ មហាភូត ១ របស់ពួកអសញ្ញសត្វ ។បេ។ បណ្ឌិតគប្បីធ្វើនូវមហាភូតទាំងអស់ ។ ព្រោះនមគ្គប្បច្ច័យ គឺនូវខន្ធ ១ ដែលមានសភាពតូចថ្មារ ជាអហេតុកៈ ... នូវខន្ធ ១ ក្នុងអហេតុកប្បដិសន្ធិ ។ សេចក្តីបង្រួញ ។ បណ្ឌិតគប្បីធ្វើនូវមហាភូតទាំងអស់ ។ ព្រោះនសម្បយុត្តប្បច្ច័យ ។

[ ៦០២ ] ... ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ៣ អាស្រ័យខន្ធ ១ ដែលមានសភាពតូចថ្មារ ក្នុងអរូប នូវខន្ធ ២ ... ពាហិរ ... អាហារ ... ឧតុ ... របស់ពួកអសញ្ញសត្វ ... ។ ធម៌ដែលដល់នូវសភាពធំ អាស្រ័យធម៌ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលដល់នូវសភាពធំ ក្នុងអរូប ... ។

[ ៦០៣ ] ធម៌ ដែលមានប្រមាណមិនបាន អាស្រ័យធម៌ ដែលមាន

ប្រមាណមិនបាន ទើបកើតឡើង ព្រោះនវិប្បយុត្តប្បច្ច័យ គឺខន្ធ ១ ដែលមានប្រមាណមិនបាន ក្នុងអរូប ... ព្រោះនោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ ។

[ ៦០៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ និងនឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ១៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ និងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៦០៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ និងនឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុង

នវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

អនុលោមបច្ចនីយៈ ចប់

[ ៦០៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ។ សេចក្ដីបង្រួញ ។ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

បដិច្ចវារៈ ចប់

សហជាតវារៈ ប្រាកដស្មើដោយបដិច្ចវារៈដែរ ។

## បច្ចយវារៈ

[ ៦០៧ ] ធម៌ ដែលមានសភាពតូចថ្មារ ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចថ្មារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលមានសភាពតូចថ្មារ នឹងខន្ធ ២ ... វត្ថុពឹងផ្អែកនឹងខន្ធទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ឧបាទារូបពឹងផ្អែកនឹងមហាភូត ១ ខន្ធទាំងឡាយ ដែលមានសភាពតូចថ្មារ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលដល់នូវសភាពធំ ពឹងផ្អែកនឹងធម៌ដែលមានសភាពតូចថ្មារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ខន្ធទាំងឡាយដែល

ដល់នូវសភាពធំ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ខន្ធទាំងឡាយដែលដល់នូវសភាពធំ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលមានប្រមាណមិនបាន ពឹងផ្អែកនឹងធម៌ដែលមានសភាពតូចឆ្មារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមានប្រមាណមិនបាន ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលមានប្រមាណមិនបានក្តី ពឹងផ្អែកនឹងធម៌ដែលមានសភាពតូចឆ្មារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលមានប្រមាណមិនបាន ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី ពឹងផ្អែកនឹងធម៌ដែលមានសភាពតូចឆ្មារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

[ ៦០៨ ] ធម៌ ដែលដល់នូវសភាពធំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវសភាពធំ នឹងខន្ធ ១ ដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមានសភាពតូចឆ្មារ ពឹងផ្អែកនឹងធម៌ ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី ពឹងផ្អែកនឹងធម៌ ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹង

ផ្អែកនឹងខន្ធ ១ ដែលដល់នូវសភាពធំ នឹងខន្ធ ២ ... នឹងខន្ធ ១ ដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៦០៩ ] ធម៌ ដែលមានប្រមាណមិនបាន ពឹងផ្អែកនឹងធម៌ ដែលមានប្រមាណមិនបាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺក្នុងអប្បមាណធម៌មានវារៈ ( នៃបុច្ឆា និងវិសជ្ជនា ) ៣ លើក ។

[ ៦១០ ] ធម៌ ដែលមានសភាពតូចថ្នារ ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចថ្នារផង នឹងធម៌ដែលមានប្រមាណមិនបានផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមានប្រមាណមិនបានផង នឹងមហាភូតទាំងឡាយផង ។ ធម៌ដែលមានប្រមាណមិនបាន ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចថ្នារផង ដែលមានប្រមាណមិនបានផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលមានប្រមាណមិនបានផង នឹងវត្ថុផង ។ ធម៌ដែលមានសភាពតូចថ្នារក្តី ធម៌ដែលមានប្រមាណមិនបានក្តី ពឹងផ្អែកនឹងធម៌ដែលមានសភាពតូចថ្នារផង ធម៌ដែលមានប្រមាណមិនបានផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលមានប្រមាណមិនបានផង វត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមានប្រមាណមិនបានផង មហាភូតទាំងឡាយផង ។

[ ៦១១ ] ធម៌ ដែលមានសភាពតូចថ្នារ ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចថ្នារផង ធម៌ដែលដល់នូវសភាពធំផង ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ ( បានដល់ វារៈនៃបុច្ឆា និងវិសជ្ជនា ) ៣ លើក ។ សូម្បីវារៈ ( នៃបុច្ឆា និងវិសជ្ជនា ) ៣ លើក ក្នុងខណៈនៃបដិសន្ធិ ក៏បណ្ឌិតគប្បីធ្វើ ។

[ ៦១២ ] ធម៌ ដែលមានសភាពតូចឆ្មារ ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចឆ្មារ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលមានសភាពតូចឆ្មារ នឹងខន្ធ ២ ... ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ ពឹងផ្អែកនឹងកាយាយតនៈ ... ខន្ធទាំងឡាយ ដែលមានសភាពតូចឆ្មារ ពឹងផ្អែកនឹងវត្ថុ ។ បញ្ហា ៦ យ៉ាងដ៏សេស ប្រាកដស្មើដោយហេតុប្បច្ច័យ បណ្ឌិតគប្បីធ្វើឲ្យទៅជាបញ្ហា ៧ យ៉ាង ។ បដិសន្ធិដោយអធិបតិប្បច្ច័យ មិនមានទេ បញ្ហា ១៧ យ៉ាង មានគ្រប់គ្រាន់ហើយ ។ ព្រោះអនន្តរប្បច្ច័យ ។ សេចក្តីបង្រួញ ។ ព្រោះអវិគតប្បច្ច័យ ។

[ ៦១៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៧ ក្នុងកម្មប្បច្ច័យ មានវារៈ ១៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១៧ ក្នុងអាហារប្បច្ច័យ មានវារៈ ១៧ ក្នុងឥន្ទ្រិ-

យប្បច្ច័យ ឈានប្បច្ច័យ និងមគ្គប្បច្ច័យ មានវារៈ ១៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៧ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១៧ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៧ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោម ចប់

[ ៦១៤ ] ធម៌ ដែលមានសភាពតូចថ្នារ ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចថ្នារ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលមានសភាពតូចថ្នារ ជាអហេតុកៈ នឹងខន្ធ ២ ... វត្ថុ ពឹងផ្អែកនឹងខន្ធទាំងឡាយ ក្នុងខណៈនៃអហេតុកប្បដិសន្ធិ ខន្ធទាំងឡាយ ពឹងផ្អែកនឹងវត្ថុ មហាភូត ១ ។ សេចក្តីបង្រួញ ។ របស់ពួកអសញ្ញសត្វ ... ចក្ខុវិញ្ញាណ ពឹងផ្អែកនឹងចក្ខាយតនៈ នឹងកាយាយតនៈ ... ខន្ធទាំងឡាយដែលមានសភាពតូចថ្នារ ជាអហេតុកៈ ពឹងផ្អែកនឹងវត្ថុ មោហៈដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែកនឹងខន្ធទាំងឡាយដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង វត្ថុផង ។

[ ៦១៥ ] ធម៌ ដែលមានសភាពតូចថ្នារ ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចថ្នារ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ គឺវារៈ ៥ ប្រាកដស្មើដោយបដិច្ចវារៈដែរ ។

[ ៦១៦ ] ធម៌ ដែលមានសភាពតូចថ្នារ ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចថ្នារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្ត-

សមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលមានសភាពតូចឆ្មារ នឹងខន្ធ ២ ... របស់ពួកអសញ្ញសត្វ ក្នុងខណៈនៃបដិសន្ធិ ... ចក្ខាយតនៈ ... កាយាយតនៈ ... ខន្ធទាំងឡាយដែលមានសភាពតូចឆ្មារ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលដល់នូវសភាពធំ ពឹងផ្អែកនឹងធម៌ដែលមានសភាពតូចឆ្មារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ដែលដល់នូវសភាពធំ ពឹងផ្អែកនឹងវត្ថុ ខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ជាវិបាក ពឹងផ្អែកនឹងវត្ថុ ខន្ធទាំងឡាយដែលដល់នូវសភាពធំ ពឹងផ្អែកនឹងវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ដែលមានប្រមាណមិនបាន ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចឆ្មារ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអប្បមាណាធិបតិ ពឹងផ្អែកនឹងវត្ថុ ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី ពឹងផ្អែកនឹងធម៌ដែលមានសភាពតូចឆ្មារ ... ព្រោះនអធិបតិប្បច្ច័យ គឺខន្ធទាំងឡាយដែលដល់នូវសភាពធំ ជាវិបាក ពឹងផ្អែកនឹងវត្ថុ ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងមហាភូតទាំងឡាយ ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៦១៧ ] ធម៌ ដែលដល់នូវសភាពធំ ពឹងផ្អែកនឹងធម៌ ដែលដល់នូវសភាពធំ ... ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ ដែលដល់នូវសភាពធំ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវសភាពធំ ជាវិបាក នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមានសភាពតូចឆ្មារ ពឹងផ្អែកនឹងធម៌ ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំង

ឡាយដែលដល់នូវសភាពធំ ជាវិបាក ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមានសភាពតូចឆ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី ពឹងផ្អែកនឹងធម៌ដែលដល់នូវសភាពធំ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី ពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវសភាពធំ ជាវិបាក នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៦១៨ ] ធម៌ ដែលមានប្រមាណមិនបាន ពឹងផ្អែកនឹងធម៌ ដែលមានប្រមាណមិនបាន ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ដែលមានប្រមាណមិនបាន ពឹងផ្អែកនឹងខន្ធទាំងឡាយដែលមានប្រមាណមិនបាន ។

[ ៦១៩ ] ធម៌ ដែលមានប្រមាណមិនបាន ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចឆ្មារផង ធម៌ដែលមានប្រមាណមិនបានផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ ដែលមានប្រមាណមិនបាន ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលមានប្រមាណមិនបានផង វត្ថុផង ។

[ ៦២០ ] ធម៌ ដែលមានសភាពតូចឆ្មារ ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចឆ្មារផង ធម៌ដែលដល់នូវសភាពធំផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ គឺចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ជាវិបាកផង មហាភូតទាំងឡាយផង ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលដល់នូវសភាពធំ ពឹងផ្អែកនឹងធម៌ដែលមានសភាពតូចឆ្មារផង ធម៌ដែលដល់នូវសភាពធំផង ... ព្រោះនអធិបតិប្បច្ច័យ គឺអធិបតិធម៌ដែលដល់នូវសភាពធំ ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវសភាពធំផង វត្ថុផង

ខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវសភាពធំ ជាវិបាកផង វត្ថុផង នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។ ធម៌ដែលមានសភាពតូចថ្មារក្តី ធម៌ដែលដល់នូវសភាពធំក្តី ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចថ្មារផង ធម៌ដែលដល់នូវសភាពធំផង ... ព្រោះនអធិបតិប្បច្ច័យ គឺខន្ធ ៣ ពឹងផ្អែកនឹងខន្ធ ១ ដែលដល់នូវសភាពធំ ជាវិបាកផង វត្ថុផង នឹងខន្ធ ២ ... ចិត្តសមុដ្ឋានរូប ពឹងផ្អែកនឹងខន្ធទាំងឡាយ ដែលដល់នូវសភាពធំ ជាវិបាកផង មហាភូតទាំងឡាយផង ពឹងផ្អែកនឹងខន្ធទាំងឡាយដែលដល់នូវសភាពធំ ក្នុងខណៈនៃបដិសន្ធិ ។

[ ៦២១ ] ធម៌ ដែលមានសភាពតូចថ្មារ ពឹងផ្អែកនឹងធម៌ ដែលមានសភាពតូចថ្មារ ទើបកើតឡើង ព្រោះនអនន្តរប្បច្ច័យ នសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ នឧបនិស្សយប្បច្ច័យ និងនបុរេជាតប្បច្ច័យ ឯបញ្ហា ១២ យ៉ាង ប្រាកដស្មើដោយបដិច្ចវារៈដែរ ។ ព្រោះនបច្ឆាជាតប្បច្ច័យ និងនអាសេវនប្បច្ច័យ ( ពាក្យនេះ ) មានគ្រប់គ្រាន់ ។ ពាក្យថា វិបាក បណ្ឌិតគប្បីសម្តែង ។ ចិត្តសមុដ្ឋានរូប បណ្ឌិតមិនគប្បីធ្វើថា ដូចជាវិបាកទេ ។ ព្រោះនកម្មប្បច្ច័យ និងនវិបាកប្បច្ច័យ ឯបដិសន្ធិនិងវិបាកមិនមានទេ ។ ព្រោះនអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ នមគ្គប្បច្ច័យ នសម្បយុត្តប្បច្ច័យ នវិប្បយុត្តប្បច្ច័យ នោនត្ថិប្បច្ច័យ និងនោវិគតប្បច្ច័យ ។

[ ៦២២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១២ ក្នុងនអនន្តរប្បច្ច័យ មាន

វារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ នអញ្ញមញ្ញប្បច្ច័យ នឧបនិស្សយប្បច្ច័យ និងនបុរេជាតប្បច្ច័យ មានវារៈ ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៧ ក្នុងនកម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១៧ ក្នុងនអាហារប្បច្ច័យ នឥន្ទ្រិយប្បច្ច័យ នឈានប្បច្ច័យ និងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## បច្ចនីយៈ ចប់

[ ៦២៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ... ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១២ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៧ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៧ ក្នុងនកម្មប្បច្ច័យ មានវារៈ ៧ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

## អនុលោមប្បច្ចនីយៈ ចប់

[ ៦២៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ... ក្នុងអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ វិគតប្បច្ច័យ និង អវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់យ៉ាងនេះចុះ ។

បច្ចនីយានុលោម ចប់

បច្ចយវារៈ ចប់

និស្សយវារៈ ប្រាកដស្មើដោយបច្ចយវារៈដែរ ។

# សំសដ្ឋវារៈ

[ ៦២៥ ] ធម៌ ដែលមានសភាពតូចឆ្មារ ច្រឡំនឹងធម៌ដែលមានសភាព តូចឆ្មារ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ច្រឡំនឹងខន្ធ ១ ដែល មានសភាពតូចឆ្មារ នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ... ។

[ ៦២៦ ] ធម៌ ដែលដល់នូវសភាពធំ ច្រឡំនឹងធម៌ដែលដល់នូវសភាព ធំ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ច្រឡំនឹងខន្ធ ១ ដែលដល់ នូវសភាពធំ នឹងខន្ធ ២ ... ក្នុងខណៈនៃបដិសន្ធិ ... ។

[ ៦២៧ ] ធម៌ ដែលមានប្រមាណមិនបាន ច្រឡំនឹងធម៌ ដែលមាន ប្រមាណមិនបាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺខន្ធ ៣ ច្រឡំនឹង ខន្ធ ១ ដែលមានប្រមាណមិនបាន នឹងខន្ធ ២ ... ។

